
វិធីបង្រៀនធម្មកថិកថ្មី
អោយចេះទេសនា
អាចារ្យ យិន ទន់

# ច្បាប់ស្តីបទដែលធម្មកថិកថ្មីត្រូវចេះចាំ

១) បើឡើងលើគ្រែហើយ មើលគេឯងអោយសព្វទើបដាក់មុខទៅវិញ ហើយសឹមទេសនា ដើម្បីកុំឱ្យញ័រភ័យ ។

២) ត្រូវតាំងចិត្តកុំខ្លាចគេ បើអញទេសន៍តាមធម៌វិន័យ នរណាមកយកខុសអញ ។

៣) ត្រូវទេសនាឱ្យមួយៗ ច្បាស់ៗ កុំញាប់ពេកកុំរង្វើលពេកធ្វើសម្តីបីយ៉ាង សម្តីស្តេច សម្តីពេជ្ឈឃាត សម្តីនាង កណ្តាលល្មម ខ្លាំងគ្រលួច ក្រអួន ។

៤) ត្រូវឱ្យចាំធម៌ពិតប្រាកដកុំឱ្យទៅនឹកផង ថាផង កណ្តាលហ្វូងមនុស្ស។

៥) បើទេសន៍ទៅត្រូវរឿងគេសើច យើងអ្នកទេសន៍ កុំសើចធ្វើមុខឱ្យស្លូត ។

៦) ត្រូវដកដង្ហើមតាមច្រមុះ កុំដកដង្ហើមតាមមាត់ឆាប់ស្អក ព្រោះខ្យល់តាមមាត់ខ្លាំងណាស់ ស្ងួតបំពង់ក បើដកបង្ហើមយើងត្រូវខ្ទប់បិទមាត់ ហិតដកបង្ហើមតាមច្រមុះ ទើបមិនស្ងួតបំពង់ក ទេសនាស្រួល ។

## <u>អង្គទេសនាបីយ៉ាង</u>

១) សេចក្តីផ្តើម ពាក្យថាសេចក្តីផ្តើមនេះ គឺរកហេតុអំពីបុណ្យដែលគេធ្វើ តើមានពីត្រឹមណាមក ត្រូវនឹងធម្មាធិដ្ឋានអ្វី បុគ្គលាធិដ្ឋានអ្វីយកមកសម្តែងផ្តើមធម៌ទេសនា (កុំគេធ្វើអំពីកឋិន ទៅទេសនាអំពីបុណ្យផ្កានោះ)។

២) អធិប្បាយ ត្រូវយើងអធិប្បាយ អំពីធម៌វិន័យ រឺរឿងរ៉ាវដែលយើងរកឃើញនោះៗ ឱ្យបានក្បោះក្បាយទូលំទូលាយប្រៀបធៀបផ្លូវលោក ផ្លូវធម៌ឱ្យឃើញពិតៗ ឱ្យដល់គំនិតឧបាសក ឧបាសិកាដែលគេស្តាប់ស្ញើចខ្លាច ត្រេកអរអំពើកុសល ។

៣) ប្រយោជន៍ យើងត្រូវសម្តែងប្រាប់ រកប្រយោជន៍ផលដែលគេធ្វើបានបុណ្យដូចម្តេច មានរឿងនិទានយ៉ាងណា ទៅកើតឯណា បានផលានិសង្សប៉ុន្មាន (រូបនិគមវចនឱ្យពរចប់ធម៌ទេសនាទៅ) ។

## ឱ្យពរចប់ធម៌ទេសនា

[1] "និគមវចនធម៌ដែល (ខ្ញុំព្រះករណា) អាត្មាភាពបានសម្តែងអម្បាញមិញនេះ ដូចបានអធិប្បាយមកហើយ ក៏ល្មមសមគួរដល់កាលវេលាតែ (ខ្ញុំព្រះករុណា) អាត្មាភាពសូមប្រគេនពរនិងជូនពរស័ព្ទសាធុការដល់សាធុសប្បុរសប្រុស-ស្រី ដែលមកស្តាប់ធម៌ទេសនាក្នុងទីនេះ សូមឱ្យបានបុញ្ញកុសលផលទានជូនដល់បុព្វការីជន នៅរស់ក្តី ចែកឋានទៅហើយក្តី បើចែកឋានទៅទីទាបឬទីខ្ពស់ **ទេវា គន្ធា និវេទយុំ** ទេព្តាជាប្លង់តុង ចូរនាំកុសលនេះឱ្យបានដល់មាតាបិតារបស់លោកអ្នកសប្បុរស ប្រាប់ថាកូនចៅឯនេះបានធ្វើបុណ្យបញ្ជូនទៅឱ្យ កាលណាបើមាតាបិតាទាំងនោះបានទទួលហើយ នឹងសូមឱ្យបានផលមកទេព្តាទាំងមួយម៉ឺន(១០០០០) លោកធាតុ មួយចំណែកផងសូមឱ្យរក្សាព្រះពុទ្ធសាសនាមហាក្សត្រកម្ពុជាប្រជាជន ក្នុងដែនដីប្រទេសប្រកបតែសេចក្តីសុខសេចក្តីចម្រើន កើនដល់អ្នកដើមបុណ្យ ជាមហាស្វារ្យកុសលសម្រេចនូវសម្បត្តិទាំងបីប្រការគឺ : សម្បត្តិមនុស្ស១ សម្បត្តិទេព្តា១ សម្បត្តិព្រះនិព្វាន១ តាមសមគួរដល់កម្លាំងសទ្ធាចេតនា ប្រាថ្នារបស់ (ព្រះករុណា) អស់លោកអ្នកចុះ យំ យំ ឥច្ឆិតំ តំ ខិប្បមេវ សមិជ្ឈតុ (ព្រះករុណា) អស់លោកអ្នកសច្ចាប្រណិធានបួងសួងយ៉ាងណាៗសូមឱ្យបានសម្រេចយ៉ាងនេះៗចុះ កុំបីឃ្លៀងឃ្លាតទៅជាបការៈដទៃ**ឡើយ អយំ សង្ខេបេន ធម្មទេសនំ សមត្តា** ធម៌ទេសនាមិនទាន់ចប់សព្វគ្រប់ទេ ប៉ុន្តែសន្មតថាចប់ដោយសង្ខេបបន្ទាប់តាមកាលវេលាតែប៉ុននោះ **ឯវំ** ។

★ ★ ★

[1] និគមវចននេះ បើមានយកធម៌ដទៃមកសម្តែងសូមឱ្យរាប់មាតិកាធម៌នោះមកផង មុនដែលចប់ធម៌ទេសនា ។

# ប្រយោជន៍ទាន់ភ្នែក

ពរទាំងឡាយបួនប្រការគឺ : អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ **វឌ្ឍន្តុ** ចូរចម្រើនកើតមានដល់អស់លោក ជាពុទ្ធសាសនូបត្ថម្ភទាំងឡាយដែលបានអញ្ជើញមកអំពីទីជិតក្ដី-ឆ្ងាយក្ដី សុទ្ធតែមានចំនង់ចង់ស្ដាប់ព្រះធម៌ទេសនាជាគ្រឿងដាស់សតិបញ្ញាស្មារតី និងជាវត្ថុបដិបត្តិរៀងៗខ្លួន ។

ហើយក៏បានអារាធនានិមន្ត អាត្មាភាពឱ្យជាអ្នកសម្ដែងធម៌ទេសនាអាត្មាភាពក៏ទទួលនិមន្ត ធ្វើជាធម្មកថិកាចារ្យមួយរូបដែលត្រូវលើកយកធម៌វិន័យត្រង់ណាមួយតាមសមគួរ មកសម្ដែងចែកជូនដល់អស់លោកសប្បុរសទាំងឡាយក្នុងវត្តិសម័យនេះដែរ។ ក៏ប៉ុន្តែប្រសិនជាសម្ដែងទៅហើយ ជួនជាមាន បើលើសលោះខ្វះខាតដោយបទបាថបាលីសេចក្ដីអធិប្បាយត្រង់កន្លែងណាមួយ ពុំបានទូលំទូលាយសមរម្យត្រូវតាមអធ្យាស្រ័យនិស្ស័យចិត្តថ្លើម របស់អស់លោក-អ្នកសប្បុរសជាពុទ្ធបរិសទ្យទាំងឡាយនោះ ក៏សូមខន្តីប្រណីទោសដល់អាត្មាភាព ដែលជាអ្នកសម្ដែងទៅតាមសតិបញ្ញាស្មារតី និងការចេះចាំតិចតួចស្ដួចស្ដើង សូមចម្រើនពរ ។

**តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតទិវសតោ បដ្ឋាយ យាវជ្ជតនា ពុទ្ធសាសនស្សាយុកាលស្ស គណនាយ សល្លក្ខេតព្វា ។**

សូមពុទ្ធបរិសទ្យទាំងឡាយ គឺគ្រហស្ថបព្វជិតដែលកាន់ពុទ្ធសាសនារួមជាមួយគ្នា គប្បីដឹងនូវអាយុកាលនៃពុទ្ធសាសនា រាប់ចាប់ពីដើមតាំងអំពីថ្ងៃដែលអង្គស្ដេចព្រះសម្មាសម្ពុទ្ធ ដ៏មានព្រះភាគព្រះអង្គនោះ ទ្រង់រំលត់ខន្ធចូលទៅកាន់បរមនិព្វានទៅមកទល់គ្នានឹងថ្ងៃនេះ អាយុកាលនៃពុទ្ធសាសនា **អតិក្កន្តានិ** កន្លងហើយបាន[2] (...) ឆ្នាំ ខែកន្លងទៅហើយបាន(...) ខែ ថ្ងៃកន្លងទៅហើយបាន(...)ថ្ងៃ។ បច្ចុប្បន្នកាលឥឡូវនេះនៅក្នុងឆ្នាំ (...ស័ក) ក្នុង(...) រដូវ (...) ខែ (...) ថ្ងៃ (...)។ ថ្ងៃ ខែ ឆ្នាំនេះ លោកសន្មតទុកថាជាបច្ចុប្បន្នកាល **អនាគតេ កាលេ** អាយុកាលនៃពុទ្ធសាសនានៅសល់ឋានខាងមុខទៀត - (២៥៥...)ឆ្នាំ (...) ខែ (...) ថ្ងៃ បូករួមសិរីទាំងបីកាលគឺ :

---

[2] ត្រង់វង់ក្រចក សូមព្រះករុណាបញ្ចូល ថ្ងៃ ខែ ឆ្នាំ ។

អតីត អនាគត បច្ចុប្បន្ន មុនក្រោយ ត្រូវជាអាយុកាលនៃពុទ្ធសាសនា ដែលប្រទេសយើងធ្លាប់និយមរាប់អានគ្រប់ចួនជា ៥.០០០ ព្រះវស្សាដោយបរិបូណ៌ ។

**តទនន្តរំ** បន្ទាប់ពីការបកសករាជនេះទៅ :

អាត្មាភាព សូមលើកយកប្រយោជន៍ទាន់ភ្នែកមកសម្តែងដូចតទៅនេះ :

១- ទ្រព្យសម្បត្តិ បរិវារសម្បត្តិ កេរ្តិ៍ឈ្មោះ យសស័ក្តិ ជាដើមដែលបុគ្គលស្វែងរកបានមកសមតាមឆន្ទៈបំណង ជាផលឱ្យកើតសេចក្តីសុខកាយសប្បាយចិត្តឃើញច្បាស់ក្នុងបច្ចុប្បន្នក្នុងពេលដែលជីវិតរស់នៅឡើយ ហៅថាទិដ្ឋធម្មិកត្ថៈ ប្រែថាប្រយោជន៍ទាក់ភ្នែក-ប្រយោជន៍បច្ចុប្បន្ន ។

★ ★ ★

# ទិដ្ឋធម្មិកត្ថប្រយោជន៍

## <u>អធិប្បាយប្រយោជន៍ទាក់ភ្នែក</u>

ធម៌ដែលជាហេតុឱ្យសម្រេចប្រយោជន៍ទាន់ភ្នែកមានបួនយ៉ាងគឺ:

១. **ឧដ្ឋានសម្បទា** បរិបូណ៌ដោយការព្យាយាម

២. **អារក្ខសម្បទា** បរិបូណ៌ដោយការរក្សា

៣. **កល្យាណមិត្តតា** ការគប់មិត្តសំលាញ់ល្អ

៤. **សមជីវិតា** ការចិញ្ចឹមជីវិតស្មើ ។

មុននឹងអធិប្បាយសម្បទាបួនយ៉ាង ដែលជាហេតុឱ្យកើតផលប្រយោជន៍សេចក្តីសុខ សេចក្តីចម្រើនឱ្យទាន់ភ្នែក អាត្មាភាពសូមអធិប្បាយអំពីទ្រព្យសម្បត្តិបន្តិចជាមុនសិន ។ ព្រោះទ្រព្យសម្បត្តិជារបស់ដែលមនុស្សលោកទាំងមូលតែប្រាថ្នាចង់បាន ចង់ជួនប្រទះ ។ ដ្បិតវត្ថុទាំងនេះអាចឱ្យសម្រេចសេចក្តីសុខកាយ សប្បាយចិត្តតាមបំណង មនុស្សអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភរមែងមានសេចក្តីរីករាយ ដោយពុំសូវមានការខ្វល់ខ្វាយព្រួយចិត្តគំនិត គិតអំពីការខ្វះខាត។ ព្រោះខ្លួនជាអ្នកបរិបូណ៌

គ្រប់គ្រាន់ បើនឹងចង់ប្រើប្រាស់បរិភោគចាយវាយពេលណា ក៏បានទាន់ចិត្តពេលនោះ ។

ព្រោះហេតុដូចនេះ បានជាទ្រព្យសម្បត្តិនេះ ជារបស់គឺបុគ្គលគប្បីប្រាថ្នាក្នុងខាងដើម ។

កាលបើមានទ្រព្យសម្បត្តិ ដែលជាប្រយោជន៍ក្នុងបច្ចុប្បន្នបរិបូណ៌ហើយវាជាការងាយស្រួលក្នុងការស្វែងរកប្រយោជន៍បរលោក និងប្រយោជន៍ក្នុងព្រះនិព្វានតទៅ។

ឯទ្រព្យសម្បត្តិរបស់មនុស្សក្នុងលោក មានច្រើនបែបច្រើនយ៉ាងមិនអាចរាប់ឈ្មោះឱ្យបានសព្វគ្រប់ឡើយ តែបើសរុបរាប់យកឈ្មោះនៃទ្រព្យដែលសំខាន់ៗ ដែលអាចឱ្យសម្រេចសេចក្តីសុខកាយសប្បាយចិត្តដល់បុគ្គលជាម្ចាស់ ឃើញទាន់ភ្នែកក្នុងលោកនេះ នឹងតាមជូនឱ្យបានសេចក្តីសុខកាយសប្បាយចិត្តក្នុងភពទៅមុខទៀតនោះមាន ៤ យ៉ាងគឺ :

១. **ថាវរនិធិ** កំណប់ទ្រព្យនៅនឹងកន្លែង

២. **ជង្គមនិធិ** កំណប់ទ្រព្យដើរបាន

៣. **អង្គសមនិធិ** កំណប់ទ្រព្យនៅក្នុងខ្លួន

៤. **អនុគាមិកនិធិ** កំណប់ទ្រព្យជាប់តាមខ្លួនទៅ ។

មាស ប្រាក់ កែវ កង ចិញ្ចៀនត្បូង ពិទូរ្យ សូរកាន្ត ចារកន្ទ្រំ ពេជ្រនិល ស្រែចម្ការ រីទ្រព្យ របស់ណាៗ ដែលជាពួកទ្រព្យឥតវិញ្ញាណកម្រើកឯងៗ មិនបានហៅថាកំណប់ទ្រព្យនៅនឹងកន្លែង ។

ខ្ញុំកំដរ-មនុស្សបម្រើ ប្រុស ស្រី គោ ក្របី ដំរីសេះ រហូតដល់ទ្រព្យណាៗដែលជាពួកទ្រព្យមានវិញ្ញាណកម្រើកឯងៗបាន ហៅថា កំណប់ទ្រព្យដើរបាន ។

ការងារ សិល្ប៍វិទ្យា ឬចំណេះវិជ្ជាណា ដែលរៀនចេះចាំនាំបានក្នុងចិត្តដែលហេតុនាំឱ្យសម្រេចការចិញ្ចឹមជីវិតបានហៅថាកំណប់ទ្រព្យនៅក្នុងខ្លួន ។

ទាន សីល ភាវនា ឬបុណ្យកុសលឯណា ដែលជាប់តាមឱ្យផលដូចស្រមោចហៅថា កំណប់ទ្រព្យជាប់តាមខ្លួនទៅ ។

កំណប់ទ្រព្យទាំង ៤យ៉ាងនេះ បើបុគ្គលស្វែងរកបានហើយ ជាផលប្រយោជន៍

ឱ្យកើតសេចក្ដីសុខក្នុងលោកនេះ និងលោកខាងមុខ។

បានជាលោកឱ្យឈ្មោះថា **"កំណប់ទ្រព្យ"** ព្រោះជារបស់ដែលបុគ្គលត្រូវជីកគាស់ឡើងដោយច្រនីក គឺសេចក្ដីព្យាយាមតស៊ូយ៉ាងខ្លាំងឱ្យដូចជាគេជីកគាស់កំណប់ដែលគេកប់ក្នុងផែនដីទើបបាន បើប្រាសចាកសេចក្ដីព្យាយាមជាជនខ្ជិលច្រអូសមិនអាចនឹងគាស់យកបានឡើយ ព្រោះហេតុនេះបានជាព្រះបរមគ្រូនៃយើង កាលនឹងទ្រង់ត្រាស់ទេសនាអំពីសម្បទាទាំង ៤ ដែលជាហេតុឱ្យបានកំណប់ទ្រព្យជាប្រយោជ-ន៍ឱ្យកើតសេចក្ដីសុខទាន់ភ្នែកក្នុងលោកនេះទ្រង់លើកយក **ឧដ្ឋានសម្បទា (ការបរិបូណ៌ដោយសេចក្ដីប្រឹងប្រែង**) ឡើងសម្ដែងជាដំបូងនៃសម្បទាទាំងពួង ។

ព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅថា អ្នកស្វែងរកទ្រព្យសម្បត្តិដែលជាផលឱ្យបានសេចក្ដីសុខក្នុងជាតិនេះ ត្រូវប្រកបដោយហេតុគឺ សម្បទា ៤យ៉ាងដូចអាត្មាសម្ដែងមកខាងដើម ដែលនឹងអធិប្បាយតទៅនេះ ÷

**១. ឧដ្ឋានសម្បទា** បុគ្គលគ្រប់រូបក្នុងលោកនេះដែលមានមុខរបរប្រកបអាជីវកម្ម ក្នុងដំណែងណាមួយ ទោះស្រែចម្ការក្ដី ជំនួញក្ដី ចិញ្ចឹមសត្វពាហនៈក្ដី អ្នកធ្វើការរាជការក្នុងដំណែងណាមួយក្ដី ក៏ត្រូវតែស្រវាស្រទេញប្រឹងប្រែងប្រកបការងារនោះៗ មិនខ្ជិលច្រអូសបណ្ដោយឱ្យកោសជ្ជៈឈ្លីឈ្លក់ញាំញីបាន ជាមនុស្សមានឆន្ទៈពេញចិត្តក្នុងវិស័យការងារគ្រប់ជំពូក យ៉ាងនេះហៅថា **ឧដ្ឋានសម្បទា** (**ការបរិបូណ៌ដោយសេចក្ដីប្រឹងប្រែង**) ។

ពុទ្ធឱ្យវាទដែលបានចង្អុលបង្ហាញខាងលើនេះ បានគូសបញ្ជាក់ឱ្យដឹងថា ការរកស៊ីចិញ្ចឹមជីវិតរបស់មនុស្សក្នុងលោកមានតែប៉ុននេះគឺធ្វើស្រែធ្វើចម្ការធ្វើជំនួញ ធ្វើការចិញ្ចឹមគោ ធ្វើរាជការ ធ្វើជាង...។ ការងារអម្បាលនេះសុទ្ធតែកិច្ចត្រូវសម្រេចប្រយោ-ជន៍ដោយអង្គ ២គឺ សេចក្ដីប្រឹងប្រែង១ ការវាងវៃ ប៉ិនប្រសប់១ ទោះបីការណាៗ ក៏ត្រូវតែប្រកបដោយអង្គ២ ប្រការនោះៗទើបបានសម្រេច គឺមុនដំបូងត្រូវតស៊ូព្យាយាមរៀនសូត្រចំណេះវិជ្ជាទាំងពួងមាន អក្សរសាស្ត្រ លេខនព្វន្ត-គុណហារ វិជ្ជាផ្លូវលោកផ្លូវធម៌ដើម្បីបណ្ដុះនិស្ស័យបញ្ញាស្មារតីឱ្យប៉ិនប្រសប់ក្នុងការងារ ហើយខំប្រឹងប្រែងរកតទៅ បើមិនដូចនោះមិនបានសម្រេចទេ បើទុកជាសម្រេចខ្លះក៏មិនបានធំទូលំ-ទូលាយ ។

ព្រោះហេតុនេះ ទើបមានពុទ្ធភាសិតដាស់តឿនថា *"កយិរា ចេ កយិ រាថេនំ បើបុគ្គលតាំងចិត្តធ្វើការអ្វី ត្រូវតែប្រឹងប្រែងធ្វើការនោះឱ្យមែនទែន កុំបណ្តែតបណ្តោយ"* មិនត្រូវធុញទ្រាន់នឹងការងារដែលត្រូវធ្វើ កុំអាងហេតុខ្ជិល ៦យ៉ាងគឺថា ព្រឹកណាស់ ល្ងាចណាស់ ក្តៅណាស់ ត្រជាក់ណាស់ ស្រេកណាស់ ឃ្លានណាស់ ហេតុណាមួយដែលជាលេសហើយបន្ធូរបន្ថយ ឬបញ្ឈប់ការងារនោះឡើយ ។

ពុទ្ធភាសិតសម្តែងថា *"ឧដ្ឋាតា វិន្ទតេ ធនំ អ្នកព្យាយាមរមែងរកទ្រព្យបាន"*។

ពុទ្ធភាសិតនេះសមនឹងខេមរភាសិតថា : ចេះពីរៀន មានពីរក ក្រពិខ្ជិល ។

**សាធុខោ** ! អស់លោកសប្បុរសទាំងឡាយ! អាត្មាភាពសម្តែងមកអំពីឧដ្ឋានសម្បទា បរិបូណ៌ដោយការព្យាយាមស្វែងរកទ្រព្យ មកប៉ុននេះក៏ល្មមស្តាប់បាន ។

បន្ទាប់ពីនេះអាត្មាភាពសូមលើកយកមាតិកាទី២ មកសម្តែងជូនតទៅទៀត :

**២. អារក្ខសម្បទា** ដល់ព្រមដោយការរក្សានោះកាលបើបុគ្គលស្វែងរកទ្រព្យសម្បត្តិដោយកម្លាំងកាយ ប្រឹងធ្វើការងារបែកញើសហូរញើស កម្លាំងគំនិតប្រាជ្ញាស្មារតី ខំព្យាយាមរកដរាបដល់បានទ្រព្យកើតឡើងដោយសម្មាអាជីវៈហើយនោះ ត្រូវមានគំនិតបញ្ញាចេះថៃទាំរៀបចំទុកដាក់មិនបណ្តែតបណ្តោយឱ្យ ខូចខាតវិបត្តិអន្តរាយដោយការមិនគួរ ឬជាអ្នកចាយវាយខ្ជះខ្ជាយហួសប្រមាណ។ ការសម្តែងដោយសង្ខេបមកប៉ុននេះដើម្បីបំភ្លឺអស់លោកឱ្យឃើញថា "អារក្ខសម្បទា (អាបរិបូណ៌ដោយការរក្សា)" អារក្ខសម្បទានេះមាននាទីសំខាន់ ខាងការឃុំគ្រងទ្រព្យសម្បត្តិឱ្យគង់វង់នៅ។

សប្បុរសជន អ្នកមានបំនងថៃរក្សាទ្រព្យសម្បត្តិឱ្យឋិតថេរគង់វង់ត្រូវដឹងវិធីរក្សា ។ ឯវិធីរក្សានោះមាន ៤យ៉ាងគឺ ÷

**ក.**/ ចេះស្វែងរករបស់ដែលបាត់

**ខ.**/ ចេះជួសជុលរបស់ដែលគ្រាំគ្រា

**គ.**/ បរិភោគល្មមប្រមាណ

**ឃ.**/ មិនតាំងស្ត្រី ឬបុរសទ្រុស្តសីលជាធំ ។

ធម្មតាទ្រព្យសម្បត្តិដែលគង់វង់នៅ ឬចម្រើនកើតបាន ក៏ដោយសារតែម្ចាស់ទ្រព្យចេះរក្សា ចេះចាយវាយប្រើប្រាស់ ។

ឯការរក្សានោះគប្បីកំណត់ដឹងដូចនេះគឺ : ចេះទុកដាក់ ចេះថ្នម ចេះជួសជុល

ថែមបំពេញ ចេះស្តាយ ចេះធ្វើឱ្យមានផលទៅមុខ ។

ត្រង់ពាក្យថា "**ចេះទុកដាក់**" គឺចេះទុកដាក់ដ៏មាំមួនឱ្យឃ្លាតចាកពីភ័យផ្សេងៗ មានចោរភ័យជាដើម សូមបីទុកដាក់ក្នុងផ្ទះសំបែង ក៏ត្រូវប្រយ័ត្នជានិច្ច និងទុកដាក់ឱ្យសមគួរតាមបែបរបស់ទ្រព្យ ទ្រព្យណាដែលគួរដាក់ខាងក្រៅ ក៏ដាក់ខាងក្រៅ ទ្រព្យណាដែលគួរដាក់ខាងក្នុង ក៏ដាក់ខាងក្នុង ឱ្យមានរបៀបរៀបរយល្អ កុំទុកដាក់ផ្តេសផ្តាសតាមតែបាន ។

ពាក្យថា "**ចេះថ្នម**" គឺពួករបស់ណាដែលជាគ្រឿងធ្លាប់ដាច់ដាច ឬចាស់គ្រាំគ្រា ដូចជាគ្រឿស្លៀកពាក់ជាដើម ក៏ចេះថែរក្សាឱ្យល្អ ពួករបស់ជាលោហធាតុដែលជាគ្រឿងធ្លាប់មានស្នឹមច្រេះចាប់ ដូចគ្រឿងដែកឬស្ពាន់ជាដើម ដែលមិនទាន់ប្រើ ក៏ចេះទុកដាក់បិទបាំងមិនឱ្យនៅហាលថ្ងៃ ហាលភ្លៀង បើកំពុងប្រើ ក៏ចេះដុសខាត់ឱ្យស្អាតជានិច្ច ពួករបស់ដែលជាគ្រឿងស្រួយដូចពែង ប៉ាន់ កែវជាដើម ពេលត្រូវការចាប់កាន់ ក៏ចាប់កាន់ដោយថ្មិតថ្នមប្រយ័ត្នមិនឱ្យរបូតធ្លាក់ប៉ះទង្គិច និងជូតសម្អាតឱ្យស្អាតជានិច្ច ។

ពាក្យថា "**ជួសជុលថែបំពេញ**" គឺផ្ទះសម្បែង ឬវត្ថុក្នុងផ្ទះ ក្រៅផ្ទះដែលទ្រុឌទ្រោម ក៏ជួសជុលឱ្យល្អឡើង គ្រឿងចក្រ គ្រឿងម៉ាស៊ីនជាដើម ដូចជានាឡិកាដែលខូចត្រូវធ្វើឱ្យល្អឡើងវិញ ឬជួលជាងឱ្យធ្វើ ។

ពាក្យថា "**ចេះស្តាប់**" គឺរបស់ដែលមិនទាន់ខូច មិនគួរបណ្តោយឱ្យខូច ដែលខូចហើយតែនៅគួរប្រើបាន មិនគួរបោះបង់ចាល់តែកុំគម្បីស្តាយជ្រុលពេក ដរាបដល់មិនហ៊ានស៊ីចាយឆ្ងាញ់ប្រើប្រាស់ល្អនោះឡើយគប្បីស៊ីចាយប្រើប្រាស់ឱ្យសមតាមកម្លាំងទ្រព្យ មិនជាអ្នកស្វិតស្វាយចាំពេក ។

ត្រង់ពាក្យថា "**ចេះធ្វើឱ្យមានផលតទៅ**" ដូចជាមានស្រែចម្ការបានធ្វើដោយខ្លួនឯង ឬជួលឱ្យគេធ្វើ មានប្រាក់កាសបានយកមកចេញចាយធ្វើជាដើមទុនក្នុងការរកស៊ីទាំងពួង មានជំនួញជាដើមឱ្យប្រាក់កាសមានការចម្រើនលូតលាស់ទៅមុខទៀត មិនត្រូវទុកប្រាក់ឱ្យងាប់នៅមួយកន្លែងឡើយ **សាធុរោ** ! អស់លោកសប្បុរសទាំងឡាយ! ការចេះរក្សាទ្រព្យដូចអាត្មាបានសម្តែងមកខាងលើនេះ ហៅថា "**អារក្ខសម្បទា**" ប្រែថា ការដល់ព្រមដោយការរក្សា ។ អារក្ខសម្បទានេះ ជាធម៌មានអានុភាពដ៏សំខាន់ខាង

ការរក្សាឃុំគ្រងទ្រព្យសម្បត្តិ ដែលកើតពីឧដ្ឋានសម្បទា (ការប្រឹងប្រែងព្យាយាមរកបានមកហើយនោះ) ឱ្យគង់នៅយឺនយូរ និងឱ្យមានកម្រៃចម្រើនទៅ ។

៣. **កល្យាណមិត្តតា** ការគាប់មិត្តសម្លាញ់ល្អនោះបានដល់ការសេពគប់ចំពោះសប្បុរសជន ទោះបីមិត្តនោះ មានបណ្ដាស័ក្តិក្តី ឥតក្តី មានក្តីក្រក្តី ចាស់ក្តី ក្មេងក្តី មិនត្រូវប្រកាន់វណ្ណៈឱ្យតែជននោះមានកិរិយាមារយាទសណ្ដាប់ធ្នាប់ ឬកពារថ្លៃថ្នូរ មានសុជីវធម៌ មនុស្សធម៌ សុភាពរាបសារទន់ភ្លន់ មានសទ្ធា សីលៈ ចាគៈ បញ្ញា នៅក្នុងខ្លួន ក៏យើងគួរសេពគប់រាប់រកយកធ្វើជាមិត្ត បើខ្លួនពុំទាន់បរិបូណ៌ដោយចំណេះវិជ្ជាទេគប្បីសាកសួរគតិផ្លូវលោកផ្លូវធម៌អំពីកល្យាណមិត្តនោះ ខ្លួនយើងក៏អាចក្លាយទៅជាមនុស្សមានចំណេះវិជ្ជាបរិបូណ៌ មានសទ្ធា សីលៈ ចាគៈ បញ្ញា តាមកល្យាណមិត្តនោះដែរ យ៉ាងនេះហៅថា "**កល្យាណមិត្តតា**" (សភាពជាបុគ្គលមានមិត្តសម្លាញ់ល្អ) ការគប់មិត្តល្អរមែងមានអានិសង្សឱ្យកើតត្រៃពិធសម្បត្តិ គឺសម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ។ ផ្ទុយទៅវិញបើយើងសេពគប់ជនពាលនោះ រមែងជួបប្រទះទុក្ខទោស គ្រោះថ្នាក់វិនាសទ្រព្យសម្បត្តិពុំខាន និងនាំឱ្យប្រព្រឹត្តអបាយមុខ ៤ យ៉ាងគឺ : ជាអ្នកលេងស្រី សេពសុរា លេងល្បែងស៊ីសង និងសេពគប់បាបមិត្ត ។ ការប្រព្រឹត្តអបាយមុខទាំង ៤ យ៉ាងនេះ ទ្រព្យសម្បត្តិណាដែលមិនទាន់កើត ក៏មិនកើតឡើង ដែលកើតឡើងហើយ ក៏វិនាសអន្តរាយទៅវិញ ។

កុំចាំបាច់ពោលទៅថ្វី ទ្រព្យសម្បត្តិបន្តិចបន្តួច សូម្បីច្រើនរាប់រយលានក៏គ្មានសល់ លោកប្រៀបដូចបឹងណាដែលមានផ្លូវបង្ហូរទឹកចូលតែមួយមានផ្លូវបង្ហូរចេញច្រើន បឹងនោះរមែងរីងស្ងួតហួតហែងទៅដោយឆាប់រហ័ស ដរាបដល់អស់រលីងឥតមានសេសសល់ ត្រង់នេះគួរនឹងឃើញដល់មនុស្សដែលចេះតែចាយមិនចេះរក ។

**ដូចមាននិទានថា :**

មានសេដ្ឋីបុត្តម្នាក់បានទទួលកេរ្តិ៍មត៌កពីមាតាបិតា ចំនួន៨០កោដិ ខាងប្រពន្ធ ៨០កោដិ រួមជា ១៦០កោដិ តែសេដ្ឋីបុត្តនោះជាមនុស្សខ្ជះខ្ជាយចាយវាយឥតគិត រកតែស្រីរបាំមកបម្រើខ្លួន ឱ្យរង្វាន់ម្នាក់ៗច្រើនៗដល់ទីបំផុតក៏អស់ទ្រព្យ ត្រលប់ជាអ្នកដើរសុំទានគេ។ ថ្ងៃមួយព្រះសាស្ដាទតឃើញសេដ្ឋីបុត្តទាំងប្តីប្រពន្ធ កំពុងឈរក្បែរទ្វារសាលាចាំទទួលទានអាហារសំណល់ដែលភិក្ខុសាមណេរឱ្យទានក៏ទ្រង់ត្រាស់នឹង

អាននូវដោយព្រះគាថា ថា :

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណាមច្ឆេវ បល្លលេ ។**

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ សេន្តិ ចាបាតិ ខីណាវ បុរាណានិ អនុត្ថុនន្តំ ។**

ពួកមនុស្សពាលដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានខំរកទ្រព្យក្នុងវេលាខ្លួននៅជាកំលោះក្រមុំ រមែងក្រៀមក្រំដូចក្រៀលចាស់ក្រៀមក្រំលើភក់ដែលអស់ត្រី ពួកមនុស្សដែលមិនប្រព្រឹត្តព្រហ្មចរិយធម៌មិនបាន ខំរកទ្រព្យក្នុងវេលាខ្លួននៅជាកំលោះក្រមុំ រមែងដេកដកដង្ហើមធំស្ដាយទ្រព្យចាស់ដែលអស់ទៅ ដូចព្រួញដែលគេបាញ់ទៅចាកបំពង់ ។

**សាធុរោ!** អស់លោកសប្បុរសទាំងឡាយ ! ការសេពគប់បាបជនពាលមានតែនាំយើងឱ្យទៅកាន់ទីមហន្តរាយ សប្បាយខុសលុះក្នុងទីទុក្ខវិនាសអន្តរាយទ្រព្យសម្បត្តិប៉ុណ្ណោះដល់អវសាន មានតែវិប្បដិសារីក្រៀមក្រំក្ដៅក្រហាយស្ដាយក្រោយជាផល ។

ដូចសេចក្ដីបុត្តប្ដីប្រពន្ធដែលបានសម្ដែងខាងលើនេះឯង ។

**ដូចមានបុរាណសុភាសិតសម្ដែងថា :**

គប់ប្រាជ្ញនាំប្រាណឱ្យបានសុខ គប់ពាលនាំស្អុកចិត្តមួហ្មង

គប់ប្រាជ្ញនាំឃ្លាតចាកបាបផង គប់ពាលសៅហ្មងជាប្រក្រតី ។

**៤. សមជីវិតា** ការចិញ្ចឹមជីវិតស្មើគឺការចិញ្ចឹមជីវិតសមគួរតាមកម្លាំងទ្រព្យដែលមាន មិនចាយខ្ជះខ្ជាយពេក រិតត្បិតពេក។ ជាអ្នកប៉ិនប្រសប់ក្នុងការប្រកបអាជីវកម្ម ស្គាល់ប្រមាណនូវហេតុដែលនាំឱ្យចម្រើន និងវិនាសហើយសម្រេចចិត្តចិញ្ចឹមជីវិតតាមលម្មសមគួរ មិនចាយវាយឱ្យជ្រុលដៃហួសប្រមាណ រហូតដល់ខ្វះមុខខ្វះក្រោយ ឬជំពាក់បំនុលគេច្រើនពេក បើវរជនណារកស៊ីមិនចម្រើនហើយចាយច្រើនលោកប្រៀបដូចជាអ្នកចង់បរិភោគផ្លែឈើទាំងឡាយ មានផ្លែត្របែកជាដើម តែមួយផ្អែត ហើយកាប់ទាំងមែកយ៉ាងធំបេះយកផ្លែមកបរិភោគតែមួយផ្អែក នៅសល់ប៉ុន្មានគ្រវាត់ចោលអស់ទៅ ខូចប្រយោជន៍ខាងមុខទទេ ។

ចំណែកវរជនដែលចេះបែងទ្រព្យសម្បត្តិ ចាយវាយតាមសមត្ថភាពខ្លួនរមែងបោះជំហានឈានទៅមុខរកសេចក្តីចម្រើនជាលំដាប់។ លោកប្រៀបដូចជាបឹងដ៏ធំហើយមានផ្លូវហូរចេញតែមួយ ទឹកនោះកម្រនឹងរីងស្ងួតយ៉ាងណា? បុគ្គលអ្នកមានទ្រព្យដែលចេះបែងចាយវាយប្រើប្រាស់ក៏កម្រអស់ដូចនោះដែរ។

**សមជីវិតា** ការចិញ្ចឹមជីវិតស្មើនេះ ស៊ីសេចក្តីដល់ការរសនៅស្មើៗ គឺសភាពមនុស្សមិនចេះប្រកាន់វណ្ណៈ មិនអាងយសស័ក្តិ ទ្រព្យសម្បត្តិ ជាតិត្រកូល។ល។ សម្រាប់យកទៅប្រើអំណាចជិះជាន់ដល់ជនអ្នកមានជីវភាពទន់ខ្សោយនោះឡើយ។

យ៉ាងនេះហៅថា "**សមជីវិតា**" (សភាពជាមនុស្សមានការចិញ្ចឹមជីវិតស្មើ ឬការរស់នៅស្មើៗ) ។

ទ្រឹស្តីសាសនាបានចង្អុលបង្ហាញអំពីការចាយទ្រព្យមាន ២ន័យ : ន័យ១ ឱ្យបែងចែកប្រាក់កាសជា ៤ភាគ ទុកសម្រាប់បរិភោគ ១ភាគ ចំណាយដើមទុនប្រកបការរកស៊ី ២ភាគ ទុកឱ្យនៅទំនេរសម្រាប់ការពារអន្តរាយ១ភាគ រួមជា ៤ភាគ ។

ន័យមួយទៀតឱ្យបែងចែកប្រាក់កាសជា ៤ផ្នែកដែរ តែក្នុងភាគមួយៗស្មើគ្នាមិនឱ្យច្រើនម្ខាងៗ ហើយក្នុងភាគទាំង ៤នោះឱ្យមានផលប្រយោជន៍ទាំងជាតិនេះនិងជាតិខាងមុខគឺ :

**១- ដោះបំណុលចាស់**

**២- បុលបំណុលថ្មី**

**៣- បោះទៅក្នុងជ្រោះជ្រៅ**

**៤- កប់ទុកជាកំណប់ព្រេង ។**

១. ត្រង់ពាក្យថា "**ចាយទ្រព្យ១ភាគដោះបំណុលចាស់**" ចាយទ្រព្យសងគុណមាតាបិតា ព្រោះមាតាបិតាជាដើមបំណុល ធីតាជាកូនបំណុល មាតាបិតាដែលបានបង្កើតខ្លួនប្រាណឱ្យមានជីវិត មានសាច់ឈាមជាដើមនោះ បានឈ្មោះថាបុលខ្លួនប្រាណ បុលសាច់ឈាមឱ្យកូន ឬដែលម្តាយបំបៅដោះកូនទំពារបាយបញ្ចុកកូន ឪខំរកប្រាក់ចិញ្ចឹមកូនក៏បានឈ្មោះថា បុលទឹកខ្សិរ (ទឹកដោះ) បុលបាយទំពារ និងបុលទ្រព្យសម្បត្តិឱ្យកូន ចំណែកខាងកូនក៏ឈ្មោះថា ជាកូនបំណុលទឹកខ្សិរ សាច់ឈាមកម្លាំងពលំ ប្រាជ្ញាស្មារតី ទ្រព្យសម្បត្តិរបស់ឪពុកម្តាយ ។ ព្រោះហេតុនោះកូនប្រុស

ស្រី ដែលជាអ្នកជំពាក់បំណុល ម្ដាយឪពុកដូចបានពោលមកហើយ មិនត្រូវបំភ្លេចគុណលោកទេត្រូវតែសងបំណុលលោកវិញ ទើបបានឈ្មោះថា ជាមនុស្សកតញ្ញូកតវេទិតា ទោះបីខ្លួនប្រកបអាជីវកម្មបានទ្រព្យសម្បត្តិតិចក្ដី ច្រើនក្ដី ក៏ត្រូវតែបែងប្រាក់កាសមួយចំណែកយកទៅទិញវត្ថុផ្សេងៗ មានគ្រឿងស្លៀកពាក់ អាហារ ភោជន គ្រឿងដេក អង្គុយ ថ្នាំកែរោគជូនម្ដាយឪពុក ឬជូនប្រាក់កាសដល់គាត់តាមត្រូវការ ដើម្បីចិញ្ចឹមម្ដាយឪពុកឱ្យសុខស្រួលកុំឱ្យលំបាកលំបិនក្នុងការរស់នៅ ។

ការដែលកូនប្រុសស្រី ចាយទ្រព្យមួយភាគសងគុណម្ដាយឪពុក ដូចបានសម្ដែងមកហើយនេះ ឈ្មោះថា ចាយទ្រព្យដោះបំណុលចាស់

២. ពាក្យថា "ចាយទ្រព្យ១ភាគបុលយកបំណុលថ្មី" នោះកាលបើជនជាម្ដាយឪពុក ខំរកទ្រព្យសម្បត្តិបានមកទោះបីតិចក្ដីច្រើនក្ដី ត្រូវយក១ចំណែកចាយចិញ្ចឹមកូនប្រុសស្រី តាំងពីតូចរហូតដល់ធំឱ្យសមតាមកាលៈទេសៈ និងសម័យនិយម ពីតូចត្រូវចិញ្ចឹមដោយគ្រឿងស្លៀកពាក់ និងអាហារភោជន ដល់ធំឡើងបន្តិចមានអាយុប្រហែ-ល ១៥ឬ ១៦ឆ្នាំជាវ័យល្មមសិក្សារៀនសូត្រ មាតាបិតាត្រូវបែងទ្រព្យមួយចំណែកទិញគ្រឿងសិក្ខូបករណ៍-ប្រដាប់សម្រាប់រៀនសូត្រឱ្យ បញ្ជូនទៅសាលារៀន ដើម្បីបណ្ដុះនិស្ស័យសតិបញ្ញាស្មារតីខាងចំណេះវិជ្ជាតាមសម័យនិយម ។

លុះដល់មានវ័យចម្រើនល្មមមានគូស្រករ ក៏ចាត់ចែងរៀនចំឱ្យមានគុស្វាមីភរិយា ហើយចែកកេរ្តិ៍មរតកតាមកម្លាំងដែលមាន ឱ្យជាដើមទុនសម្រាប់រកស៊ីជាដើម កាលបើម្ដាយឪពុកទំនុកបម្រុងកូនបែបនេះ រមែងបានផលយ៉ាងល្អ គឺបានទទួលការតបគុណអំពីកូនវិញ យ៉ាងនេះហៅថា ចាយទ្រព្យបុលយកបំណុលថ្មី ។

៣. ត្រង់ពាក្យថា "យកទ្រព្យមួយភាគទៅបោះក្នុងជ្រោះជ្រៅ" នោះគឺចាយចិញ្ចឹមជីវិតខ្លួនឯង ៥ផ្លូវ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាយ កាយដោយប្រការផ្សេងៗ។ ភ្នែក ច្រមុះ ត្រចៀក អណ្ដាត កាយ ទាំង ៥នេះលោកទុកដូចជាជ្រោះ ឬរណ្ដៅ ព្រោះជារបស់ជ្រៅ កម្រនឹងបំពេញឱ្យពេញដោយសំឡេង ក្លិន រស សម្ផស្សបាន ការចាយវាយជាគ្រឿងសប្បាយក្នុងផ្លូវភ្នែក ត្រចៀក អណ្ដាត កាយយ៉ាងនេះ ហៅថាបោះក្នុងជ្រោះជ្រៅ ឯភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយនេះ បានជាហៅជ្រោះជ្រៅ ព្រោះភ្នែកមិនចេះឆ្អែតនឹងរូប ត្រចៀកមិនចេះឆ្អែតនឹងសំឡេង ច្រមុះមិនចេះឆ្អែតនឹងក្លិន

អណ្តាតមិនចេះឆ្អែតនឹងរស កាយមិនចេះឆ្អែតនឹងសម្ផស្ស បើពោលចំពោះអណ្តាត អណ្តាតនេះតែបរិភោគហើយមិនគង់នៅយូរប៉ុន្មានទេ សេចក្តីនេះសមដូចពោលទុកក្នុងកាយវិរតិកថា ថា "**ឥតោ បវិដ្ឋមេតស្មិ ឯត្តោ យាតិទ បូតិកំ** អាហារនោះដាក់ចូលទៅតាមផ្លូវនេះ ក៏ស្អុយរលួយហើយចេញទៅតាមផ្លូវនោះ" ដល់ទីបំផុតរាងកាយដែលខំប្រឹងបំប៉នដោយអាហារមកអស់កាលយូរ ក៏ដេកសង្កត់លើផែនដី មិនមានវិញ្ញាណដូចអង្កត់អុសឥតប្រយោជន៍។

៤. ត្រង់ពាក្យថា "យកទ្រព្យមួយចំណែកទៅកប់ទុកជាកំណប់ព្រេង" នោះគឺចាយធ្វើបុណ្យសន្ទូវទាន ដូចជាបរិច្ចាគបច្ច័យ ៤គឺចីវរ បិណ្ឌបាត្រ សេនាសនៈ គិលានៈភេសជ្ជៈ ចិញ្ចឹមសមណព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ព្រមទាំងប្រកបការដទៃៗទៀតដែលជាការទំនុកបម្រុងដល់មនុស្សជាតិឱ្យមានសេចក្តីចម្រើនតាមអារ្យធម៌ ឬទំនុកបម្រុងព្រះពុទ្ធសាសនារហូតដល់ការកសាងអាគារសិក្សាផ្លូវលោកផ្លូវធម៌ ទីកន្លែងសម្រាប់បណ្តុះសតិបញ្ញាជាសាធារណៈប្រយោជន៍ ឱ្យសមតាមកម្លាំងធនធានដែលអាចធ្វើបាន ដូចនេះជាដើម ហៅថា ធ្វើបុណ្យ។ **សាធុវោ** ! អស់លោកសប្បុរសជនទាំងឡាយ! បុណ្យនេះ បើនរជនណាបានធ្វើហើយជាកំណប់ទ្រព្យដ៏ប្រសើរជាទីបំផុត។

ដូចមានពុទ្ធដីកាក្នុងនិធិកណ្ឌសូត្រថា :

**ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ ។**

កំណប់ទ្រព្យ គឺបុណ្យនោះ ដែលបុគ្គលកប់ទុកល្អហើយមិនមាននរណាផ្ចាញ់បាន និងជាប់តាមនៅកាលបុគ្គលលះបង់ភោគសម្បត្តិទាំងឡាយ គឺពេលដែលខ្លួនស្លាប់ទៅហើយ រមែងនាំយកកំណប់នោះទៅបាន ។

ព្រោះហេតុនេះ បានជាលោកពោលថា ការដែលបុគ្គលយកទ្រព្យ១ ចំណែកទៅចាយធ្វើបុណ្យនោះបានឈ្មោះថា យកទៅកប់ទុកជាកំណប់ព្រេង ។

ការចែកចាយទ្រព្យសម្បត្តិជា ៤ចំណែក ដូចដែលអាត្មាភាពបានសម្តែងមកនេះហៅថា "**សមជីវិតា ការចិញ្ចឹមជីវិតស្មើ**" ពាក្យថា ស្មើក្នុងទីនេះ សំដៅយកស្មើភាគគ្នា ដូចមានហិរញ្ញវត្ថុចំនួន ១០០ត្រូវបែងទុកជា៤ភាគ ភាគមួយៗ ២៥រួមជា១០០

ភាគ ទី១សម្រាប់ដោះបំណុលចាស់ គឺសងគុណមាតាបិតាភាគទី២ សម្រាប់បុលបំណុលថ្មី គឺចិញ្ចឹមបុត្រធីតា ភាគទី៣សម្រាប់បោះក្នុងជ្រោះជ្រៅ គឺបរិភោគខ្លួនឯង ភាគទី៤សម្រាប់កប់ទុកជាកំណប់ព្រេង ពោលគឺការធ្វើបុណ្យ ទោះបីមានចំនួនតិច ឬច្រើនៗ នោះក៏គប្បីបែងចំណែកជា ៤តាមទំនងដូចបានសម្តែងមកនេះ ទើបហៅថា ចិញ្ចឹមជីវិតសមតាមកម្លាំងទ្រព្យ ចិញ្ចឹមជីវិតស្មើ ។

និទានមានដំណាលប្រារព្ធរឿងចាយទ្រព្យថា : ក្នុងកាលកន្លងយូរទៅហើយ មានបុរសកម្សត់ម្នាក់ជាមនុស្សចេះលៃលកចាយទ្រព្យត្រូវតាមកម្លាំងទ្រព្យ។ កាលដែលបិតាធ្វើមរណកាលទៅ បុរសនោះចិញ្ចឹមមាតាចាស់ ព្រមទាំងប្រពន្ធកូនដោយរបររកាប់អុសលក់ ។

វេលាមួយបុរសនោះបររទេះគោចូលទៅរកអុសក្នុងព្រៃ បានអុសផ្ទុកពេញរទេះហើយ ក៏រែកអុសមួយអំរែកដើរពីមុខរទេះត្រឡប់ទៅផ្ទះ ។

កាលបើបុរសនោះកំពុងតែរែកអុសដើរមុខរទេះដូចនោះ ព្រះរាជាទ្រង់ទតឃើញប្លែក ទ្រង់ត្រាស់ឱ្យគេហៅមកសួរថា *"អ្នកឯងម្តេចក៏ប្លែកពីគេម្ល៉េះតើយកអុសទៅធ្វើអ្វី?"* ។ បុរសនោះក្រាបបង្គំទូលថា *"យកទៅលក់បានប្រាក់មកចែកជា ៤ចំណែក គឺដោះបំណុលចាស់១ បុលបំណុលថ្មី១ បោះក្នុងជ្រោះជ្រៅ១ កប់ទុក១"*។ ព្រះរាជាទ្រង់ឆ្ងល់ ក៏ត្រាស់សួរបុរសនោះ ក្រាបបង្គំទូលថា *"ដោះបំណុលចាស់ គឺចិញ្ចឹមម្តាយ បុលបំណុលថ្មីគឺចិញ្ចឹមកូន បោះក្នុងជ្រោះជ្រៅ គឺទទួលព្រះរាជទានខ្លួនឯង កប់ទុកគឺធ្វើទាន"*។

ព្រះរាជាទ្រង់សោមនស្ស ក៏ប្រទានព្រះរាជទ្រព្យព្រមទាំងយសស័ក្តិឱ្យបានសេចក្តីសុខសប្បាយតទៅ ។

**សាធុរោ** ! អស់លោកសប្បុរសទាំងឡាយ !

អាត្មាភាពលើករឿងនេះមកសម្តែង ដើម្បីបញ្ជាក់ឱ្យឃើញបែបផែនក្នុងការចាយវាយទ្រព្យ ដែលសមតាមកម្លាំងទ្រព្យ ហើយត្រូវតាមគន្លងធម៌ ។

ការចេះលៃលកចាយវាយទ្រព្យ ដូចអាត្មាសម្តែងមកនេះ ហៅថាសមជីវិតា (សភាពជាបុគ្គលចិញ្ចឹមជីវិតស្មើ-ឬភាពជាបុគ្គលរស់នៅស្មើៗ) ។ ធម៌ទាំង៤យ៉ាងគឺ ឧដ្ឋានសម្បទា១ អារក្ខសម្បទា១ កល្យាណមិត្តតា១ សមជីវិតា១ ទាំង៤យ៉ាងនេះជា

ធម៌មានឫទ្ធានុភាព អាចញ៉ាំងមនុស្សលោកទាំងឡាយឱ្យតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ និង ជាអ្នកមានរបៀបរៀបរយល្អដែលជាផលឱ្យកើតសេចក្តីសុខកាយសប្បាយចិត្ត ឃើញច្បាស់ទាន់ភ្នែកក្នុងបច្ចុប្បន្នសមតាមសេចក្តីប្រាថ្នា ។

**សាធុរោ** ! អស់លោកសប្បុរសទាំងឡាយ !

អាត្មាភាពសម្តែងមកអំពីទិដ្ឋធម្មិកត្ថប្រយោជន៍ប្រែថា ប្រយោជន៍ទាន់ភ្នែក ឬប្រយោជន៍បច្ចុប្បន្នមកប៉ុណ្ណោះនេះ ក៏ល្មមសមកាលវេលានឹងបញ្ចប់ធម៌ទេសនា តែមុននឹងបញ្ចប់អាត្មាភាពសូមលើកយកកុសលទាំងអស់នេះជា ព្រះរាជកុសលវិសេសថ្វាយចំពោះសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃប្រជាពលរដ្ឋខ្មែរ ព្រមទាំងសម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ-មុនីវង្ស កុសុមៈនារីរតន៍ សិរីវឌ្ឍនា ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក និងជាជីវិតនៃប្រជាពលរដ្ឋខ្មែរទាំងព្រះរាជាណាចក្រ សូមសម្តេចទាំងពីរព្រះអង្គទ្រង់ប្រកបដោយព្រះបរមសុខ ក្នុងព្រះសិរីរាជសម្បត្តិ មានព្រះជន្មវស្សាទីឃាយុយឺនយូរដរាបដល់រយព្រះវស្សា សត្រូវគ្រប់ទិសទីបាក់បបខ្លបខ្លាចចេស្តាបារមីនៃព្រះអង្គ ព្រមទាំងព្រះរាជវង្សានុវង្ស-មន្ត្រីរាជការគ្រប់ជំណែង ក៏សូមឱ្យបានទទួលនូវចំណែកនៃកុសលនេះដែរ ហើយសូមឱ្យបានប្រកបតែសេចក្តីសុខចម្រើនតទៅ ។

ជាពិសេស ! ចំពោះបុព្វការីជនរបស់អស់លោកទាំងឡាយដែលទម្លុះកាយទម្លាយខន្ធទៅកាន់បរលោក ព្រមទាំងអស់លោកសប្បុរសដែលរស់នៅសព្វថ្ងៃ ក៏សូមឱ្យបានចំណែកផលស្មើៗគ្នា ហើយសូមឱ្យបានសម្រេចនូវសម្បត្តិទាំង ៣ប្រការគឺ សម្បត្តិសមុស្ស១ សម្បត្តិទេព្ដា១ សម្បត្តិព្រះនិព្វាន១ តាមសមគួរដល់សេចក្តីប្រាថ្នា។

**អយំ សង្ខេបេន សម្មត្តា** ធម៌ទេសនាដែលបានសម្តែងមកនេះក៏សន្មតថាចប់ដោយសង្ខេប **ឯវំ** ។

★ ★ ★

# បញ្ហាធម៌

ពរទាំងឡាយ ៤ ប្រការគឺ :

**អាយុ** សូមឱ្យមានអាយុវែងយឺនយូរ១

**វណ្ណៈ** សូមឱ្យមានពណ៌សម្បុរកាយ និងសម្បុរស្រស់

**សុខ:** សូមឱ្យសុខកាយសប្បាយចិត្ត១

**ពល:** សូមឱ្យមានកម្លាំងកាយ និងកម្លាំងសទ្ធា-ប្រាជ្ញា១ ។

ពរទាំងបួនប្រការនេះ វឌ្ឍន្តុ ចូរចម្រើនកើមានដល់អស់លោកពុទ្ធបរិសទ្យទាំងឡាយ (មានលោកជាសាមីម្ចាស់បុណ្យជាដើម) ដែលបានអញ្ជើញមកប្រជុំសន្និបាតក្នុងទីនេះ ដើម្បីក្រេបជញ្ជក់នូវអត្ថរសនៃធម៌ទេសនាជាគ្រឿងប្រដាប់សតិបញ្ញាស្មារតីរៀងៗខ្លួន ពេលនេះអាត្មាភាពមាននាទីជាអ្នកសម្តែងធម៌ទេសនា ទុកដូចជាការសម្តែងតបស្នង ឬបំពេញសទ្ធា (សេចក្តីជ្រះថ្លា) នៃពុទ្ធបរិស័ទ្យទាំងឡាយ បើជូនជាអាត្មាសម្តែងទៅហើយក្រែងមានភ្លាំងភ្លាត់មិនរាបសារខុសបំណងអធ្យាស្រ័យនៃ អស់លោកអ្នកស្តាប់ទាំងឡាយនោះ សូមខន្តីអភ័យទោសដល់អាត្មាភាព អាត្មាភាពនឹងសម្តែងទៅតាមហេតុផល និងតាមកាលវេលាក្នុងពេលឥឡូវនេះសូមចម្រើនពរ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ដង) ខ្ញុំព្រះករុណា សូមនមស្សការចំពោះព្រះអរហន្តមុនី សម្មាសម្ពុទ្ធដ៏មានព្រះភាគអង្គនោះ (ព្រមទាំងព្រះសទ្ធម្ម និងព្រះអរិយសង្ឃ) ដោយសេចក្តីគោរព។

បន្ទាប់ពីបទនមស្សការនេះទៅ អាត្មាភាពសូមលើកយកបញ្ហាធម៌មកសម្តែងដូចតទៅនេះ ÷

ដោយបុព្វាចារ្យបានចងក្រងជាពាក្យឃ្លោងទុកមកថា ÷

**"ឱ្យកាប់ព្រៃ៣ រក្សាព្រៃ១០ ធឹកថ្នាំ៥កញ្ចប់ តមត្រណម២"** ។

ពាក្យនេះជាបញ្ហាធម៌សុទ្ធៗ លោកបានចងជាឃ្លោងដើម្បីឱ្យកុលបុត្រសិក្សាងាយចាំ ហើយក្រភ្លេចទៅវិញផង ។

ពាក្យថា ឱ្យកាប់ព្រៃ៣ ព្រៃ៣ក្នុងទីនេះ លោកសំដៅយកអកុសលមូល៣យ៉ាង

គឺ : **លោភៈ ទោសៈ មោហៈ** ដែលជាឫសគល់នៃអកុសលធម៌ទាំងពួង ព្រោះកិលេសតណ្ហាតូចក្តី ធំក្តី កណ្តាលក្តី សុទ្ធតែបណ្តោយចេញមកអំពីធម៌នេះឯង ទើបលោកហៅថាព្រៃស្នាប់ **លោភៈ** ល្មោភ ឬជាប់ជំពាក់ក្នុងអារម្មណ៍១ **ទោសៈ** សំដៅដល់ការថ្នាំងថ្នាក់ចំពោះអារម្មណ៍ ហើយប្រទូស្តរ៉ាយខឹងក្រោធច្រឡោតតូងតាង១ **មោហៈ** សេចក្តីវង្វេងវង្វាន់កាន់ច្រឡំល្ងង់ខ្លៅ មិនស្គាល់ខុសត្រូវ មិនដឹងហេតុផល១ ទាំងបីប្រការនេះលោកហៅថា "**ព្រៃស្នាប់**" ព្រោះបុគ្គលដែលធ្វើអំពើអាក្រក់គ្រប់ប្រការ ក៏មកអំពី **លោភៈ ទោសៈ មោហៈ** នេះឯង ឬ **លោភៈ ទោសៈ មោហៈ** ទាំងបីនេះជាពូជសម្រាប់សាបព្រួសបណ្តុះកំណើតឱ្យកើតបាបផ្សេងៗ គ្រប់ផ្លូវ ដូចរុក្ខជាតិនានាដែលលូតលាស់ដុះឡើងជាមែកធាង ផ្លែផ្កា ព្រោះតែមានឫសគល់ដូចនោះ។ មនុស្សលោកភាគខ្លះប្រព្រឹត្តធ្វើអំពើទុច្ចរិត ដោយអំណាចលោភៈ ខ្លះប្រព្រឹត្តធ្វើអំពើទុច្ចរិតដោយអំណាចទោសៈ ខ្លះប្រព្រឹត្តទុច្ចរិតដោយអំណាចមោហៈ ដូចជាការសម្លាប់សត្វ បុគ្គលខ្លះសម្លាប់ដោយអំណាច់លោភៈ ព្រោះចង់បានសាច់របស់សត្វដែលខ្លួនសម្លាប់នោះមកស៊ី ឬចំណាយលក់ដូរយកផលប្រយោជន៍ ខ្លះដោយអំណាចទោសៈ គឺការក្រោធខឹងមួរម៉ៅ ខ្លះសម្លាប់ដោយអំណាចមោហៈ គឺសម្លាប់លេងឱ្យសប្បាយ រីករាយចិត្តដោយគ្មានឧតម្តគតិពិចារណាថា គេចង់រស់ ចង់សប្បាយដូចខ្លួនដែរនោះទេ ។

**សាធុរ៉ោ** ! អស់លោកសប្បុរសទាំងឡាយ ! មនុស្សលោកទាំងអស់ដែលសម្លាប់សត្វ រមែងសម្លាប់ដោយហេតុទាំង ៣យ៉ាងនេះឯង ។

ចំណែកអំពើទុច្ចរិតដទៃក្រៅពីសម្លាប់សត្វ ទោះបីសេចក្តីលាមកអាក្រក់ណាមួយក៏ដោយ ដែលមនុស្សយើងប្រព្រឹត្តធ្វើសព្វថ្ងៃនេះ រមែងមិនផុតពីអកុសលមូលទាំង៣ ប្រការដែលហៅថា ព្រៃស្នាប់នោះឡើយ គឺសុទ្ធតែនៅក្នុងអំណាចនៃព្រៃស្នាប់ទាំង ៣នេះឯង ។

ការបើព្រៃស្នាប់ទាំង ៣នេះ ណាមួយមានហើយអកុសលដទៃដែលមិនទាន់កើត ក៏កើតឡើង ដែលកើតស្រាប់ហើយក៏ចម្រើនឡើង ។

តាមពិត ! បុគ្គលដែលមិនធ្លាប់ធ្វើអំពើអាក្រក់ណាមួយ ប្រសិនបើជាអកុសលទាំង ៣នេះ មួយណាកើតឡើងហើយ រមែងប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ដែលធ្លាប់ធ្វើនោះបានទាំងអស់ ហើយបើសិនជាធ្លាប់ធ្វើពីដើមមកផងនោះមិនបាច់និយាយ

ឡើយរឹតតែច្រើនឡើងថែមទៀត ។

ហេតុនេះបានជាលោកឱ្យសប្បុរសជនទាំងឡាយ ព្យាយាមកាប់គាស់នូវព្រៃស្អាប់គឺ :

**លោភៈ** នេះបាន ដោយការធ្វើទាន

**ទោសៈ** នេះបាន ដោយការរក្សាសីល

**មោហៈ** នេះបាន ដោយការចម្រើនភាវនា ។

**សាធុរ៉ោ** ! អស់លោកសប្បុរសទាំងឡាយ ! អាត្មាភាពសម្តែងមកប៉ុននេះ ដើម្បីនឹងដោះស្រាយនូវបញ្ហាទី១ ដែលថា "ឱ្យកាប់ព្រៃ ៣ គឺអកុសលទាំង ៣ខាងលើនេះលោកហៅថា "ព្រៃស្អាប់" ។ បញ្ហាទី២ ដែលលោកហៅថា "ឱ្យរក្សាព្រៃ១០" នោះ ចុះព្រៃ១០ ប្រការនេះ ហេតុអ្វីបានជាលោកឱ្យរក្សា? ព្រៃនេះមានប្រយោជន៍ដូចម្តេចខ្លះ?

**សាធុរ៉ោ** ! អស់លោកសប្បុរសទាំងឡាយ ! ព្រៃ១០ ប្រការក្នុងទីនេះលោកសំដៅយក "កុសលកម្ម១០ ប្រការ" គឺ : កាយសុចរិត៣ វចីសុចរិត៤ មនោសុចរិត៣ ព្រោះព្រៃទាំងនេះមានទេសភាពដ៏ល្អមានបរិយាកាសដ៏ត្រជាក់ជាទីរមណីដ្ឋាន គួរឱ្យរីករាយសប្បាយ មែនជាព្រៃមានសុគន្ធជាតិក្រអូបឈ្ងុយឈ្ងុបជ្រួតជ្រាបត្រជាក់បេះដូង។

ជាពិសេស! បើបុគ្គលណាបានចូលទៅហើយ បុគ្គលនោះឯងតែងប្រកបដោយកាយវិការដ៏ប្រពៃ គឺមានចរិយាសណ្តាប់ធ្នាប់សុភាពរាបសា សមរម្យល្អមិនច្រងេងច្រងាងដោយឥរិយាបថទាំង៤គឺ : ដេក ដើរ ឈរ អង្គុយ ។

ឯវាចាសោតទៀតក៏ពោលតែបិយវាចាៗ ដែលមានប្រយោជន៍វាចាផ្អែមល្ហែមទន់ភ្លន់ មិនពោលបញ្ឆិតបញ្ឆៀង ទិទៀននិន្ទាដល់អ្នកដទៃឱ្យគេរង្កៀសមន្ទិលសៅហ្មងចិត្ត។ ឯចិត្ត! ទោះបីគិតអ្វី ក៏គិតតែអំពើល្អ ផ្លូវល្អមិនគិតបៀតបៀនដល់សត្វនិងសង្ខារទាំងពួងឡើយ ។ ព្រោះមានគុណសម្បត្តិឫទ្ធានុភាពដូចបានពោលមកនេះបានជាលោកត្រូវឱ្យរក្សា ។

បណ្តាព្រៃទាំង១០គឺ "**កាយសុចរិត៣ វចីសុចរិត៤ មនោសុចរិត៣**" អាត្មាភាពសូមលើកយកម្តងមួយៗមកអធិប្បាយដោយសង្ខេបដូចតទៅនេះ :

# អធិប្បាយ

សុចរិតគឺការប្រព្រឹត្តល្អដែលផុសចេញអំពីកាយហៅថាកាយសុចរិតមាន ៣ ប្រការគឺ **បាណាតិបាតា វេរមណី** វៀរចាកការចាក់សម្លាប់ អាយុជីវិតនៃសត្វដទៃ១ វៀរចាកការបំបាត់ប្រវ័ញ្ចដណ្តើមលបលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមប្បវេណីប្រពន្ធកូនអ្នកដទៃ១ ។

ការវៀរចាកអំពើអាក្រក់ មិនធ្វើដោយកាយទាំងបីប្រការនេះ ហៅថាកាយសុច-រិត ។

កាលបើបុគ្គលបានប្រតិបត្តិនូវកាយសុចរិត ដូចបានពោលមកខាងលើនេះ កន្លែងខ្លះសម្តែងថា បុគ្គលនោះលុះទៅជាតិខាងមុខបានអានិសង្សគឺ : មានសុខភាពល្អ-មានអាយុវែង ព្រោះមិនបៀតបៀនជីវិតសត្វ មានទ្រព្យសម្បត្តិគង់វង់មិនវិនាសអន្តរាយព្រោះមិនបំបាត់ប្រវ័ញ្ចទ្រព្យអ្នកដទៃ ។

មានកូនលុះក្នុងដំបូន្មានល្អ ព្រោះមិនប្រព្រឹត្តខុសក្នុងកាមប្បវេណីប្រពន្ធកូនអ្នកដទៃ ជាពិសេស ! (ជាអ្នកមិនបាច់ទៅពោបឡើងរកាដែកនាំឱ្យបាក់កម្លាំង) ។

**សុចរិត** គឺការប្រព្រឹត្តល្អដោយវាចាហៅថា វចីសុចរិតមាន ៤យ៉ាងគឺ : **មុសាវា-ទា វេរមណី** វៀរចាកការនិយាយកុហកភូតភរ គឺនិយាយតែពាក្យពិត សច្ចៈ ទៀងត្រង់ល្អ ១ **បិសុណាយ វាចាយ វេរមណី** វៀរចាកមិននិយាយពាក្យញុះញង់ស៊កសៀត និយាយតែពាក្យដែលកើតសាមគ្គីឱ្យមានប្រយោជន៍១ **ផរុស្សាយ វាចាយ វេរមណី** វៀរចាកការនិយាយរោយរាយផ្តេសផ្តាស ប៉ប៉ោចប៉បាចឥតប្រយោជន៍ ១។

ការវៀរចាកមិនធ្វើអំពើទុច្ចរិតដោយវាចា គឺប្រព្រឹត្ត ឬនិយាយដោយវាចាទាំង៤ នេះហៅថា វចីសុចរិត ។

**សាធុវា!** អស់លោកសប្បុរសទាំងឡាយ !

ការប្រព្រឹត្តល្អដោយវាចានេះ បើបុគ្គលណាមួយ ប្រកាន់ភ្ជាប់ហើយរមែងបានជាទីស្រឡាញ់ពេញចិត្តនៃសង្គមមនុស្សផងគ្នា ម្យ៉ាងទៀតការសុខទុក្ខមានលាភឥតលាភកន្លែងខ្លះ ក៏ព្រោះវាចានេះដែរ ។

បុរាណាចារ្យតែងពោលថា :

*អណ្តាតជាអាទិកន្លង បានសុខទុក្ខផងពីព្រោះអណ្តាត ។*

អស់លោកសប្បុរសទាំងឡាយ! អាត្មាភាពសូមលើកយករឿងមួយមកសម្តែងបញ្ជាក់អំពីប្រយោជន៍នៃវចីសុចរិតនេះ :

## រឿងសេដ្ឋីបុត្ត៤នាក់

កាលកន្លងទៅហើយក្នុងក្រុងពារាណសី មានសេដ្ឋីបុត្ត៤នាក់ចេញអំពីនគរទៅអង្គុយក្នុងទីមួយ បានឃើញព្រានម្រឹគម្នាក់បានដឹកសាច់មកលក់ក្នុងនគរ។ បណ្តាសេដ្ឋិបុត្តទាំងនោះ **សេដ្ឋីបុត្តម្នាក់ស្រែកសូមថា** : *"នែតាកំណាចចូរឱ្យសាច់មួយដុំមកយើង"* ពាក្យនោះពោលថា ធម្មតាពាក្យអ្នកសូមទានគេ តោងតែពោលពាក្យជាបិយវាចា វាចាដែលជាទីស្រឡាញ់ពេញចិត្ត ឯវាចារបស់អ្នកនេះទ្រគោះខ្មោះខ្មួលពេកណាស់ ប្រហែលគ្នានឹងសាច់វាវ អញត្រូវឱ្យសាច់វាវនេវ ទើបសមនឹងសម្តីរបស់អ្នកហើយ ក៏ឱ្យសាច់វាវមួយដុំដែលឥតរសជាតិនោះទៅ ។

**សេដ្ឋីបុត្តទី២** ស្រែកសូមថា : *"នែ! អ្នកបងជាធំ សូមឱ្យសាច់១ ដុំមកខ្ញុំ"* ព្រានពោលថា : នែ! សម្លាញ់! ពាក្យឯណាដែលអ្នកពោលថា បងប្រុសបងស្រី ពាក្យនោះប្រហែលគ្នានឹងអវយវៈរបស់មនុស្សលោកនេះវាចាអ្នកនេះប្រហែលគ្នានឹងអវយវៈ ។ ខ្ញុំឱ្យសាច់អវយវៈដ៏សមគួរដល់វាចារបស់អ្នកហើយក៏ឱ្យសាច់អវយវៈនោះទៅ ។

**សេដ្ឋីបុត្តទី៣** ស្រែកសូមថា : *"បពិត្របិតា សូមមេត្តាឱ្យសាច់១ ដុំមកខ្ញុំ"* ព្រានពោលថា កូនដែលហៅបិតាដូចនោះរមែងញ៉ាំងហឫទ័យនៃបិតាឱ្យព្រឺព្រួចវាចានេះប្រហែលគ្នានឹងសាច់ហឫទ័យ។ *"នែសម្លាញ់! ឱ្យសាច់បេះដូងដល់អ្នក!"* ហើយក៏ឱ្យសាច់មានរសជាតិឆ្ងាញ់ព្រមទាំងសាច់បេះដូងនោះទៅ ។

**សេដ្ឋីបុត្តទី៤** ស្រែកសូមថា: "នែសម្លាញ់! ចូរអ្នកឱ្យសាច់១ ដុំមកខ្ញុំ" ។ ព្រានតបថា *"សម្លាញ់នៃបុរសឯណាដែលមិនមានក្នុងស្រុកទេសទេ ស្រុកទេសនៃបុរសនោះ ទុកដូចជាព្រៃដែលឥតមានមនុស្សនៅ វាចារបស់អ្នកនេះប្រហែលគ្នានឹងសម្បត្តិរបស់ខ្ញុំទាំងអស់ ខ្ញុំត្រូវឱ្យសាច់ព្រមទាំងយានរបស់ខ្ញុំនេះដល់អ្នកទាំងអស់"* ។ ហើយក៏ព្រាននោះបរយានទៅកាន់ផ្ទះសេដ្ឋីបត្តទី៤ សេដ្ឋីបុត្តក៏បានធ្វើសក្ការៈ និងសេចក្តីរាប់អាន ហើយឱ្យព្រានទៅហៅប្រពន្ធកូនខ្លួនមក លែងឱ្យព្រាននោះប្រព្រឹត្តធ្វើអំពើអាក្រក់តទៅទៀតឱ្យនៅធ្វើការងារជាមួយគ្នានឹងខ្លួនដរាបដល់អស់ជីវិតរៀងខ្លួន ។

សេដ្ឋីបុត្តទី៤ ដែលបានលាភកើតឡើងដល់ខ្លួនយ៉ាងនេះអាស្រ័យមកអំពីពោលពាក្យថា "**បិយវាចា**" វាចាជាទីស្រឡាញ់ពេញចិត្តនៃអ្នកផងទាំងពួង ។

**សាធុរោ!** អស់លោកសប្បុរសទាំងឡាយ !

វចីសុចរិតនេះហើយដែលលោកប្រៀបថាដូចជាផ្កា អ្នកផងបូជាពុំដាច់ឱ្យសម្រេចប្រយោជន៍ក្នុងកាលជាបច្ចុប្បន្ននេះ មិនចាំបាច់ពោលដល់បរលោកឡើយ។ ហេតុនេះគួរសាធុជនទាំងឡាយ ប្រព្រឹត្តពោលតែពាក្យជាបិយវាចាផ្អែមល្ហែមពីរោះចាប់ចិត្តគួរឱ្យអ្នកផងទាំងពួង ចង់ស្តាប់ចង់ឮកុំខានឡើយ ។

**សុចរិត** ដែលផុះផុះចេញអំពីចិត្ត ហៅថាមនោសុចរិត មាន ៣គឺ : **អនភិជ្ឈា** មិនសម្លឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជារបស់ខ្លួនគឺជាអ្នកសន្តោសពេញចិត្តតែនឹងទ្រព្យរបស់ខ្លួន១ **អព្យាបាទ** មិនគំនុំគុំគួនចងអាឃាតអ្នកដទៃ ជាអ្នកមានមេត្តាករុណាដល់សត្វ ឬជននានា១ **សម្មាទិដ្ឋិ** មានគំនិតគិតសំគាល់ យល់ឃើញត្រូវ១ ។

ការប្រព្រឹត្តសុចរិតដោយចិត្តទាំង៣យ៉ាងនេះហៅថា មនោសុចរិត ។

សុចរិតទាំង៣យ៉ាងនេះ ជាកិច្ចគួរបំពេញ គួរធ្វើ ព្រោះជាផ្លូវនាំទៅកាន់សេចក្តីសុខ-ចម្រើនកើតសម្បត្តិ-លទ្ធផលល្អ ដែលបុគ្គលគប្បីបាននោះក៏ព្រោះប្រកបកាន់សុចរិតទាំង៣ យ៉ាងនេះ ។

បាលីបញ្ជាក់សុចរិតទាំង ៣យ៉ាង :

**"យទិទំ អានន្ទ មយា ឯកំសេន ករណិយំ អក្ខាតំ កាយសុ ចរិតំ វចីសុចរិតំ មនោសុចរិតំ តស្មឹ ករណិយេ ករិយមានេ អយំ អានិសំសោ បាដិកង្ខោ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មុឡ្ហោ កាលំ ករោតិ កាយស្ស ភេទាបរម្មរណា សុគតឹ សគ្គំ លោកំ ឧមបជ្ជតិ" ។**

"ម្នាលអានន្ទ កាលសុចរិត វចីសុចរិត មនោសុចរិត" ណាដែលតថាគតពោលថាជាកិច្ចគួរធ្វើដោយចំណែកមួយ បុគ្គលកាលធ្វើកិច្ចគឺសុចរិតដែលគួរធ្វើនោះ រមែងបានអានិសង្សដូចតទៅនេះ :

គឺខ្លួនឯងរមែងតិះដៀលខ្លួនមិនបាន១ លោកអ្នកប្រាជ្ញជ្រាបហើយរមែងសរសើរ១ ជាអ្នកមិនវង្វេងពេលជិតស្លាប់១ ខាងមុខអំពីសេចក្តីស្លាប់គឺបែកធ្លាយរាង

កាយទៅរមែងចូលទៅដល់សុគតិសួគ៌ទេវលោក១ ។

**សាធុរវោ**! អស់លោកសប្បុរសទាំងឡាយ !

អាត្មាភាពសម្តែងមកប៉ុននេះនេះ គឺជាការដោះស្រាយបញ្ហា ដែលបានបម្រុងទុកខាងដើមថា :

"ឱ្យរក្សាព្រៃ ១០" ។

បន្ទាប់ពីនេះទៅ អាត្មាភាពសូមលើកយកបញ្ហាទី៣ ដែលលោកពោលថា "ផឹកថ្នាំ ៥កញ្ចប់" នោះមកសម្តែងជូនសាធុជនដូចទៅនេះ :

ចុះអ្វីដែលលោកហៅថា "ថ្នាំ ៥កញ្ចប់នេះ បញ្ហានេះអស់លោកភាគខ្លះក៏តែងតែបានជួបប្រទះជាញឹកញាយណាស់ដែរមកហើយ ថែមទាំងបានក្រេបផឹកនូវថ្នាំ ៥កញ្ចប់នេះស្ទើរតែរាល់សប្តាហ៍ទៀតផង ។

ថ្នាំ ៥កញ្ចប់ក្នុងទីនេះមិនមែនអ្វីដទៃឡើយ លោកពោលថាសីលនេះឯង ព្រោះសីល ៥យ៉ាងនេះ ជាសីលប្រចាំលោក-សីលតែងមានក្នុងលោកគឺ :

**១. បាណា**... ។ល។ វៀរចាកការសម្លាប់សត្វ គឺមិនបៀតបៀនជីវិតសត្វទោះបីតូចក្តី-ធំក្តី (តែលោកឱ្យសម្លាប់សត្វទាំង៦)[3] ។

**២. អទិន្នា**... ។ល។ លោកឱ្យវៀរចាកការបំបាត់ប្រវ័ញ្ចលបលួចឆក់ដណ្តើមទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា ។

**៣. កាមេសុ មិច្ឆា**... ។ល។ ប្រែថាវៀរចាកការប្រព្រឹត្តខុសក្នុងកាមប្បវេណី-ប្រពន្ធកូនអ្នកដទៃ ។

**៤. មុសាវាទា វេ**... ។ល។ វៀរចាកការនិយាយកុហកភូតភរបោកប្រាសខ្វះការទៀងត្រង់ ។

**៥. សុរា មេរយ**... ។ល។ វៀរចាកការផឹកនូវទឹកស្រវឹងសុរា និងមេរ័យ ឬគ្រឿងស្រវឹងផ្សេងៗ មានកញ្ឆា ឬអាភៀនជាដើម ។

ថ្នាំទាំង ៥កញ្ចប់នេះ ជាថ្នាំពូកែស័ក្តិសិទ្ធិទាន់ចិត្ត អាចផ្ចាញ់ផ្ចាលនូវមេរោគនៃអកុសលធម៌ទាំងឡាយ ដែលបណ្តាលចេញមកតែអំពីព្រៃស្នាប់ទាំង៣ ដូចបានពោល

[3] សត្វទាំង៦ដែលលោកអនុញ្ញាតឱ្យសម្លាប់ក្នុងទីនេះ សំដៅយកឥន្ទ្រីយ៍៦ ហៅថា សត្វឥន្ទ្រីយ៍គឺ: ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។

មកហើយនោះឯង ។ មិនតែប៉ុណ្ណោះឡើយបើបុគ្គលណាបានផឹកនូវថ្នាំទិព្វទាំង ៥ កញ្ចប់នេះ បុគ្គលនោះតែងបានលទ្ធផលយ៉ាងពិសេសគឺ :

**១. អប្បមាទោ ធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ** អ្នកនោះនឹងបាននូវគំនរទ្រព្យដ៏ច្រើន មិនមានអធិករណ៍ព្រោះសេចក្ដីមិនប្រមាទ

**២. កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** នឹងមានឈ្មោះពីរោះល្អថាកល្យាណកិត្តិស័ព្ទផុះអណ្ដែតឡើង

**៣. វិសារទោ ឧបសង្កមិ អមង្កុភូតោ** កាលនឹងចូលទៅកាន់ទីប្រជុំតែងរីករាយមិនមានអៀនអន់ដាក់មុខសំយុងចុះ

**៤. អសម្មូឡ្ហោ កាលំ ករោតិ** វេលានឹងធ្វើកាលកិរិយាមិនវង្វេងស្មារតី

**៥. កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** បន្ទាប់ពីការបែកធ្លាយខន្ធទៅ តែងបានទៅកើតក្នុងសុគតិស្ថានសួគ៌ ។ ហើយត្រូវបានផល ៣យ៉ាងទៀតគឺ :

**សោតាបត្តិផល ១**

**សកទាគាមិផល ១**

**អនាគាមិផល ១ ។**

កន្លែងដទៃទៀតដែលលោកតែងសន្មតថា :

**សីលេន សុគតឹ យន្តិ** សត្វទាំងឡាយបានទៅកាន់ស្ថានសួគ៌ក៏ព្រោះសីល

**សីលេន ភោគសម្បទា** សត្វទាំងឡាយបានបរិបូណ៌ដោយភោគ ក៏ព្រោះសីល

**សីលេន និព្វុតឹ យន្តិ** សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ក៏ព្រោះសីល

**តស្មា សីលំ វិសោធយេ** ព្រោះហេតុនោះ បុគ្គលជាសប្បុរសគប្បីជម្រះនូវសីលឱ្យបរិសុទ្ធកុំឱ្យសៅហ្មង ។

អស់លោកសប្បុរសទាំងឡាយ! នេះជាសេចក្ដីបញ្ចប់ចុងក្រោយបង្អស់ដើម្បីទ្រោលបំភ្លឺឱ្យឃើញថា បើវរជនណាបានផឹកនូវថ្នាំ ៥កញ្ចប់ដូចអាត្មាបានសម្ដែងមកហើយខាងដើមនោះ គឺសុទ្ធតែជាផ្លូវនាំឱ្យទៅកាន់ប្រភពនៃសេចក្ដីសុខ-សេចក្ដីចម្រើនទាំងសុខ-ចម្រើនក្នុងលោកនេះ និងបរលោក ។

បន្ទាប់ពីនេះ អាត្មាភាពសូមលើកយកបញ្ហាទី៤ ដែលលោកបញ្ញត្តថា "**តមត្រណម២**" មកសម្តែងដោយសង្ខេបដូចតទៅនេះ :

ពាក្យថា តមត្រមណ២ ក្នុងទីនេះ លោកសំដៅយក "**មានះ១ ទិដ្ឋិ១**" ព្រោះធម៌ពីរប្រការនេះ ជាឧបសគ្គស្ទាក់ដំនើរជីវិតដែលកំពុងតែបោះជំហានឈានទៅរកសុខភាព-វឌ្ឍនភាព ដើម្បីជីវិតផ្ទាល់ ជីវិតគ្រួសារនិងជាប្រយោជន៍នៃជីវិតប្រទេសជាតិ។

**១. មានះ** សេចក្តីប្រកាន់រឹងត្អឹង ដោយមិនព្រមសុខចិត្តរណបចំពោះអ្នកប្រាជ្ញរាជបណ្ឌិត ឬសប្បុរសជនណាមួយឡើយ ទោះបីកិច្ចប្រតិបត្តិរបស់ខ្លួននោះមានការទាក់ទងផ្លូវលោកក្តី-ផ្លូវធម៌ក្តី ។ ព្រោះនឹកស្មានថា មនុស្សដទៃគ្មាននរណាមានចំណេះវិជ្ជា-ទ្រព្យសម្បត្តិ-យសស័ក្តិ-ជាតិត្រកូលវិសេសលើសខ្លួនឡើយ មានតែខ្លួននេះហើយដែលជាអ្នកគ្រាន់បើ ។

ម្ល៉ោះហើយមនុស្សម្នាក់នេះ បើនឹងគិត ឬធ្វើកិច្ចការអ្វី ក៏គ្មានក្រុមពិភាក្សា សូម្បីមួយនាក់ឡើយ ។ បញ្ហានេះអស់លោកជ្រាបស្រាប់ហើយ កិច្ចការណាមួយក៏ដោយក្នុងលោក កាលបើបុគ្គលប្រតិបត្តិធ្វើដោយគ្មានក្រុមសមាជិកពិភាក្សា ហើយការធ្វើម្នាក់ឯងនោះ ពុំសូវបានសម្រេចផលល្អទេ ការសម្រេចផលអាក្រក់តែងមានជាញឹកញាប់ដល់ជនប្រភេទនេះ ។

មនុស្សដែលមានភាពបែបនេះ ប្រៀបដូចជន្លេនដែលកើតក្នុងត្រឡោកផ្កាប់។ ធម្មតាជន្លេនដែលកើតក្នុងត្រឡោកផ្កាប់ កាលបើខ្លួនកានតែធំបណ្តោយខ្លួនក៏លូតវែងក៏ទើសនឹងត្រឡោក ហើយជន្លេននេះឥតដឹងថាត្រឡោកទេ បែរជាថាចក្រវាឡទៅវិញ កាលបើជន្លេនកើតក្នុងត្រឡោកផ្កាប់ដូចនេះគឺសន្មតថា *"អែយ៉ាងក្នុងកណ្តាប់ចក្រវាឡនេះមានតែអញទេតើ!"*

បញ្ហានេះមានន័យយ៉ាងណា ឯមនុស្សដែលប្រកាន់មានះរឹងត្អឹងក៏ដូចនោះដែរ ។

**២. ទិដ្ឋិ** ការយល់ឃើញខុស ការយល់ឃើញខុសនេះ ក៏ជាហេតុមួយនាំឱ្យបិទលាភជោគ-សិរីគ្រប់ប្រការ ព្រោះតែការយល់មិនច្បាស់ប្រាសចាកសភាវពិត យល់ទោសថាជាគុណ-យល់គុណថាជាទោស-កំហុសថាជាត្រូវយល់លាមកថាជាផ្កា យល់ធម្មាថាជាល្បែង យល់ម៉ែ-ឪឯងថាគ្មានគុណ ។

**សាធុរ៉ោ** ! អស់លោកសប្បុរសទាំងឡាយ! ការយល់បែបនេះហៅថា "**មិច្ឆាទិដ្ឋិ**" ប្រែថា "ការយល់ឃើញខុស" ការយល់ឃើញខុសនេះហើយដែលជាអន្លង់មួយធ្វើសត្វឱ្យលិចអណ្តែតៗ រកកោះត្រើយពុំឃើញហៅថា **ទិដ្ឋោឃៈ** អន្លង់នេះបើនឹងឆ្លងដោយនាវាទាំងឡាយមានទូកជាដើម ក៏ពុំអាចឆ្លងបានឡើយ ។ វៀរលែងតែបុគ្គលយកមហានាវាពោលគឺ សទ្ធាទៅឆ្លងទើបផុតពីអន្លង់គ្រោះកាចនេះបាន ។

ទ្រឹស្តីដែលប្រស្សូត្រចេញពីពុទ្ធឱស្ឋថា :

**សទ្ធាយ តរតិ ឱឃំ** សត្វឆ្លងនូវអន្លង់គឺ ឱឃៈបានដោយសារសទ្ធា ។ ការសម្តែងមកអំពីពាក្យថា "តមត្រណម២" ដោយសង្ខេបមកប៉ុននេះនេះដើម្បីបញ្ជាំងបំភ្លឺឱ្យឃើញថា ផ្លូវទាំងពីរដែលលោកតមនេះ ព្រោះសុទ្ធតែជាផ្លូវប្រកបដោយ មហន្តរាយគ្រោះថ្នាក់ទុក្ខទោសប្រាសចាកសេចក្តីសុខចម្រើនគ្រប់ប្រការក្នុងបច្ចុប្បន្នជាតិនេះនិងជាតិខាងមុខ ។

សាធុរ៉ោ ! អស់លោកសប្បុរសទាំងឡាយ! អាត្មាភាពបានសម្តែងមកអំពីបញ្ហាដែលបានពោលទុកខាងដើមថា :

"ឱ្យកាប់ព្រៃ ៣ រក្សាព្រៃ ១០

ធឹកថ្នាំ ៥កញ្ចប់ តមត្រណម ២"

ឱ្យកាប់ព្រៃ ៣ ព្រៃគឺ លោភៈ ទោសៈ មោហៈ ទាំង ៣នេះជាឫសគល់នៃអកុសលធម៌ទាំងពួង ឱ្យរក្សាព្រៃ ១០ ព្រៃគឺកុសលកម្មបថ ១០គឺ កាយសុចរិត ៣ វចីសុចរិត ៤ មនោសុចរិត ៣ ត្រូវជា ១០ ឱ្យតមត្រណម២ គឺមានះ១ ទិដ្ឋិ១ ។

ការសម្តែងមកប៉ុននេះ ក៏ល្មមសមតាមពេលវេលានឹងបញ្ចប់ធម៌ទេសនាតែមុននឹងបញ្ចប់ អាត្មាភាពសូមពូតផ្តុំប្រមុំបញ្ចូល ប្រមូលនូវគំនរកុសលផលបុណ្យទាំងឡាយដែលកើតអំពីសោមនស្សចេតនាជ្រះថ្លា បាននាំគ្នាបំពេញកងកម្មដ៏ប្រពៃនេះតាមដម្រាយទ្រឹស្តីនៃពុទ្ធសាសនា ។

ហេតុនេះសូមលើកយកកុសលមួយចំណែក ឧទ្ទិសជូនចំពោះវិញ្ញាណក្ខន្ធនៃពុទ្ធការីជនរបស់អស់លោកទាំងឡាយ ដែលទំលុះកាយទំលាយខន្ធទៅកាន់លោកខាងមុខក្តី មានជីពជន្មរស់នៅសព្វថ្ងៃនេះក្តី ចំពោះបុព្វការីដែលបានឆ្លងលោកនេះទៅហើយនោះ ក្រែងជួនជាគាត់ភ្លាំងភ្លាត់សតិអារម្មណ៍ណាមួយបានទៅកើតក្នុងទីថោកទាប ពុំសមតាមបំណងនោះ។ សូមបុញ្ញកុសលដែលកើតក្នុងវេលានេះ ទៅជួយឃិតយោងសណ្តោងយកនូវ

វិញ្ញាណក្ខន្ធនៃលោកទាំងនោះដាក់ទៅក្នុងទីដ៏ខ្ពង់ខ្ពស់ ឱ្យសមតាមបំណងកុំបីខានឡើយ បើគាត់បានកើតក្នុងទីដ៏ខ្ពង់ខ្ពស់ ហើយក៏សូមឱ្យរឹងតឹងតែខ្ពង់ខ្ពស់ជាភេយ្យោភាព ។

មួយចំណែកទៀត ជូនចំពោះអស់លោកទាំងឡាយដែលបានអញ្ជើញមកអំពីទីជិតក្តី ឆ្ងាយក្តី មិនបានអញ្ជើញមកក្តី សូមឱ្យបានចំណែកភាគផលស្មើៗនឹងលោកជាសាមីម្ចាស់បុណ្យ ហើយសូមឱ្យអស់លោកបានជួបប្រទះប៉ះសម្ភពជំពប់លើតែគំនរ ជោគសិរីគ្រប់ប្រការ ព្រមទាំងរបរអាជីវកម្មចិញ្ចឹមជីវិត ក៏សូមឱ្យមានការចម្រើនលូតលាស់ដុះដាលកើតកាលវាលគុម្ពត្រជាក់ត្រជុំថ្មុំថ្មើងរុងរឿងជាលំដាប់ ។

ជាពិសេស សូមឱ្យបានរួបរួមសាមគ្គី មាតា-បិតា-មីងមា-ស្វាមី-ភរិយា-ពូជពង្ស-វង្សត្រកូល កុំមានប្រេះឆាទាស់ទែងខ្វែងគំនិតបែកខ្ញែកព្រាត់ប្រាសនិរាសចាកគ្នីគ្នា សូមឱ្យបានប្រកបតែសុខមាលភាពមានជន្មវស្សាទីឃាយុយឺនយូរដរាបរៀងទៅហោង ។

**យំ យំ ឥច្ឆិតំ** សេចក្តីប្រាថ្នាក្នុងចិត្តយ៉ាងណាៗ

**តំ តំ សមិជ្ឈតុ** សូមឱ្យសេចក្តីប្រាថ្នានោះៗ បានសម្រេចដូចបំណងកុំបីឃ្លៀងឃ្លាតឡើយ ។

**អយំ ធម្មទេសនា** ឬព្រះធម៌ទេសនានេះ សម្មតា សន្មតថាចប់តែប៉ុននេះ **ឯវំ** ។

★ ★ ★

# អំពីសម្បុរសធម៌

ពរទាំងឡាយ ៥ប្រការគឺ :

**អាយុ** សូមឱ្យមានជន្មវស្សាយឺនយូរ១

**វណ្ណៈ** សូមឱ្យមានពណ៌សម្បុរកាយផូរផង់១

**សុខៈ** សូមឱ្យបានសុខកាយសប្បាយចិត្ត១

**ពលៈ** សូមឱ្យមានកម្លាំងកាយ-ចិត្ត១

**បដិភាណៈ** សូមឱ្យមានប្រាជ្ញាស្មារតី១ ។

ពរទាំង ៥ប្រការនេះ **ចរឡុន្ត** ចូរចម្រើនកើតមានដល់អស់លោកជាពុទ្ធមាកជនទាំងឡាយដែលមានបរិស័ទសទ្ធាជ្រះថ្លា ជឿជាក់ក្នុងពុទ្ធសាសនាបានចំណាយធនធាន លះបង់នូវមច្ឆិរិយមន្ទិលធម៌ នាំគ្នាអញ្ជើញពីគេហដ្ឋានរៀងៗខ្លួនមកកាន់ទីសន្និបាតនេះ ដើម្បីត្រងត្រាប់ស្តាប់នូវព្រះធម៌ទេសនា និងបានជាវត្តប្រតិបត្តិទៅ ។

ហើយបានអារាធនានិមន្តអាត្មាភាព ឱ្យជាអ្នកសម្តែងធម៌ទេសនាអាត្មាក៏ទទួលភារៈភ្នាក់ងារជាធម្មកថិការចារ្យ ខាងលើយកធម៌មកសម្តែងត្រដាងលាតលាចែកជូនដល់អស់លោក ដើម្បីជាបដិការៈតបស្នងឆ្លងសទ្ធាក្នុងឱកាសនេះដែរ ។

ប៉ុន្តែបើប្រសិនជាអាត្មាសម្តែងទៅហើយ ជូនជាមានបើលើសលោះខ្វះខាតបទបាឋព្យញ្ជនៈ អក្ខរៈបាលី សេចក្តីសម្រាយត្រង់កន្លែងណាមួយដោយអចេតនា ឬពុំសមរម្យតាមអធ្យាស្រ័យ-គោលបំណងនៃអស់លោកទាំងឡាយនោះ ត្រង់នេះសូមអស់លោកខន្តីអភ័យទោសដល់អាត្មាដែលជាអ្នកមិនមានបំណងពោលក្លែងមួលបង្កាច់ពុទ្ធដីកានោះឡើយសូមចម្រើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់) !

ខ្ញុំព្រះករុណាសូមនមស្សការចំពោះព្រះសម្មាសម្ពុទ្ធវិសុទ្ធិគុណអានន្ទញ្ញាណ ព្រះអង្គជាម្ចាស់សាសនាសាងសន្តិភព ឬថាព្រះអង្គជាវិរបុរសមួយមានមហាប្រទីបដ៏ធំវិសាល មានពន្លឺភ្លឺត្រចះត្រចង់រុងរោចន៍ពាសពេញផ្ទៃលោកទាំង ៣ជាប្រទីបសម្រាប់បំភ្លឺដល់សព្វសត្វដែលកំពុងដេកត្រាំក្នុងអន្លង់អវិជ្ជា-ក្នុងមោហន្ធភាព ក្នុងរាត្រីអន្ធការ ឱ្យមានចក្ខុភ្លឺស្វាង មើលឃើញសភាវពិតដើរតាមផ្លូវត្រង់ បោះជំហានឆ្ពោះទៅរកស្ថានសួគ៌-ស្ថាននិព្វានបាន ក៏ដោយសារមហាប្រទីបដ៏ភ្លឺ ពោលគឺព្រះសម្ពុទ្ធបរមគ្រូ ដែលព្រះអង្គបានរកឃើញពោធិបក្ខិយធម៌

ពុទ្ធការកៈធម៌ (ធម៌សម្រាប់ត្រាស់ដឹងថាព្រះពុទ្ធ) ហើយលើកឡើងសម្តែងបង្ហាញដល់សត្វនិករឱ្យនាំគ្នាដើរតាមមជ្ឈិមាបដិបទា គឺផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឆ្វេងមិនស្តាំ ឱ្យបានសម្រេចធម៌ដូចព្រះអង្គតាមនិស្ស័យរបស់សត្វដែលព្រះអង្គអាចទូន្មានបាន ។

ខ្ញុំព្រះករុណា សូមអភិវន្ទន៍បន្ទន់កាយក្រាបថ្វាយបង្គំចំពោះ ព្រះសម្មាសម្ពុទ្ធដោយសេចក្តីគោរព ។

ខ្ញុំព្រះករុណា សូមលំអុតលំអោនបន្ទន៍កាយ ក្រាបថ្វាយបង្គំចំពោះព្រះធម៌ដែលប្រសូត្រចេញពីពុទ្ធឱស្ឋជាធម្មជាតិដ៏វិសេសអាចដឹកនាំសត្វឱ្យ នាំគ្នាបែរមុខឈមត្រង់ឆ្ពោះទៅរកសេចក្តីសុខ-ចម្រើនក្នុងលោកនេះឬលោកខាងមុខ។

ហៅថា **មជ្ឈិមាបដិបទា** ផ្លូវប្រតិបត្តិយ៉ាងកណ្តាល អាចនាំសត្វឱ្យទទួលវត្ថុចំណងគ្រប់ប្រការ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះធម៌ដោយសេចក្តីគោរព ។

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំរំលឹកនឹកដល់គុណសង្ឃទាំងពីរប្រការគឺ : សម្មតិសង្ឃ និងអរិយសង្ឃ សង្ឃអង្គឯណាដែលបានសម្រេចធម៌ជាន់ខ្ពស់ឆ្លងលោកនេះទៅហើយព្រះសង្ឃអង្គនោះឈ្មោះថា "**អរិយសង្ឃ**" ព្រះសង្ឃដែលកើតឡើងដោយសន្មតដូចជាព្រះសង្ឃសព្វថ្ងៃនេះ លោកកំពុងតែសិក្សារៀនសូត្រប្រតិបត្តិ តាមធម៌-វិន័យរបស់ព្រះសម្ពុទ្ធដើម្បីកំចាត់បង់នូវ លោភៈ ទោសៈ មោហៈ ឱ្យស្រាលស្តែងជាលំដាប់ជាពិសេស ! សម្មតិសង្ឃសព្វថ្ងៃនេះលោកជាអ្នកកាន់សាសនាផ្ទាល់ខំថែរក្សា ប្រកាសសាសនាដោយចងក្រងបោះពុម្ពជាសៀវភៅខ្លះ ប្រកាសដោយការសម្តែងធម៌ទេសនាខ្លះ ។

**សព្វន្តរាយនិវារណត្ថំ** ការនមស្ការមកប៉ុននេះនេះដើម្បីការពាររារាំង នូវទុក្ខទោសគ្រោះថ្នាក់ភយន្តរាយផ្សេងៗ ដែលធ្លាប់មានមកដល់អាត្មាភាពនិងអស់លោកតាំងពីពេលមុនមកហើយក្តី ឬចង្រៃកាឡកិណ្ណិអព្វមង្គលសេចក្តីចង្អៀតចង្អល់តប្បៈម៉ល់ទល់ពុទ្ធោ ទង្គឹះខ្សឹកខ្សួលក្តួលក្តៅសៅហ្មងដែលបម្រុងចូលមករុករានក្នុងពេលឥឡូវនេះក្តី សូមឱ្យគ្រោះកំណាចអស់ទាំងនោះបររៀចចៀសចេញឆ្ងាយពីខន្ធសន្តាននៃយើងទាំងឡាយ...។

**ឯតេន សច្ចវជ្ជេន វុឌ្ឍិ ហោតុ សព្វទា** ដោយសច្ចៈវាចាដ៏ពិតដែលបានរៀបរាប់មកប៉ុននេះនេះ សូមសិទ្ធិសិរីសួស្តីជោគជ័យមង្គលសុខចម្រើន គ្រប់ប្រការកើតមានដល់ពុទ្ធបរិសទ្យទាំងឡាយ ឱ្យបានសព្វៗកាលតរៀងទៅ កុំបីមានឧបសគ្គណាមួយមកបៀតបៀនបានឡើយ ។

**តទនន្តរំ** បន្ទាប់ពីបទនមស្សការនេះទៅ អាត្មាភាពសូមលើកយក "**សប្បុរិសធម៌**" មកសម្តែងចែកជូនដល់អស់លោកដោយត្រួសៗ មិនបានពិស្តារវែងឆ្ងាយទេ លៃឱ្យល្មមតែពេល

វេលាដែលរាត្រីកាលធ្វើដំណើរទៅកាន់តែឆ្ងាយណាស់ហើយ ធម៌របស់សប្បុរស ហៅថា សប្បុរិសធម៌មាន ៧ យ៉ាងគឺ :

**១. ធម្មញ្ញុតា** ភាពជាអ្នកស្គាល់ហេតុ ដូចស្គាល់ថា នេះជាហេតុនៃសេចក្តីសុខ នេះជាហេតុនៃសេចក្តីទុក្ខជាដើម ។

**២. អត្ថញ្ញុតា** ភាពជាអ្នកស្គាល់ផល ដូចស្គាល់ថា នេះជាហេតុនៃសេចក្តីសុខ ជាផលកើតអំពីហេតុនេះហេតុនោះជាដើម ។

**៣. អត្តញ្ញុតា** ភាពជាអ្នកស្គាល់ខ្លួន ថាអាត្មាអញនេះមានត្រកូលយសស័ក្តិ សម្បត្តិ បរិវារសេចក្តីចេះដឹងនិង គុណធម៌ដែលមានក្នុងខ្លួនត្រឹមតែប៉ុននេះហើយប្រព្រឹត្តតាមគួរដល់ឋានៈរបស់ខ្លួន ។

**៤. មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណ ក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុងការបរិភោគជាដើម ។

**៥. កាលញ្ញុតា** ភាពជាអ្នកស្គាល់វេលាដែលនឹងប្រកបកិច្ចការនោះៗ ។

**៦. បរិសញ្ញុតា** ភាពជាអ្នកស្គាល់ប្រជុំជន និងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះៗ ថាពួកនេះកាលចូលទៅរក ត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយយ៉ាងនេះៗ ។

**៧. បុគ្គលបរោបរញ្ញុតា** ភាពជាអ្នកស្គាល់បុគ្គលថា អ្នកនេះស្គាល់មនុស្សល្អគួរគប់រក អ្នកនេះជាមនុស្សមិនល្អ មិនគួរគប់រកជាដើម ។

## អធិប្បាយ

**សាធុវោ** ! អស់លោកអ្នកសប្បុរសទាំងឡាយ ! សប្បុរិសធម៌ទី ១គឺ : ធម្មញ្ញុតា "ភាពជាអ្នកស្គាល់ហេតុ" ហេតុគឺរបស់ដែលបណ្តាលឱ្យមានផលដូចស្គាល់ថា ការប្រព្រឹត្តសុចរិតជាហេតុឱ្យបានសុខ ការប្រព្រឹត្តអំពើទុច្ចរិតជាហេតុបណ្តាលឱ្យកើតសេចក្តីទុក្ខ ការព្យាយាមខំសិក្សារៀនសូត្រ ជាហេតុនាំឱ្យចេះដឹង ការប្រឹងប្រែងស្វែងរក ជាហេតុនាំឱ្យមានទ្រព្យសម្បត្តិ ការប្រព្រឹត្តអបាយមុខ ជាហេតុនាំឱ្យវិនាសយ៉ាងនេះជាដើមហៅថា ស្គាល់ហេតុ។ ការស្គាល់ ជាគុណមួយយ៉ាងសំខាន់ អាចកំចាត់ចោលនូវហេតុដែលឥតប្រយោជន៍ជាទុក្ខ-ទោស គ្រោះថ្នាក់ មកប្រព្រឹត្តធ្វើតែហេតុដែលមានប្រយោជន៍ ជាសេចក្តីសុខសាន្ត និងបានប្រកបធ្វើតែហេតុណាដែលនាំឱ្យចម្រើនលូតលាស់ ។

សប្បុរិសធម៌ទី ២ គឺ **អត្ថញ្ញុតា** "ភាពជាអ្នកស្គាល់ផល" ផលគឺផ្លែផ្កាដែលបានមកអំពីហេតុដូចស្គាល់ថា សេចក្តីសុខជាផលរបស់សុចរិតធម៌ សេចក្តីទុក្ខជាផលដែលដែលមកពីការធ្វើទុច្ចរិត ចំណេះដឹងជាផលដែលបានមកពីការខំព្យាយាមរៀនសូត្រ យ៉ាងនេះជាដើមហៅថា ស្គាល់ផល ។

សប្បុរិសធម៌ទី ៣ គឺ **អត្តញ្ញុតា** "ភាពជាអ្នកស្គាល់ខ្លួន" ដូចស្គាល់ថាអាត្មា មានជាតិ ត្រកូល យសស័ក្តិ សម្បត្តិ បរិវារ មានការចេះដឹងនឹងគុណធម៌ត្រឹមប៉ុននេះ គប្បីទុកដាក់ខ្លួនតាមធុន តាមឋានៈដូចស្គាល់ថាខ្លួនជាសិស្សត្រូវប្រព្រឹត្តខ្លួនតាមខ្លួនតាមនាទីជាសិស្ស ឬជាគ្រូត្រូវប្រព្រឹត្តខ្លួនតាមឋានៈជាគ្រូ គឺតាំងខ្លួនឱ្យល្មមតាមឋានៈ ជាអ្នកចេះលៃចរិយាសណ្តាប់ធ្នាប់ឱ្យល្មមតាមសមត្ថភាពរបស់ខ្លួន ។

សប្បុរិសធម៌ទី ៤គឺ **មត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកគ្រឿងចិញ្ចឹមជីវិតដោយផ្លូវប្រពៃ និងដឹងប្រមាណក្នុងការបរិភោគតែល្មមសមគួរ ។ អាជីវកម្មគឺជានាទីប្រចាំបុគ្គល តែបុគ្គលដែលមិនដឹងប្រមាណដល់កិច្ចការដែលខ្លួនគប្បីធ្វើឱ្យសមល្មមតាមសមត្ថភាព និងតាមព្រឹត្តិការណ៍ទេក៏មុខជានឹងនាំខ្លួនឱ្យអន្តរាយខាតប្រយោជន៍ពុំខានឡើយ ។

ចំណែកបុគ្គល ដែលស្គាល់ប្រមាណកិច្ចការ មានសេចក្តីព្យាយាមឧស្សាហ៍ខ្វល់ខ្វាយ រមែងរកទ្រព្យបានទ្វេឡើងបរិបូណ៌ ការបើដឹងប្រមាណក្នុងការស្វែងរកហើយត្រូវដឹង ប្រមាណក្នុងការបរិភោគផងគឺចាយវាយប្រើប្រាស់តាមសមគួរដល់ការរកបាន។ មនុស្សខ្លះខ្ជាយចាយវាយទូលាយនៃហួសប្រមាណរមែងមិនបានសេចក្តីឆ្អែតឆ្អន់ចិត្តក្នុងការមានទ្រព្យ មនុស្សកំណាញ់ស្វិតចិត្តស្ងួតទុជនក្រៅតម្រា ក៏មិនបានទទួលផលល្អគឺសេចក្តីសុខ ។

ការដឹងប្រមាណក្នុងការស្វែងរក និងដឹងប្រមាណក្នុងការបរិភោគ រមែងញ៉ាំងប្រយោជន៍ឱ្យសម្រេចគ្រប់ទីស្ថាន អស់លោកសប្បុរសទាំងឡាយការសម្តែងមកនេះហៅថា សប្បុរិសធម៌ទី៤ ។

សប្បុរិសធម៌ទី ៥គឺ **កាលញ្ញុតា** "ភាពជាអ្នកស្គាល់វេលាដែលគួរប្រកបកិច្ចការនោះៗ" ត្រង់នេះក៏ជាការសំខាន់ បើបុគ្គលមិនស្គាល់ក្នុងការប្រកបកិច្ចការគួរធ្វើ ឬគួរនិយាយទេនោះ ជាហេតុនាំឱ្យបានទុក្ខទោសទាស់ទែងខាតប្រយោជន៍ ពេលវេលា

ដែលគួរធ្វើ ក៏មិនធ្វើ ដល់ពេលវេលាមិនគួរធ្វើបែរជាធ្វើទៅវិញ ការប្រព្រឹត្តផ្ទុយដូចនេះ រមែងបានផលអាក្រក់មិនតាមបំណងល្អឡើយ តែវាសមតាមគំនិតស្មាដៃរបស់ខ្លួន ដែលប្រកបខុសកាល ឧទាហរណ៍ ! ដូចពេលគេត្រូវធ្វើការ-ពេលគេត្រូវរៀនសូត្រ ខ្លួន មិនធ្វើការ មិនរៀនសូត្រ ដល់ពេលគេសម្រាក គេដេក ខ្លួនក៏ចាប់ផ្ដើមធ្វើការ ក្ដុងក្ដាំង រៀនសូត្រទន្ទេញឡូឡា នាំឱ្យរំខានដល់គេឯង ទៅជាទាស់ទែងខ្វែងយោបល់គ្នា ។ ការនិយាយក៏ដោយ ក៏ត្រូវស្គាល់ពេលស្គាល់វេលា កន្លែង ឬពេលដែលគួរនិយាយចាំ និយាយ មិនគួរនិយាយត្រូវស្ងៀម ដូចជាពេលគេកំពុងសូត្រសុទ្ធរកថាលោកទេសនា ជាដើម ខ្លួនទៅនិយាយរ៉ូងរ៉ាងរចេករចចក្នុងទីនោះ ឈ្មោះថា ខ្លួនមិនស្គាល់កាលវេលា ដូចនេះរមែងមិនបានទទួលសេចក្ដីសុខឡើយ ផ្ទុយទៅវិញគេអាចទិទៀនបានថា ខ្លួន ជាមនុស្សខ្វះសុជីវធម៌មិនស្គាល់កាលៈទេសៈ បុគ្គលដែលស្គាល់វេលាគួរធ្វើ គួរប្រកប កិច្ចការ គួរនិយាយ តាមកាលសម័យក្នុងការស្វែងរកទ្រព្យសម្បត្តិក្ដី និងកិច្ចដទៃៗ ឬ ការសិក្សាចំណេះវិជ្ជាក្ដី បុគ្គលនោះរមែងបានសម្រេចតាមឆន្ទៈពុំខានឡើយ ព្រោះ ហេតុនោះបានលោកចាត់ការដឹងវេលានេះថា សប្បុរិសធម៌ទី ៥ ។

ឯសប្បុរិសធម៌ទី ៦គឺ បរិសញ្ញុតា "ភាពជាអ្នកស្គាល់ប្រជុំជននិងកិរិយាដែលត្រូវ ប្រព្រឹត្តក្នុងទីប្រជុំជននោះៗថា ពួកនេះកាលចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវ និយាយយ៉ាងនេះៗ" បានសេចក្ដីថា ពាក្យថាប្រជុំជនគឺគ្រាដែលជនប្រជុំគ្នាជាសន្និ បាត បានក្នុងពាក្យថា ខត្តិយបរិសទ្យព្រាហ្មណបរិសទ្យ គហបតីបរិសទ្យ សមណ បរិសទ្យ ។

កាលចូលទៅរកបរិសទ្យណាមួយ ត្រូវប្រើកិរិយាវាចាឱ្យសមតាមឋានៈបរិសទ្យ នោះៗ មិនធ្វើ ឬនិយាយឱ្យខុសទំនងដំណើរ ខ្វះសម្ដីរាបសារជាទីជំទាស់ដល់ចិត្តនៃ បរិសទ្យនោះៗឡើយ យ៉ាងនេះចាត់ជាសប្បុរិសធម៌ខទី ៦ ។

សប្បុរិសធម៌ទី ៧ **បុគ្គលបរោរញ្ញុតា** "ភាពជាអ្នកស្គាល់បុគ្គលអ្នកនេះជាមនុស្ស គួរគប់រក អ្នកនេះជាមនុស្សមិនល្អ មិនគួរគប់រក" ជាដើម ត្រង់ខទី៧នេះ ជាកិច្ចយ៉ាង សំខាន់ មានប្រយោជន៍ឧត្តមក្នុងការរើសរកកល្យាណមិត្ត។

ព្រោះមនុស្សមានល្អ មានអាក្រក់ បើសេពគប់ត្រូវលើមនុស្សបាបមិត្រវាអាច ដឹកនាំខ្លួនយើង ឱ្យដើរតែផ្លូវវិនាស-ផ្លូវទុក្ខ-ផ្លូវអបាយមុខ ផ្លូវសោកចុងក្រោយ។ បើ

សេពគប់នឹងមនុស្សជាកល្យាណមិត្ត អាចដឹងនាំយើងឱ្យបានសេចក្តីសុខ-ចម្រើន បានសួគ៌និព្វាន ហេតុនេះមុននឹងសេពគប់មនុស្សណាមួយត្រូវស្គាល់ឱ្យច្បាស់ថាមនុស្សនេះ ជាមនុស្សទុច្ចរិត ឬសុចរិតជាមុនសិនទើបសេពគប់ជាមិត្តខាងក្រោយ ។

ការស្គាល់មនុស្សនេះចាត់ជាសប្បុរិសធម៌ខទី ៧។

**សាធុវោ** ! អស់លោកអ្នកសប្បុរសទាំងឡាយ !

មនុស្សជាសប្បុរស រមែងមានធម៌ ៧ ប្រការនេះជាគ្រឿងប្រព្រឹត្តជាដរាប ។ អាត្មាភាពសម្តែងមកអំពីសប្បុរិសធម៌ ៧ ប្រការក៏ល្មមសមកាលវេលានឹងបញ្ចប់ធម៌ទេសនា តែមុននឹងបញ្ចប់ សូមផ្សាយនូវបុញ្ញរាសីដែលកើតពីសេចក្តីជ្រះថ្លា នៃអស់លោកអ្នកក្នុងពេលនេះជូនដល់ពួកទេពនិករអម៉ររមេយ ដែលស្ថិតនៅក្នុងស្រុកតូចស្រុកធំ និគមជនបទកំណើតរាជធានីទីខេត្តខណ្ឌព័ន្ធព័ទ្ធសីមាសកឡាមហាវិហារកុដិសាលាប្រាង្គប្រាសាទព្រះស្តូបព្រះចេតិយ ព្រះស្រីមហាពោធិព្រឹក្សទាំងហេមវ័នសត្តបរភ័ណ្ឌគិរីបពិតព្រៃតូច ព្រៃធំព្រៃល្បាតញៀតញូក កោះដំបូកជ្រោះជ្រលងដងអូរទន្លេស្ទឹងបឹងបួរ សមុទ្រសាគរ វារីបឹងទីឋានតាមលំអានហូរហៃ ដរាបដល់លោកបាលមហារាជដែលមានអំណាចឃុំគ្រងនូវសត្វផងនានា ទៅដល់គ្នានឹងសហស្សន័យព្រះឥន្ទកោសិយជាអធិបតីនៃពពួកទេព្តា ។

កាលបើបានទទួលផលនេះហើយ សូមកុំមើលបំណាំឡើយ ត្រូវជួយថែរក្សាព្រះពុទ្ធសាសនាឱ្យបានថ្កុំថ្កើងរុងរឿងរហូតដល់ ៥០០០ ព្រះវស្សា ។

ម្យ៉ាងទៀតត្រូវជួយថែរក្សាពុទ្ធបរិស័ទ្យឱ្យបានសេចក្តីសុខ ចម្រើនលូតលាស់គ្រប់វិស័យក្នុងដំណើរជីវិតប្រាសចាក ឧបសគ្គភយន្តរាយផ្សេងៗសូម អស់លោកជាពុទ្ធបរិស័ទ្យទាំងឡាយបានសម្រេចសម្បត្តិ ៣ ប្រការគឺ :

សម្បត្តិមនុស្ស១ សម្បត្តិទេព្តា១ សម្បត្តិព្រះនិព្វាន១

**អយំ សង្ខេបេន សម្មតា** ធម៌ទេសនាសន្មតថាចប់ដោយសង្ខេបតែប៉ុននេះ **ឯវំ**។

★ ★ ★

# មន្ទិលធម៌៩យ៉ាង

ពរទាំងឡាយ ៤ប្រការគឺ :

**អាយុ** សូមឱ្យមានអាយុវែងយឺនយូរ១

**វណ្ណៈ** សូមឱ្យមានពណ៌សម្បុរសកាយផូរផង់១

**សុខៈ** សូមឱ្យមានសុខកាយសប្បាយចិត្ត១

**ពលៈ** សូមឱ្យមានកម្លាំងកាយ និងកម្លាំងសទ្ធា១

ពរទាំង ៤ប្រការនេះ **វឌ្ឍន្តុ** ចូរច្រើនកើតមានដល់អស់លោកពុទ្ធមាមកជនទាំងឡាយដែលបានអញ្ជើញមកអំពីគេហដ្ឋានផ្សេងៗគ្នា ទោះបីជិតឆ្ងាយក្តី មកប្រជុំសន្និបាតក្នុងទីនេះ ដើម្បីត្រងត្រាប់ស្តាប់យកនូវអត្ថរសនៃព្រះធម៌ទេសនា ហើយក៏បាននិមន្តអាត្មាភាពឱ្យជាអ្នកសម្តែង ។

អាត្មាក៏ទទួលភារៈភ្នាក់ងារជាអ្នកសម្តែង ដើម្បីតបស្នងឆ្លងសទ្ធារបស់អស់លោកក្នុងពេលនេះដែរ ប៉ុន្តែបើប្រសិនជាអាត្មាសម្តែងទៅហើយជួនជាមានបើលើសលោះខ្វះខាតដោយបទបាថ អក្ខរៈ ព្យញ្ជនៈបាលី សេចក្តីអធិប្បាយស្រាយត្រង់កន្លែងណាមួយ ពុំសមរម្យតាមអធ្យាស្រ័យ និស្ស័យចិត្តថ្លើមនៃអស់លោកនោះ ត្រង់នេះសូមខន្តីអភ័យទោសដល់អាត្មានឹងសម្តែងទៅតាមសតិបញ្ញាស្មារតីតិចតួចស្តួចស្តើង សូមចម្រើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ដង)

ខ្ញុំព្រះករុណាសូមមនស្សការចំពោះព្រះអរហន្តមុនីសម្មាសម្ពុទ្ធដ៏មានព្រះភាគអង្គនោះ(ព្រមទាំងព្រះសទ្ធម្មនិងព្រះអរិយសង្ឃ) ដោយសេចក្តីគោរព។

លំដាប់អំពីបទមនស្សការនេះ អាត្មាភាពសូមលើកយក **មលៈ "មន្ទិល"** ៩យ៉ាងគឺ : **កោធៈ** ក្រោធ១ **មកៈ** រមិលគុណ១ **ឥស្សា** ឫស្សា១ **មច្ឆរិយៈ** កំណាញ់១ **មាយា** មាយា១ **សាថេយ្យ** ពោលអួត១ **មុសា** កុហក១ **បាបិច្ឆៈ** ប្រាថ្នាអាក្រក់១ **មិច្ឆាទិដ្ឋិ** ឃើញខុស១ ។

## អធិប្បាយ

**មលៈ** គឺមន្ទិលនោះតាមវោហារសាសនាជាឈ្មោះនៃសេចក្តីប្រព្រឹត្តនិងសេចក្តីគិតដ៏សៅហ្មង គឺលាមក ប្រៀបដូចមន្ទិលខាងក្រៅ មន្ទិលនៃរាងកាយនិងច្រែះស្នឹមនៃលោហៈជាដើម។ មន្ទិលគឺញើសក្អែលនៃរាងកាយបើមិនលាងជម្រះទេ រមែងធ្វើពណ៌ឱ្យ សៅហ្មងធ្វើឱ្យស្អុយឆ្អេះឆ្អាបមានក្លិនអាក្រក់បណ្តាលឱ្យកើតរោគមានកមរមាស់ជាដើមយ៉ាងណា? ឯមន្ទិលរបស់មិត្តគឺមលៈ ៩រមែងធ្វើចិត្តឱ្យសៅហ្មងក្រខ្វក់ល្អក់មិនស្អាតក៏យ៉ាងនោះដែរ ។

ហេតុនេះសូមអស់លោកជាពុទ្ធបរិសទ្យទាំងឡាយ រង់ចាំស្តាប់អាត្មានឹងអធិ-ប្បាយជូនជាសណ្តាប់ដូចតទៅនេះ :

**មន្ទិលទី១** គឺសេចក្តីក្រោធ សំដៅដល់សេចក្តីឆុរឆេះគ្នាន់ខ្នាញ់តតូងតតាង ក្នុងកាលមានអារម្មណ៍ដែលមិនជាទីពេញចិត្តមកប៉ះពាល់ ។ សេចក្តីក្រោធនោះ កើតអំពីសេចក្តីមិនចេះអត់ធន់ មិនដែលពត់ហាត់ចិត្តពីមុនមក។ មនុស្សដែលបៀតបៀនរាងកាយគេក៏ព្រោះកើតសេចក្តីក្រោធជាមុន កាលសេចក្តីក្រោធចម្រើនឡើងហើយ ក៏តាំងធ្វើឱ្យគេអន្តរាយ ដោយផ្លូវកាយខ្លះវាចាខ្លះ ព្រោះសេចក្តីក្រោធកើតឡើងហើយរមែងធ្វើចិត្តឱ្យមួរម៉ៅ ពេលនោះហើយមនុស្សនេះលែងស្គាល់បាប បុណ្យ គុណទោសខុសត្រូវ ជ្រៅរាក់ព្រោះខ្លួនកំពុងតែត្រូវសេចក្តីក្រោធគ្របសង្កត់ ។

**មន្ទិលទី២** គឺរមិលគុណគេ ។ លោកអ្នកមានគុណដូចយ៉ាងមាតាបិតាឧបជ្ឈា-យាចារ្យ ឬបុគ្គលណាមួយដែលបានជួយសង្គ្រោះខ្លួន ខ្លួនបែរជាពេលក្រោយបំភ្លេចចោលនូវគុណបំណាច់ មើលងាយមាក់ថោកចំពោះបុព្វការីនោះវិញថាគ្មានគុណលើខ្លួននេះចាត់ជាមនុស្សអកតញ្ញូឬមនុស្សចិត្តខ្មៅ ។

ទ្រឹស្តីពុទ្ធសាសនាបានគូសបញ្ជាក់ថា :

កតញ្ញូតាធម៌មិនមានចំពោះបុគ្គលណា នរជនដទៃមិនគួរចូលទៅជិតដិតស្និទ្ធស្នាលនឹងបុគ្គលនោះឡើយ ។

សេចក្តីរមិលគុណនេះ កាលកើតដល់នរជនណា រមែងធ្វើនរជននោះឱ្យខូចទាំងផ្លូវលោក-ផ្លូវធម៌ ខូចប្រយោជន៍បច្ចុប្បន្ន និងអនាគតទើបលោកចាត់ថាជាមន្ទិលរបស់ចិត្ត ។

**មន្ទិលទី៣** គឺឫស្យា ។ ឫស្យាការច្រណែនឈ្នានីស កាលបើកើតមានដល់បុគ្គលណា រមែងធ្វើចិត្តបុគ្គលនោះឱ្យក្តៅក្រហាយ ខ្វាយខ្វល់អន្ទះអន្ទែងក្នុងកាលឃើញអ្នកដទៃល្អជាងខ្លួន ឬស្មើនឹងខ្លួន អត់ទ្រាំមិនបានក៏សម្តែងចេញឱ្យប្រាកដនូវចិត្តឫស្យានោះ ដោយកាយខ្លះ ដោយវាចាខ្លះ បន្ទាប់ពីនោះ ក៏ព្យាយាមដើម្បីនឹងបំផ្លិចបំផ្លាញគុណនៃសេចក្តីល្អរបស់គេ ចង់ល្អប្រសើរ ខ្ពស់មុខតែម្នាក់ឯង កាលបើធ្វើអ្វីគេមិនបាន ក៏កើតក្តៅចិត្តខ្លួនឯងរកសេចក្តីសុខគ្មាន ។

ព្រោះមានន័យយ៉ាងនេះទើបលោកចាត់ឫស្យាថាជាមន្ទិលរបស់ចិត្ត ។

**មន្ទិលទី៤** គឺកំណាញ់ ។ មានភាសិតថា "**មច្ឆេរំ ទទតោ មលំ** សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឱ្យ" បានសេចក្តីថា មនុស្សអ្នកឱ្យទាន បើត្រូវកំណាញ់គ្របសង្កត់ចិត្តហើយ ក៏មិនអាចបរិច្ចាកទានបានដែរ ។

សេចក្តីកំណាញ់ មិនចែកចាយផ្សាយសុខចម្រើនដល់សង្គមមនុស្សនេះរមែងធ្វើចិត្តឱ្យស្អុគ្រស្អាញចង្អៀតចង្អល់ មិនអាចសម្តែងសេចក្តីរីករាយបានឡើយ ហើយជាមនុស្សទ្រុស្តមិត្តឥតគេរាប់អាន ខានមានមិត្តភាពនឹងជននានាហេតុនេះកំណាញ់លោកចាត់ថាជាមន្ទិលរបស់ចិត្ត ។

**មន្ទិលទី៥** គឺមាយា លាក់ពុតត្បុត ធ្វើកិច្ចកលឧបាយលែបខាយនាយអាយបញ្ចេញកាយវិការឱ្យខុសប្រក្រតី ដោយចង់ឱ្យគេស្រឡាញ់ខ្លួន ឬឱ្យគេថែរក្សាខ្លួនដូចជាមិនឈឺ ធ្វើជាឈឺ ឬឈឺតិចក៏ធ្វើកិច្ចជាឈឺខ្លាំង ឬជាទៅហើយក៏ប្រាប់គេថាមិនទាន់ជាទៅវិញ ពុំនោះសោតទេខ្លួនជាមនុស្សប្រព្រឹត្តតែអំពើទុច្ចរិត ក៏ក្លែងធ្វើអាការកាយវិការជាមនុស្សស្លូតបូតសុភាពរាបសា ដើម្បីឱ្យគេទុកចិត្ត និងជាឧបាយងាយប្រព្រឹត្តអំពើទុច្ចរិតណាមួយ មានការបោកប្រាសជាដើម មនុស្សឆ្លាតគេអាចដឹងបានកាលគេដេញពុទទាន់ ក៏ជាការធ្វើឱ្យក្តៅក្រហាយគ្មានទីពឹងនឹងទៅទីណា ក៏មិនជាទីស្រឡាញ់ទុកចិត្តរបស់គេ ដូចនេះមាយានេះជាមន្ទិលរបស់ចិត្តមួយដែរ ។

**មន្ទិលទី៦** ពោលអួត គឺការអំនួតអួត គុណសម្បត្តិ សមត្ថភាពដែលមិនមានក្នុងខ្លួន ឱ្យគេឯងស្រឡាញ់កោតសរសើរ ដូចជាខ្លួនគ្មានចំណេះវិជ្ជាអ្វីទេ តែចង់ឱ្យគេរាប់អានស្រឡាញ់សរសើរខ្លួន ក៏តាំងនិយាយអួតអាងថាខ្លួនមានគុណវិសេសចំណេះវិជ្ជាយ៉ាងនេះ យ៉ាងនោះជាដើម ការអួតខ្លួននេះ បើគេដេញទាន់ជាន់ថ្នាក់បាននឹងនាំឱ្យ

រំខានក្តៅក្រហាយដល់ខ្លួនមិនខាន បានជាលោកចាត់ថា ជាមន្ទិលរបស់ចិត្ត ។

**មន្ទិលទី៧** គឺនិយាយកុហក ។ ការនិយាយចេញមកឱ្យឃ្លាតចាកសេចក្តីពិត គឺ មិនដឹងថាដឹង មិនឃើញថាឃើញ មិនមែនថាមែន ជាដើម ហៅថានិយាយកុហក និយាយកុហកនេះជាការបំផ្លាញ់សេចក្តីជឿរបស់អ្នកដទៃឱ្យវិនាស និងជាមន្ទិលជាប់ នៅនឹងចិត្តមិនចេះអស់ កាលគេដឹងថាខ្លួនកុហកគេម្តងទៅហើយ លុះពេលក្រោយ សូម្បីនិយាយពិតក៏តតនរណាជឿ ។

**មន្ទិលទី៨** គឺប្រាថ្នាក់អាក្រក់ ។ សេចក្តីប្រាថ្នាចង់បានក្នុងរបស់ដែលមិនត្រូវ តាមធម៌ ដូចប្រាថ្នាចង់បានលាភផលក្នុងផ្លូវទុច្ចរិត រកលាភផលក្នុងការអួតគុណវិសេ-សដែលមិនមានក្នុងខ្លួន ឬធ្វើអនេសនកម្ម ដូចជាដើរលលួងគេចិញ្ចឹមជីវិត ដោយការ ធ្វើជាពេទ្យ គ្រូទឹកមន្ត អាគមស្នេហ៍ស្និទ្ធ ភិក្ខុសាមណេរណាប្រព្រឹត្តស្វែងលាភ ដោយ ខុសចាកគន្លងធម៌យ៉ាងនេះ ឈ្មោះថាធ្វើចិត្តរបស់ខ្លួនឱ្យល្អក់មិនស្អាតចិត្តគ្រោតគ្រាត មិនស្ងប់ស្ងាត់ ទើបចាត់ថាជាមន្ទិលរបស់ចិត្ត ។

**មន្ទិលទី៩** គឺឃើញខុស ។ សេចក្តីឃើញខុសឃ្លាតពីសភាវៈពិត ពីគតិរបស់ ព្រះពុទ្ធសាសនា គឺយល់ឃើញថា បុណ្យបាបមិនមាន មានតាបិតាមិនមាន នរកសួគ៌ មិនមាន សត្វដែលបានសុខ ឬទុក្ខអាក្រក់ ឬល្អមិនមែនព្រោះកម្មទេ សុទ្ធតែព្រះជា ម្ចាស់សួគ៌បណ្តាលឱ្យទាំងអស់ដូចនេះចាត់ថាជាសេចក្តីឃើញខុស ព្រោះមិនត្រូវ ហេតុផល ។ សេចក្តីឃើញខុសបែបនេះមាននៅដរាបណាក៏ធ្វើចិត្តឱ្យសៅហ្មងដរាប នោះ ព្រោះកាលកើតឡើងហើយ នឹងធ្វើ ឬនិយាយ ក៏រមែងតែខុស ព្រោះចិត្តឃើញ ខុសទៅហើយ តអំពីនោះក៏រមែងជាផ្លូវមានទុច្ចរិតផ្សេងៗ ។

ព្រះពុទ្ធជាម្ចាស់ត្រាស់ប្រដៅថា "**មិច្ឆាទិដ្ឋឹ ន សេវេយ្យ** បុគ្គលមិនគួរសេពសេច-ក្តីឃើញខុស" ដូចនេះការឃើញខុសក៏រាប់ថាជាមន្ទិលរបស់ចិត្តមួយដែរ ។

បុគ្គលអ្នកមានបំណងចង់បានសេចក្តីបរិសុទ្ធផុតមន្ទិលទាំងអស់នោះ គប្បី បំពេញបញ្ញាឱ្យបរិបូណ៌ ព្រោះបញ្ញាជាគុណញុំាងបុគ្គលឱ្យបរិសុទ្ធបានដូចពុទ្ធភាសិត ថា :

"**បញ្ញាយ បរិសុជ្ឈតិ** បុគ្គលរមែងបរិសុទ្ធដោយបញ្ញា" ដូចនេះ ។

ឯវិធីជម្រះមន្ទិលទាំង ៩នោះគឺ : ចម្រើនមេត្តា ករុណា ឬខន្តី បំបាត់សេចក្តី

ក្រោធ ។ ប្រើកតញ្ញូកតវេទី បំបាត់ការលុបគុណគេ ។

ចម្រើន មុទិតា បំបាត់ឫស្យា ។ បំពេញទាន ឬចាគៈ បំបាត់កំណាញ់ប្រព្រឹត្ត សច្ចៈ បំបាត់មាយា។ បំពេញអត្តញ្ញូតា បំបាត់ការអួត ។ និយាយតែពាក្យពិត បំបាត់កុហក ។ ប្រព្រឹត្តសន្តោស គឺត្រេកអរតាមមានតាមបាន បំបាត់សេចក្តីប្រាថ្នាអាក្រក់។ ធ្វើសេចក្តីឃើញឱ្យត្រូវតាមគន្លងធម៌ គឺធ្វើសេចក្តីឃើញឱ្យត្រូវជាវិធីបំបាត់សេចក្តីឃើញខុស ឱ្យបានត្រូវឡើង ។

**សាធុរៅ** ! អស់លោកសប្បុរសទាំងឡាយ ! អាត្មាភាពសម្តែងមកអំពីមន្ទិល ៩ យ៉ាង ក៏ល្មមសមកាលវេលា តែមុននឹងបញ្ចប់ធម៌ទេសនាអាត្មាភាពសូមលើកយកបុញ្ញកុសលមួយចំណែក ដែលកើតឡើងក្នុងពេលនេះផ្សាយជូនចំពោះបុព្វការីជនរបស់អស់លោកទាំងឡាយ ដែលធ្វើមរណកាលទៅហើយក្តីរបស់នៅសព្វថ្ងៃក្តី បើលោកដែលធ្វើមរណកាលទៅហើយនោះ ក្រែងជួនជាគាត់ភ្លាំងភ្លាត់សតិអារម្មណ៍បានទៅកើតក្នុងទីដ៏ថោកទាប សូមកុសលដែលកើតក្នុងវេលានេះ ទៅជួយស្ទួចទ្រនូវវិញ្ញាណក្ខន្ធនៃលោកទាំងនោះដាក់ទៅក្នុងទីដ៏ខ្ពង់ខ្ពស់ផង ចំពោះបុព្វការីជនរបស់លោកដែលរស់នៅសព្វថ្ងៃនេះ សូមបានប្រកបដោយសេចក្តីសុខ សេចក្តីចម្រើន មានជន្មាយុយឺនយូរវែងឆ្ងាយ ។

ព្រមទាំងអស់លោក ដែលបានអញ្ជើញមកមីរដេរដាសពាសពេញក្នុងទីនេះ សូមបានប្រកបជួបប្រទះតែនឹងសេចក្តីសុខ-ក្តីចម្រើន កុំបីមានឧបសគ្គណាមួយមកបៀតបៀន យាយីបានឡើយ ។

ហើយសូមឱ្យលោកបានសម្រេចសម្បត្តិទាំង ៣ប្រការគឺ : សម្បត្តិ មនុស្ស១ សម្បត្តិទេព្តា១ សម្បត្តិព្រះនិព្វាន១ ។

**អយំ សង្ខេបេន សម្មតា** ធម៌ទេសនា ក៏សន្មតថាចប់ដោយសង្ខេប **ឯវំ** ។

★ ★ ★

# ខន្តីធម៌

ខ្ញុំព្រះករុណា សូមនមស្សការចំពោះព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ព្រោះថា ចាប់ដើមតាំងពីព្រះអង្គបានត្រាស់ដឹងបរមាភិសេកសម្ពោធិញ្ញាណមកកាល ណា ហើយ ព្រះអង្គទ្រង់មានព្រះទ័យពោរពេញទៅដោយមហាករុណា ទិគុណអាណិត អាសូរដល់សព្វសត្តនិករ ទាំងអស់ដោយមិនរើសមុខថាសត្វមាន ឬក្រ អាក្រក់ ឬល្អ នោះឡើយ ម្ល៉ោះហើយបានជាព្រះអង្គខំប្រឹងប្រែងយកព្រះទ័យទុកដាក់ក្នុងការសម្តែង ធម៌ទេសនាទាំងយប់ទាំងថ្ងៃ ឥតមានសម្រាកព្រះអង្គមួយវេលារាត្រីណាសោះ ដរាប ដល់៤៥ព្រះវស្សាគត់ ។

សូម្បីតែព្រះអង្គរៀបយាងទៅកាន់សិវដ្ឋាន គឺព្រះនិព្វានសោតទៀតក៏ព្រះអង្គខំ ប្រតិស្ឋានសាសនាទុកឱ្យមាន ៥០០០ព្រះវស្សាទៀត ដើម្បីប្រយោជន៍ដល់សព្វសត្វ ទាំងអស់ក្នុងត្រៃភព ។

ម្យ៉ាងទៀតខ្ញុំព្រះករុណាសូមនមស្សចំពោះនិយ្យានិកធម៌ ដែលជាធម៌សម្រាប់ ស្រោចស្រង់សត្វ និងដឹកនាំពាំយួរគៀរគរប្រមូលបញ្ចូលចិត្តរបស់សត្វឱ្យនាំគ្នាបែរមុខ ឈមត្រង់ទៅ **បជ្ឈិមាបដិបទា** គឺផ្លូវប្រតិបត្តិយ៉ាងកណ្តាលមិនឆ្វេង មិនស្តាំ ឬ **ឧជុច-មគ្គោ** និយ្យានិកធម៌ ដែលជាធម៌ដឹកនាំសត្វឱ្យធ្លាក់ចុះទៅក្នុងផ្លូវត្រង់ ឆ្ពោះទៅរក សេចក្តីសុខចម្រើនក្នុងលោកនេះនឹងលោកខាងមុខ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណាសូមនមស្សការចំពោះព្រះសង្ឃទាំងពីរប្រការគឺសម្មតិ សង្ឃ និងអរិយសង្ឃ ដែលលោកមានសីលដ៏បរិសុទ្ធ អាចរក្សាការពារនូវអនេសនៈ ២១ និងបាបធម៌ ៥យ៉ាង សង្ឃទាំងពីរពួកនេះហើយដែលជាបុញ្ញខេត្ត គឺជាស្រែ បុណ្យ មានជីវជាតិដ៏ល្អស្អាត សត្តនិករទាំងអស់បាននាំគ្នាយកពូជធារ ពោលគឺបច្ច័យ ៤មានចីវរបច្ច័យជាដើម យកទៅសាបព្រួសអាចលូតលាស់ដុះដាល ផ្លែផ្កាសម្រេចទៅ តាមសេចក្តីប្រាថ្នារបស់ម្ចាស់ទានទៅបាន ។

ការរៀបរាប់បទនមស្សការមកប៉ុននេះ សន្មតថាចប់ **សព្វន្តរាយ និវា រណត្ថំ** ការ ធ្វើបទនមស្សការមកប៉ុននេះនេះ ដើម្បីការពាររារាំងនូវទុក្ខទោសគ្រោះថ្នាក់ ឬភយន្ត រាយផ្សេងៗ ដែលធ្លាប់មានដល់អាត្មាភាពនិងពុទ្ធបរិសទ្យតាំងពីយូរយារណាស់មក

ហើយក្តី ឬចង្រៃឧបទ្រពកាឡកិណ្ណីអពមង្គលណាមួយដែលបម្រុងនឹងចូលមករុករាន ទន្ទ្រានបៀតបៀនយាយី ក្នុងគ្រាឥឡូវនេះក្តី សូមឱ្យបាបគ្រោះទាំងអស់នោះ ចៀស ចេញឆ្ងាយពីខន្ធន្ទាននៃយើងទាំងឡាយ **ឯតេន សច្ចវជ្ជេន វុឌ្ឍិ ហោតុ សព្វទា** ដោយ សច្ចៈវាចា គឺវាចាដ៏ពិតដែលបានរៀបរាប់មកនេះ សូមសិរីសួស្តីជ័យមង្គលសុខ-ចម្រើ-នគ្រប់ប្រការកើតមានដល់អស់លោកជាពុទ្ធបរិស័ទ្យទាំងឡាយ ឱ្យបានសព្វកាលត រៀងទៅកុំបីមានឧបសគ្គណាមួយមកបៀតបៀន ជិតដាមជាប់ដល់សិរី អវយវៈរបស់ អស់លោកឡើយ ។

**តទនន្តរំ ធម្មំ ទេសេស្សាមិ** បន្ទាប់បន្សំអំពីបទនមស្សការនេះទៅអាត្មាភាពនឹង លើកយក "**ខន្តីធម៌**" ដែលជាធម៌ទ្រទ្រង់លោកទុកជាជន្ទល់ទី២ក្នុងបណ្តាជន្ទល់ទាំង បីគឺ សច្ចៈ ខន្តី កតញ្ញូ ធម៌ទាំងបីនេះជាធម៌សម្រាប់ទល់ទ្រស្ទួយសត្វលោកឱ្យមានមុខ ឆ្ពោះទៅរកអារ្យធម៌ ។

តែធម៌ទាំងបីប្រការនេះមិនបានលើកយកមកសម្តែងទាំងអស់ទេ ក្នុងឱកាស នេះសូមសម្តែងតែខន្តីធម៌ ដែលជាធម៌ទីពីរប៉ុននោះ ដើម្បីជាបដិការៈតបស្នងឆ្លង សទ្ធារបស់អស់លោក ដែលមានសោមនស្សចេតនាប្រកបដោយញ្ញាណសម្បយុត្ត បានបង្កើតឡើងនូវបុញ្ញកម្មដ៏ឱឡារឹកនេះ !

**ខន្តី** ប្រែថាសេចក្តីអត់ជាគូនឹង **តីតិក្ខា** ប្រែថាសេចក្តីអត់ធន់ សព្ទទាំងពីរនេះ មានសេចក្តីជាមួយគ្នាទើបរួមចូលគ្នាហៅថា សេចក្តីអត់ធន់ ។ សេចក្តីអត់ធន់នេះ លោកចែកចេញជា ៣យ៉ាងគឺ :

១. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតលោភៈ

២. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតទោសៈ

៣. អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតមោហៈ

ឯការអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឱ្យកើតលោភៈនោះបានខាងការ អត់ទ្រាំនឹងចំណង់ផ្សេងៗ ដែលកើតឡើងក្នុងទ្វារទាំង ៦ ។

ពាក្យថា អត់ទ្រាំ គឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬតាមសេចក្តីស្រេកឃ្លាន នោះៗ ។

បុគ្គលជំពូកខ្លះ ព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ ឬសេចក្តីស្រេកឃ្លានបាន

ជាហ៊ានលួចឆក់ដណ្តើមបំបាត់ប្រវ័ញ្ចទ្រព្យសម្បត្តិរបស់អ្នកដទៃ កាលបើប្រព្រឹត្តដូចនោះ រមែងតែជួបប្រទះនឹងសេចក្តីទុក្ខព្រួយដែលជាផលរបស់ទុច្ចរិតនោះៗ មានត្រូវទោសជាប់គុកច្រវាក់ជាដើម ។ បុគ្គលណាជាមនុស្សមិនសូវជាមនុស្សរវះរវាមពេកចេះអត់ទ្រាំបាននឹងស្រេកឃ្លាន នឹងចំណង់ផ្សេងៗបុគ្គលនោះតែងប្រកបដោយសុភាព និងអនាម័យល្អ ។

**ខន្តី** សេចក្តីអត់ធន់បែបនេះ ហៅថាអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុនាំឱ្យកើតលោភៈ សូម្បីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឱ្យកើតរាគៈ ក៏គួរសង្គ្រោះចូលក្នុងខន្តីនេះដែរ ។

ឯសេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុនាំឱ្យកើតទោសៈបានខាងសេចក្តីអត់ធន់និងពាក្យបរម្បវាទ ដែលបុគ្គលដទៃស្តីថា រិះគន់ទិទៀននិន្ទា ឬត្មិះតិះដៀល ពុំនោះអត់ធន់នឹងអំពើដែលបុគ្គលដទៃបៀតបៀនប្រទុស្តរ៉ាយដែលជាហេតុឱ្យកើតទោសៈ ។ តាមពិត ! មនុស្សដែលកើតមកក្នុងលោកនេះ ដែលថាមិនឱ្យគេស្តីថាមិនឱ្យគេរិះគន់នោះគ្មានទេសូម្បីព្រះអាទិត្យ ព្រះចន្ទ្រ ដែលរះឡើងបំភ្លឺលោកជាប្រក្រតី ម្តេចគង់មានគេតិះដៀលខ្លះដែរ ចំណង់លើមនុស្សលោកនឹងរកនរណាឱ្យជាមនុស្សឥតគេតិះដៀលនោះមិនមានឡើយ ទុកជាព្រះសម្ពុទ្ធជាម្ចាស់ដែលប្រកបដោយមហាករុណាទិគុណ ទ្រង់ត្រាស់ដឹងនូវសព្វញ្ញុញ្ញាណជ្រាបច្បាស់នូវមគ្គផលទាំងពួង ក៏គង់គេតិះដៀលខ្លះដែរ បើយល់ជាក់យ៉ាងនេះហើយ គួរឱ្យមានខន្តីអត់ធន់កុំប្រញាប់ក្រេវក្រោធច្រឡោតតតួងតតាង។ បោរាណាចារ្យទាំងឡាយលោកសម្តែងប្រាប់ឧបាយ ជាគ្រឿងរំលត់សេចក្តីក្រោធខឹងថា : *"បើទុកជាមានភ្នែកភ្លឺ ក៏ត្រូវធ្វើជាងងឹត មានត្រចៀកស្តាប់ឮពិត ក៏ត្រូវតែធ្វើដូចជាថ្លង់"* ដូចនេះទើបអត់ធន់សេចក្តីក្រោធខឹងនោះបាន ប្រសិនបើជាមនុស្សភ្នែកទិព្វត្រចៀកទិព្វ ចេះតែឃើញចេះតែឮហើយយើងនៅជាបុថុជ្ជន ចិត្តស្រាលផងក៏នឹងរក្សាខន្តីសេចក្តីអត់ធន់នោះបានដោយកម្រណាស់។ ម្យ៉ាងទៀតលោកជាពាក្យឃ្លោងថា : *"បើសិនជាមានសេចក្តីក្រោធ កុំច្រឡោតត្រូវរាប់អក្សរសិន រាប់អក្សរ ក-ខ ដល់ឡអាំង ចសំកាំងត្រូវនឹកដល់ដង្ហិនត្រិះរិះរកហេតុផលសិន បើប្រសិនខឹងល្មមគង់នឹងស្រាក ពុំនោះលោកថាឱ្យរាប់លេខពីឯកដល់ទសឈប់សម្រាក ទ្រឹងមួយស្របក់គង់នឹងស្រាក ឃ្លាតចាកកំហឹងដ៏ឃោរ-*

*ឃៅ*" ។ ឯការអត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុឱ្យកើតមោហៈនោះបានខាង សេចក្ដីអត់ធន់នឹងទុក្ខវេទនាផ្សេងៗ ដែលកើតឡើងក្នុងកាយនឹងចិត្តមិនលុះក្នុង អំណាចទុក្ខវេទនា ហើយទៅប្រព្រឹត្តអំពីទុច្ចរិតផ្សេងៗ ជាហេតុជួយឧបត្ថម្ភឱ្យមាន **សតិសម្បជញ្ញៈ** គឺសេចក្ដីភ្ញាក់រលឹក និងសេចក្ដីដឹងខ្លួន ដែលជាគុណវិសេសគួរមាន គ្រប់កាយទាំងពួង ពុំនោះសោតក្នុងវេលាមានព្យាធិ ដែលជាហេតុឱ្យដល់មរណៈ ក៏ ត្រូវតែមានខន្តីយ៉ាងមាំមួនខានពុំបានឡើយ ។ ឧបាយដែលនឹងឱ្យកើតខន្តីក្នុងវេលា នោះក៏ត្រូវគិតឱ្យឃើញតាមសេចក្ដីពិតថា ព្យាធិនិងមរណៈនោះ ជាទុក្ខដែលសត្វទាំង ឡាយត្រូវជួបប្រទះរាល់ៗរូប គេចមិនរួចក្នុងអភិណ្ហប្បច្ចវេក្ខណៈដែលព្រះសម្ពុទ្ធទ្រង់ ប្រដៅ ឱ្យនឹករំពឹងជារឿយៗថា : "**ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ** អាត្មាអញមានជំងឺ ដម្កាត់ជាធម្មតា នឹងចៀសវាងពីជំងឺដម្កាត់មិនបានឡើយ" ដូចនេះនោះក៏គប្បីឱ្យប្រុង ខ្លួនអំពីកាលដែលនៅជានៅឡើយ បើចាំទៅរំពឹងក្នុងពេលដែលជំងឺដម្កាត់មកដល់តែ ម្ដង ក៏មុខជាកម្រនឹងបាន ព្រោះវេលាដែលឈឺនោះឯងតែងមានទុក្ខព្រួយលំបាក ច្រើនយ៉ាងណាស់ កាលបើអត់ទ្រាំទុក្ខវេទនាមិនបាន សតិសម្បជញ្ញៈក៏រសាត់អណ្ដែត ទ្រេតទ្រោត មិនតាំងខ្ជាប់ខ្លួនឡើយ ដូចជនជំពូកខ្លះដែលមិនបានហាត់ចិត្តទុកអំពី កាលនៅជានោះ លុះវេលាដែលមានជំងឺយ៉ាងធ្ងន់មក ក៏ច្រើនតែមានចិត្តរវើរវាយ ផ្សេងៗ សូម្បីតែយ៉ាងនេះហើយក៏នៅតែមិនទាន់ភ្ញាក់កំណើតកើតគំនិតគិតតែប្រព្រឹត្ត អំពើទុច្ចរិត មានសម្លាប់សត្វជាដើមទៀត ដើម្បីបូជាគ្រោះចង់រស់តែខ្លួនឯង មិនគិត អាណិតដល់សត្វដទៃក៏មាន ។

ព្រោះហេតុដូចនោះ ការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតីដើម្បីឱ្យកើតខន្តីនោះ ជា ដែលយើងត្រូវការគ្រប់ៗប្រាណ សម្រាប់ប្រយុទ្ធតស៊ូនឹងគូសត្រូវ គឺព្យាធិទុក្ខក្នុងវេលា ដែលជិតនឹងដល់នូវមរណៈទុក្ខនោះ។ ចំណែកអ្នកដែលមានប្រាថ្នារៀនរកនូវភោគ ទ្រព្យ និងវទ្យាសាស្ត្រ អក្សរសាស្ត្រ ក្សេត្រសាស្ត្រ ពាណិជ្ជកម្ម កសិកម្ម ជាដើម បើ មានខន្តីចេះអត់ធន់ចំពោះការអត់ឃ្លានមានក្រក្ដៅត្រជាក់ជាដើម ហើយវិជ្ជាការនឹង ភោគ ក៏រមែងសម្រេចដល់បុគ្គលនោះសមតាមបំណងហើយការរស់នៅរបស់បុគ្គល នោះឈ្មោះថាមិនចង្អៀតលោកឡើយ ។

ម្យ៉ាងទៀត អ្នកដែលមានខន្តីរមែងជាទីស្រឡាញ់ពេញចិត្តនៃវេទនានិងមនុស្ស

ទាំងឡាយ ។

ដូចមានពុទ្ធភាសិតសម្តែងថា :

**ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា**

**បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ ។**

មានខន្តីជាអ្នកមានមេត្តា ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកមានខន្តីរមែងជាទីស្រឡាញ់ជាទីគប់ចិត្តនៃទេវតានិងមនុស្សទាំងឡាយ ។

ម្យ៉ាងទៀតខន្តីនេះទុកដូចជាភាជន៍ សម្រាប់តម្កល់នូវគុណធម៌ គឺសីលនិងសមាធិឱ្យស្ថិតនៅខ្ជាប់ខ្ជួនកុំឱ្យរាត់រាយខ្ចាត់ខ្ចាយ ឬទុកដូចជាពូជរបស់កុសលធម៌ទាំងពួង ។

សមដូចពុទ្ធភាសិតសម្តែងថា :

**សីលសមាធិគុណានំ ខន្តិ បធានការណំ**

**សព្វេបិ កុសលាធម្មា ខន្ត្យាយេវ វឌ្ឍន្តិតេ ។**

ខន្តីជាហេតុ ជាទីតាំងនៃគុណ គឺសីលនិងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដល់សេចក្តីអត់ធន់មែនពិត ។

ម្យ៉ាងទៀតខន្តីនេះទុកជាអាវុធដ៏មុតថ្លា សម្រាប់កាត់ផ្តាច់នូវឫសគល់នៃបាបទាំងឡាយ ឬសម្រាប់ជីកគាស់រំលើងនូវឫសនៃទោសទាំងឡាយមានការឈ្លោះប្រកែកជាដើម សមនឹងពុទ្ធភាសិតថា :

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**

**គរហកលហាទីនំ មូលំ ខនតិ ខន្តិកោ ។**

ខន្តីដែលតែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ឈ្មោះថា ជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យត្រិះដៀលនិងការឈ្លោះប្រកែកជាដើម ។

ម្យ៉ាងទៀតខន្តីនេះ ទុកជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ជាភ្លើងសម្រាប់ដុតនូវកំលោចនៃបាបជាពលីរបស់ធម្មចារីទាំងឡាយ និងជាប្រលាយសម្រាប់បង្ហូរមកនូវ

ប្រយោជន៍ និងសេចក្ដីសុខ ។

ព្រោះពុទ្ធភាសិតថា :

**ខន្តី ធីរស្សាលង្ការោ ខន្តិ តបោ តបស្សិនោ**

**ខន្តី ពលំ វ យតីនំ ខន្តិ ហិតសុខាវហា ។**

ខន្តីជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ខន្តីជាគ្រឿងដុតនូវបាបរបស់អ្នកប្រព្រឹត្តធម៌ ខន្តីជាគុណជាតនាំមកនូវប្រយោជន៍និងសេចក្ដីសុខ ។

ម្យ៉ាងទៀតខន្តីនេះ បើមាននៅក្នុងបុគ្គលណាហើយ បុគ្គលនោះឈ្មោះថាជាអ្នកដឹកជញ្ជូននាំមកនូវប្រយោជន៍ ដើម្បីខ្លួនឯងផង ឱ្យដល់បុគ្គលដទៃផងទាំងឈ្មោះថាជាអ្នកបានដើរក្នុងផ្លូវជាទីទៅកាន់ឋានសួគ៌ និងព្រះនិព្វាន ។

ម្យ៉ាងវិញទៀតអ្នកមានខន្តី ឈ្មោះថាជាអ្នកប្រតិបត្តិតាមឱវាទរបស់ព្រះសម្ពុទ្ធជាអ្នកបានបូជានូវព្រះសម្ពុទ្ធដោយការបូជាដ៏ខ្ពង់ខ្ពស់ ។

ព្រោះមានពុទ្ធភាសិតសម្ដែងថា :

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ**

**បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកមានខន្តី ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីការជាឱវាទរបស់ព្រះសាស្ដាមែន អ្នកមានខន្តីឈ្មោះថា បានបូជានូវព្រះជិនស្រីដោយការបូជាដ៏ឧត្ដម ។

ឯពាក្យថាខន្តីនេះ សំដៅយកត្រង់ការអត់ធន់នូវសម្ផស្ស របោម មូស ខ្យល់កំដៅថ្ងៃ ពស់តូច ពស់ធំ សេចក្ដីស្រេចឃ្លាន និងពាក្យអាក្រក់របស់បុគ្គលដទៃជាដើម កាលបើហេតុទាំងនេះកើតមានឡើងចេះអត់ធន់បានមិនញាប់ញ័រ មិនបណ្ដោយឱ្យខូចប្រយោជន៍ដោយសារតែហេតុទាំងនោះ ។

អ្នកប្រាជ្ញទាំងឡាយតែងសរសើរនូវបុគ្គលដែលចេះអត់ធន់ គឺចេះប្រើខន្តីតាមលម្អានរបស់បណ្ឌិត ធម្មតាបណ្ឌិត បើបុគ្គលណាតូចទាបមានជីវភាពខ្សត់ខ្សោយជាងខ្លួន ទោះបីបុគ្គលនោះពោលពាក្យអាក្រក់យ៉ាងណាទៅរក ក៏ចេះអត់ធន់សង្កត់ចិត្តបានមិនរំភ័យញាប់ញ័រដោយទោសៈឡើយ ដោយមានឧត្ដមគតិថា : មនុស្សល្ងង់ច្រើនប្រើសម្ដីសប្បុរស ។

ន័យនេះសមនឹងសុភាសិតដែលសរភង្គតាបសបានពោលទុកមកថា :

**តយោ ហិ សេដ្ឋស្ស ភយេន ខមេថ សារម្ភហេតុ បន សាទិសស្ស យោ ចីធ ហីនស្ស វចោ ខមេថ ឯតំ ខន្តី ឧត្តមមាហុ សន្តោ ។**

សេចក្ដីថា : ការអត់ធន់នូវពាក្យពោលរបស់បុគ្គលដែលប្រសើរជាងខ្លួនដោយខ្លួនដោយខ្លួនដោយជាតិ និងគោត្តជាដើមព្រោះខ្លាចគេ១ ការអត់ធន់នូវពាក្យអាក្រក់របស់បុគ្គលដែលល្មើសនឹងខ្លួន ព្រោះឃើញទោសនៃកាប្រណាំងប្រជែង១ នេះមិនហៅអធិវាសនខន្តីទេ[4] ។ លុះតែបុគ្គលណាក្នុងលោកនេះ ខំអត់ធន់នូវពាក្យពោលរបស់បុគ្គលដែលថោកទាបជាងខ្លួនដោយជាតិជាដើម សប្បុរសទាំងឡាយតែងពោលសរសើរនូវការអត់ធន់នោះថា ជាខន្តីដ៏ឧត្តម ។

ខន្តីនេះព្រះសម្ពុទ្ធចាត់ឱ្យឈ្មោះថាបរមធម៌ក្នុងលោកិយ ឯព្រះនិព្វានជាបរមធម៌ក្នុងលោកុត្តរៈ ។

ខន្តីនោះ បានជាហៅបរមធម៌ក្នុងលោកិយ ព្រោះវិសេសបំផុតខាងការដុតកំដៅបាបធម៌ទាំងឡាយមាន **ទោសៈ** សេចក្ដីប្រទុស **កោធ** សេចក្ដីក្រោធ **ព្យាបាទ** ការបំផ្លាញគេឱ្យវិនាស **វិហឹសា** ការបៀតបៀនគេ **អរតិ** ការឈ្នានីសគេ **បដិឃៈ** សេចក្ដីថ្នាំងថ្នាក់ជាដើមដែលជាសាខារបស់ទោសៈដែលចម្រើនទៅបាន ក៏អាស្រ័យសេចក្ដីមិនចេះអត់ធន់ ប្រៀបដូចបុគ្គលពីរពួកដែលឈ្លោះទាស់ទែងគ្នាអំពីរឿងអ្វីមួយ បើពួកម្ខាងកំពុងតែក្រេវក្រោធតូងតាងឡើង ហើយពួកម្ខាងទៀតចេះអត់ធន់ មិនដៅឈ្មោះរបស់សំឡេងឆ្លើយតបវិញនោះ ការវិវាទគូសត្រូវតាំងសងខាង ក៏អាចមានសន្ទុះចម្រើនកើនឡើងដល់ទៅបែកបាក់សាមគ្គីគ្នានោះឡើយ ។

ខន្តីនេះមិនមែនមានគុណវិសេសចំពោះតែខ្លួនឯងទេ រមែងមានគុណវិសេសដល់បុគ្គលដទៃផង ។

ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់សរសើរថា ជាបរមធម៌ក្នុងលោកិយ ដូចមានភាសិតក្នុងគម្ពីរមហាបដ្ឋានត្រង់សរូបចតុព្វីសតិបច្ចយវារៈថា :

**ខន្តិ ហិ បរមំ លោកេ ខន្តិ លោកេ បធានតា**

**ខន្តិយា វិជ្ជមានាយ សព្វបុញ្ញញ្ច វឌ្ឍតិ ។**

[4] ការអត់ធន់ចំពោះហេតុដែលបណ្ដាលឱ្យកើតទោសៈ ហៅថាអធិវាសនខន្តី ។

សេចក្ដីថា : ខន្តីជាឧត្តមធម៌ក្នុងលោក ខន្តីធម៌ជាប្រធានក្នុងលោកកាលបើខន្តីមានហើយ បុណ្យទាំងអស់នឹងមានដោយពិត ។

បើប្រាសចាកខន្តីហើយ រមែងជួបប្រទះតែនឹងសេចក្ដីទុក្ខលំបាកក្រីក្រថោក-ទាបជានិច្ច ។

ខន្តីនេះគួរតែមានគ្រប់ពេលវេលា សូម្បីក្នុងហេតុបន្តិចបន្តួចក៏គួរតែឱ្យមាន បើមិនមានក្នុងវេលាណាមួយហើយ រមែងជួបប្រទះប៉ះទង្គិចសេចក្ដីព្រួយលំបាកអាប់អួរសិរីសួស្ដីពុំខាន ដូចមានរឿងមួយក្នុងគម្ពីរសំស្រ្កឹតដំណាល់ថា :

ក្នុងសម័យមួយ មានបុរសម្នាក់ទើបនឹងការហើយថ្មីៗ ថ្ងៃមួយបាននាំភរិយាទៅលេងផ្ទះឪពុកក្មេក ម្ដាយក្មេក លុះទៅដល់ឪពុកក្មេកម្ដាយក្មេក ក៏មានសេចក្ដីត្រេកអរនឹងកូនប្រសារនោះឥតឧបមា ឪពុកក្មេកបានរៀបចំអាសនៈឱ្យអង្គុយ ឯម្ដាយក្មេកក៏ខំទៅម្ទីម្ទា ទៅចាត់ចែងចំអិនអាហារបួនមុខដែលប្រកបដោយរស ៦ប្រការជាអាហារផ្សំដោយរសឆ្ងាញ់ផ្សេងៗ មានអាហារឈ្មោះបបួដៈជាដើម ដើម្បីឱ្យកូនប្រសារនោះបរិភោគ ។

លុះចំអិនរួចហើយក៏ដួសដោះដាច់ចានដម្កល់ស្លក លើកយកទៅឱ្យកូនប្រសារនោះបរិភោគ ។ ក្នុងពេលកូនប្រសារកំពុងតែបរិភោគម្ដាយក្មេកបានរោយលំអិតល្ងឱ្យ។ ឯកូនប្រសារនោះជាមនុស្សដែលមានសេចក្ដីខ្មាសអៀនច្រើន ក៏និយាយឃាត់ម្ដាយក្មេកថាល្មមហើយៗ ម្ដាយក្មេករោយតែបន្តិចបន្តួចក៏ដើរចេញទៅ ។ គ្រានោះកូនប្រសាបានភ្លក់មើលលំអិតល្ងដែលម្ដាយក្មេកបានរោយឱ្យ ។

ឯលំអិតល្ងមានរសឆ្ងាញ់យ៉ាងពិសេស ជាហេតុបណ្ដាលឱ្យកូនប្រសាមានចំណង់ក្នុងលំអិតល្ងនោះក្រៃពេក ប៉ុន្តែមិនអាចហ៊ានលូកដៃទៅចាប់យកលំអិតល្ងទៀតឡើយ ព្រោះជាអ្នកមានសេចក្ដីអៀនខ្មាសច្រើន ។ លុះបរិភោគរួចហើយ ក៏បានឃើញត្បាល់និងអង្រែដែលម្ដាយក្មេកបុកលំអិតល្ងនៅក្បែរជញ្ជាំង ។

ពេលនោះ សេចក្ដីចំណង់ក៏បណ្ដាលឡើងម្ដងទៀតជាខ្លាំង ព្រោះបានឃើញលម្អិតល្ងជាប់នៅក្នុងបាតត្បាល់ត្រង់កន្លែងដែលខូងៗបន្តិចៗ។

ឯកូនប្រសានោះ ជាមនុស្សគ្មានខន្តីពុំអាចអត់ទ្រាំនឹងសេចក្ដីចំណង់បានសេចក្ដីចំណង់ក៏កាន់តែបណ្ដាលខ្លាំងឡើងៗ ដរាបដល់ស្រក់ទឹកមាត់ ជួនជាវេលា

នោះជាពេលស្ងាត់ល្អ ក៏ក្រោកដើរទៅអោនក្បាលបញ្ចូលទៅក្នុងត្បាល់ដើម្បីលិទ្ធនូវលំអតិល្ង ។ ឱជារសនៃល្ងអាចបំភាន់ស្មារតីរបស់កូនប្រសារនោះ ឱ្យភ្លេចគិតពីគ្រោះថ្នាក់ផ្សេងៗ ក៏ចេះតែខំរុសក្បាលទៅក្នុងត្បាល់បន្តិចម្តងៗ លុះលិទ្ធរួចហើយ ក្បាលក៏ជាប់ណែននៅក្នុងត្បាល់នោះ ទោះបីខំរើដកយ៉ាងណាក៏ពុំអាចធ្វើក្បាលឱ្យផុតពីបាតត្បាល់បានឡើយ ។ គួរឱ្យសង្វេគណាស់ ។ កូនប្រសារនោះធ្វើដូចម្តេចទៅហ្ន៎ !

លំដាប់នោះជនទាំងឡាយមានឪពុកក្មេកជាដើម បានឃើញដូចនោះហើយ ក៏នាំគ្នាខំទាញយកកូនប្រសារអំពីត្បាល់បានមកដោយលំបាក កូនប្រសារនោះបានរួចពីត្បាល់ហើយក៏ដល់នូវសេចក្តីថោកទាប អាប់សិរីសួស្តីខ្មាសជនទាំងឡាយ មានម្តាយក្មេង ឪពុកក្មេកជាដើមនោះឥតឧបមា ។

ដែលដល់នូវហេតុដ៏ចំណែកយ៉ាងនេះ ក៏ព្រោះតែគ្មានខន្តីអត់ធន់នូវចំណង់ក្នុងលម្អិតល្ងប៉ុននោះ ។ ព្រោះហេតុនោះអស់លោកសប្បុរសទាំងឡាយ ! គួរចម្រើនខន្តីធម៌ឱ្យមានឡើងគ្រប់ៗគ្នា ។

ត្បិតខន្តីធម៌នេះបើបានស្ថិតនៅសន្តានចិត្តរបស់សត្វណាហើយ អាចទាញដួងសន្តានចិត្តសត្វនោះ ឱ្យផុតអំពីទុក្ខភាព ទៅតម្កល់លើកគំនរសុខភាពបាន ដូចមានរឿងក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់អនុស្សតិនិទ្ទេសថា : កាលដែលព្រះមានព្រះភាគ ត្រង់ប្រទានធម៌ទេសនាដល់បរិសទ្យអ្នកនៅក្នុងនគរចម្ប៉ាក្បែរមាត់ស្រះបោក្ខរណីឈ្មោះគគ្គរា: ។

គ្រានោះមានសត្វកង្កែបមួយកំពុងសំងំស្តាប់ធម៌ទេសនា ស្រាប់តែមានអ្នកគង្វាលគោម្នាក់ដើរមកឈរច្រង់ដំបងសង្កត់លើក្បាលកង្កែបនោះ ក៏អត់ទ្រាំនិងជំងឺប្រឹងតែស្តាប់ធម៌ មិនលះបង់សព្ទព្រះសទ្ធម្ម ក៏ធ្វើមរណៈកាលក្នុងខណៈនោះទៅ ទៅកើតក្នុងឋានតាវតឹង្សបានឈ្មោះថា "មណ្ឌូកទេវបុត្រ នៅក្នុងវិមានមាសកំពស់ ១២ យោជន៍ ហាក់ដូចជាភ្ញាក់ពីដេកហើយ ស្រាប់តែឃើញស្រីទេពអប្សរចោមរោមជាបរិវារ ក៏នឹកថា : យី អើ! គួរឱ្យឆ្ងល់ពេកណាស់ ហេតុអ្វី អេះ ! អញលោតែបានមកប្រតិស្ថានក្នុងទីនេះរំពឹងទៅឃើញបុញ្ញកម្មដែលខ្លួនខំអត់ទ្រាំនឹងជំងឺ ប្រឹងផ្ទង់ស្មារតីមិនឱ្យឃ្លៀងឃ្លាតពីសព្ទព្រះសទ្ធម្មទេសនារបស់ព្រះពុទ្ធ ទើបហោះចុះពីទេវលោកព្រមទាំងវិមាសមកថ្វាយបង្គំព្រះសម្ពុទ្ធបរមគ្រូ ។ គ្រានោះព្រះមានព្រះភាគទ្រង់មាន

ពុទ្ធតម្រាស់ត្រាស់សួរថា :

**កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ**

**អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា ។**

អ្នកណាហ្ន៎! មានឫទ្ធិ មានយសរុងរឿង មានរស្មីចាំងចែងញ៉ាំងទិសទាំងពួងឱ្យភ្លឺស្វាង មកសំពះ បាទាតថាគត ?

ទេវបុត្រក្រាបទូលថា :

**មណ្ឌូកោហំ បុរេ អាសឹ ឧទកេ វារិគោចរេ**

**តវ ធម្មំ សុណន្តស្ស អវធី វច្ឆបាលកោ ។**

ខ្ញុំព្រះអង្គ កាលពីដើម្បីឡើយជាសត្វកង្កែប នៅអាស្រ័យក្នុងទឹកមានវារីជាទីគោចរ កាលកំពុងស្តាប់ធម៌ព្រះអង្គ អ្នកគង្វាលគោសម្លាប់ខ្ញុំព្រះអង្គ ។

ព្រះមានព្រះភាគទ្រង់សណ្តាប់ហើយ ក៏ទ្រង់ប្រទានធម្មទេសនាសត្វទាំងឡាយបានលុះមគ្គាភិសម័យចំនួន ៨ម៉ឺន ៤ពាន់នាក់ ។

ឯទេវបុត្រនោះ បានលុះដល់សោតាបត្តិផល ក៏ហោះទៅកាន់ទេវលោកវិញ។ **សាធុរ៉ោ** ! អស់លោកសប្បុរសទាំងឡាយ ! នេះជាអានិសង្សរបស់ខន្តី បញ្ជាក់សេចក្តីថា ក្នុងពេលដែលអ្នកគង្វាលគោច្រត់ដំបងលើ បើកង្កែបពុំមានការអត់ទ្រាំបណ្តាលឱ្យជវនចិត្តស្ទុះចេញពិសព្វព្រះសទ្ធម្ម ក៏កង្កែបពុំអាចបានសម្រេចដល់ឋានៈដ៏ខ្ពង់ខ្ពស់យ៉ាងនេះដែរ ។

អស់លោកសប្បុរសទាំងឡាយ! អាត្មាភាពសម្តែងមកអំពីខន្តីប៉ុននេះនេះ ក៏ល្មមសមគួរដល់កាលវេលានិងបញ្ចប់ធម៌ទេសនា ។ តែមុននឹងបញ្ចប់អាត្មាភាពសូមលើកយក នូវព្រះរាជបុសលពិសេសនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃសម្តេចព្រះមហាកាញ្ចនកោដិ ដែលជាអតិតព្រះមហាក្សត្រខ្មែរ ព្រះអង់ទ្រង់សោយព្រះទិវង្គតទៅកាន់បរលោកហើយនោះ ក្រែងជួនជាព្រះអង្គទ្រង់បានសោយព្រះសញ្ជាតិក្នុងភពដ៏មិនសមគួរ ដោយកុសលកម្មធម្មទានក្នុងឱ្យកាសនេះ ទៅជួយស្ទួយទ្រព្រះវិញ្ញាណក្ខន្ធរបស់ព្រះអង្គដាក់ក្នុងភពដ៏ខ្ពង់ខ្ពស់ឱ្យសមតាមព្រះរាជបំណាងកុំបីខានឡើយ ។

ជាពិសេស ! ថ្វាយចំពោះសម្តេចព្រះមហាក្សត្រីយានីជាព្រះមាតាជាតិនិងជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក ព្រមទាំងសម្តេចព្រះមុខរដ្ឋ សូមព្រះអង្គទ្រង់បានប្រកប

ដោយព្រះបរមសុខក្នុងព្រះសិរីរាជសម្បត្តិ មានព្រះជន្មវស្សាទីឃាយុយឺនយូរដរាបដល់រយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ជាទីជ្រកកោននៃប្រជាពលរដ្ឋខ្មែរក្នុងព្រះរាជាណាចក្រទាំងមូល ។

នឹងថ្វាយ-ជូនចំពោះព្រះរាជវង្សានុវង្ស មន្ត្រីរាជការគ្រប់ដំណែងឋានន្តរស័ក្តិ សូមទ្រង់និងមន្ត្រីរាជការទាំងនោះ បានប្រកបដោយសុខមាលភាព និរទុក្ខ និរភ័យ មានមេត្រី ហឫទ័យ-ចិត្តចេះរួបរួមសាមគ្គីជាធ្លុងមួយ ជុំវិញព្រះរាជបល្ល័ង្កកុំបីមានចិត្តជាទេវទត្ត មាត់ជាទេវតា ជាដើម ការពារបូរណៈទឹកដីឯករាជ្យ អព្យាក្រឹត សន្តិភាពនៃប្រជាជាតិខ្មែរ ។

ម្យ៉ាងទៀតសូមជូនកុសលនៃធម្មទាននេះ ចំពោះលោកជាសាមី(ម្ចាស់បុណ្យ) ព្រមទាំងអស់លោកទាំងឡាយដែលបានអញ្ជើញមកអំពីទីជិតក្តី ឆ្ងាយក្តី ដែលបានមកជួបជុំឧបត្ថម្ភក្នុងកិច្ចបុណ្យនេះ អស់លោកខ្លះគ្មានបានទេយ្យវត្ថុពិតមែន ប៉ុន្តែបានយកកម្លាំងកាយខ្វល់ខ្វាយជួយបម្រើធ្វើជាចុងភៅ ទឹកក្តៅ ទឹកត្រជាក់ សម្រាប់ព្រះសង្ឃ និងញាតិមិត្តជាភ្ញៀវក្នុងដែលបានមកក្នុងបុណ្យនេះ ក៏ឈ្មោះថា បានបុណ្យ-កុសលដោយពិត ។ អស់លោកខ្លះទៀត មានទាំងទេយ្យវត្ថុ បានចូលជាកុសលផង ព្រមទាំងជួយខ្វល់ខ្វាយដោយកម្លាំងផង ថ្វីត្បិតតែអស់លោកដែលបានសាងបុញ្ញកម្មមានតុល្យភាពមិនស្មើគ្នាដូចនេះក៏ដោយ ក៏សូមឱ្យបានចំណែកកុសលស្មើៗគ្នានិងលោកជាម្ចាស់បុណ្យ ។

ហើយសូមឱ្យអស់លោកទាំងអស់គ្នា បានប្រកបជួបប្រទះតែនឹងសេចក្តីសុខចម្រើនគ្រប់ពេលវេលា ជាពិសេស សូមឱ្យបានសម្រេចនូវសម្បត្តិទាំង៣ប្រការគឺ : សម្បត្តិមនុស្ស១ សម្បត្តិទេវតា១ និងសម្បត្តិព្រះនិព្វាន១ ជាឋានបរមសុខឯក ជាសម្បត្តិឧត្តមថ្លៃថ្លាលើសសម្បត្តិទាំងពួងដល់សេចក្តីប្រាថ្នារបស់អស់លោកកុំបីឃ្លៀងឃ្លាតឡើយ ។

**អយំ សង្ខេបេន សម្មតា** ធម៌ទេសនាក៏សន្មតថាចប់តែប៉ុននេះ **ឯវំ** ។

★ ★ ★

# អធិប្បាយពុទ្ធភាសិត

ពរទាំងឡាយ ៥ ប្រការគឺ :

**១. អាយុ** សូមឱ្យអស់លោកមានជន្មាយុយឺនយូរ

**២. វណ្ណៈ** សូមឱ្យមានពណ៌សម្បុរកាយផូរផង់ល្អ

**៣. សុខៈ** សូមឱ្យបានសុខកាយសប្បាយចិត្ត

**៤. ពលៈ** សូមឱ្យមានកម្លាំងកាយ កម្លាំងសទ្ធា

**៥. បដិភានៈ** សូមឱ្យមានបញ្ញាស្មារតី-វៀវៃ ។

ពរទាំង ៥ប្រការនេះ វឌ្ឍន្តុ ចូរចម្រើនកើតមានដល់អស់លោកជាពុទ្ធបរិសទ្យទាំងឡាយ ដែលបានអញ្ជើញមកប្រជុំសន្និបាតក្នុងឱកាសនេះសុទ្ធតែជាអ្នកមានបំណងត្រងត្រាច់ស្តាប់ យកនូវអត្ថរសនៃព្រះសទ្ធម្ម វិសេសទេសនាហើយក៏បានអារាធនានិមន្តអាត្មាភាពឱ្យសម្តែងធម៌ទេសនា អាត្មាភាពក៏បានទទួលភារៈភ្នាក់ងារជាអ្នកសម្តែងធម៌ទេសនា ដើម្បីបដិភារៈតបស្នងឆ្លងសទ្ធារបស់អស់លោកក្នុងពេលនេះដែរ ប៉ុន្តែបើសិនជាអាត្មាភាពសម្តែងទៅហើយជួនជាមានលើសខ្វះខាតដោយបទបាថព្យញ្ជនៈ អក្ខរៈបាលី សម្តីមិនសមរម្យមិនចំតាមអធ្យាស្រ័យនិស្ស័យចិត្តថ្លើមរបស់អស់លោកនោះ ក៏សូមទន្តីអភ័យទោសដល់អាត្មាភាពដែលជាអ្នកគ្មានចេតនាបំណង នឹងពោលក្លែងមូលបង្កាច់ពុទ្ធឱវាទ ឬក៏ទិទៀនបៀបបៀនចំពោះអស់លោកនោះឡើយ សូមចម្រើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

ខ្ញុំព្រះករុណាសូមនមស្សការចំពោះព្រះអរហន្តមុនីសម្មាសម្ពុទ្ធ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្តីគោរព ។

**សព្វរាយនិវារនត្ថំ** ការធ្វើបទនមស្សការមកប៉ុណ្ណេះនេះ ដើម្បីការពាររាងរាំនូវទុក្ខទោសគ្រោះថ្នាក់ភយន្តរាយផ្សេងៗ ដែលបម្រុងចូលមកបៀបបៀនយាយីឆាឆៅ ឬកំពុងតែបានទទួលសព្វថ្ងៃនេះ សូមឱ្យបាបគ្រោះទាំងអស់នោះបររៀសជៀសចេញឆ្ងាយ ពិខន្ធសន្តាននៃអស់លោកជាពុទ្ធបរិសទ្យទាំងឡាយ ទោះបាបគ្រោះនោះមក

បៀតបៀនដោយកាយក្តី ដោយវាចាក្តី ។

**ឯតេន សច្ចវជ្ជេន វុឌ្ឍិ ហោតិ សព្វទា** ដោយសច្ចវាចា គឺវាចាដ៏ពិត ដែលបានរៀបរាប់មកប៉ុណ្ណេះនេះ សូមសិរីសួស្តីជយមង្គលសុខ-ចម្រើនគ្រប់ប្រការ កើតមានដល់អស់លោកសប្បុរសទាំងឡាយសព្វៗកាលតរៀងទៅ កុំបីមានសត្រូវណាមួយមកពារធារបៀតបៀនបានឡើយ ។

**តទនន្តរំ ធម្មទេសេស្សាមិ** បន្ទាប់បន្សំអំពីបទនមស្សការនេះទៅអាត្មាភាពនឹងលើកយក ពុទ្ធភាសិតមួយកន្លែងដែលទ្រង់សម្តែងថា "**អត្តា ហិ អត្តនោ នាថោ**" ប្រែថា ខ្លួនជាទីពឹងរបស់ខ្លួនឯង ។ គោលនៃពុទ្ធភាសិតនេះ មានសេចក្តីអធិប្បាយថា : ការពឹងពាក់ពំនាក់អាស្រ័យគ្នានឹងគ្នា ដែលទាក់ទងគ្នាក្នុងផ្លូវណាមួយ ដូចបុត្រីធីតាពឹងមានតាបិតា បាវព្រាវត្រូវពឹងចៅហ្វាយ ពលរដ្ឋត្រូវពឹងព្រះមហាក្សត្រ ញាតិមិត្តត្រូវពឹងញាតិមិត្តផងគ្នា ។ បើបុគ្គលមានអធ្យាស្រ័យទូលំទូលាយចេញទៅត្រឹមណា ក៏រមែងពឹងគ្នានឹងគ្នាបានច្រើនត្រឹមនោះ ។

ដល់មកក្នុងទីនេះ គួរនិយាយថា មិនត្រូវពឹងគេតែងម្យ៉ាងទេ ត្រូវឱ្យគេពឹងយើងវិញខ្លះ ដូចបុត្រធិតាត្រូវទីពឹងមាតាបិតាៗ ត្រូវទីពឹងបុត្រធីតាបានវិញដូចនេះជាដើម យើងពឹងលោកបានយ៉ាងណាៗ លោកពឹងយើងបានយ៉ាងនោះៗដែរ ។ លោកណាឱ្យគេពឹងពាក់មុន លោកនោះហៅថាបុព្វការី ។ អ្នកណាពឹងលោកនេះ ពេញចិត្តតបឧបការគុណឱ្យលោកបានទីពឹងខ្លួនឯងវិញ អ្នកនោះហៅថាកតញ្ញូកតវេទី ។

ធ្វើដូចនេះទើបពេញជាមនុស្សល្អព្រោះការប្រព្រឹត្តដូចនោះ ជាគ្រឿងសំគាល់នូវភាពនៃមនុស្សល្អ ។ មនុស្សគ្រប់លក្ខណៈ គ្រប់ជាតិសាសន៍ ប្រទេសនិងប្រទេសទោះបីផ្សេងៗគ្នា ក៏ត្រូវពឹងគ្នាបើមិនច្រើនក៏តិចមិនខាន ។

បើនឹងវែកញែកពាក្យថា ទីពឹងឱ្យទូលាយចេញទៅទៀតហើយក៏នឹងឃើញបានថា មិនមែនមនុស្សនឹងមនុស្សទីពឹងគ្នាប៉ុននោះទេ សូមបីក្រៅពីនោះ មនុស្សយើងនៅត្រូវទីពឹងរបស់ឯទៀតជាច្រើនហួសវិស័យនឹងពណ៌នាដូចត្រូវទីពឹង ដី - ទឹក - មេឃ - អាកាសជាដើម តែរឿននេះ មិនចាំបាច់សម្តែងទេ ព្រោះមិនត្រូវតាមបំណង ។

គោលនៃពុទ្ធភាសិតដែលបានអធិប្បាយមកនេះ រួមនៅក្នុងភាសិតថាមនុស្សនឹងទៅទោលឯកឯងតាមទំនើងមិនបាន យើងយល់ហើយ យើងមិនសង្ស័យទេ ថា

ត្រូវតែទីពឹងគ្នានឹងគ្នា បើមិនច្រើនក៏តិច ។

ហេតុនេះ ពាក្យអំនួតប្រកាន់ខ្លួនថា *"មិនត្រូវពឹងអ្នកណា មិនបាច់ទាក់ទងនឹងអ្នកណា ក៏នៅជាសុខបាន"* ត្រង់នេះត្រូវចាត់ជាពាក្យខុស ។ ដើម្បីនឹងដោះពាក្យកំហុសនោះ យើងមិនត្រូវគិត មិនត្រូវនិយាយ មិនត្រូវធ្វើកិរិយាសរសន់យ៉ាងនោះទេ គឺយើងត្រូវយល់ថា ត្រូវពឹងអ្នកដទៃ របស់ដទៃជាច្រើនតាមធម្មតានោះឯង និងគេចឱ្យផុតពីធម្មតាទៅមិនបាន បើដូចនោះ ពុទ្ធភាសិតថា "**ខ្លួនជាទីពឹងរបស់ខ្លួនឯង**" ដូចនេះនឹងទៅជាពាក្យមិនពិតវិញឬ? កាលបើត្រូវគេសួរហើយ បើឆ្លើយមិនស្រួលល្អនឹងចាត់ជាមិច្ឆាទិដ្ឋិ។ បញ្ហានេះយើងត្រូវឆ្លើយដោយសេចក្តីពិតត្រង់ភ្លាមៗថា : ការពឹងអាស្រ័-យគ្នានោះត្រូវញែកចេញជាពីរយ៉ាងគឺ :

**១**. ពឹងអ្នកដទៃ ឬរបស់ដទៃ ដែលរាប់ថាជាទីពឹងក្រៅអំពីខ្លួនយើង ។

**២**. ពឹងខ្លួនឯង សំដៅយកសេចក្តីប្រព្រឹត្តល្អរបស់ខ្លួនឯង ត្រូវគ្នានឹងពាក្យប្រៀនប្រដៅរបស់ពុទ្ធាទិបណ្ឌិតជាគោល ។

សាធុរោ ! អស់លោកសប្បុរសទាំងឡាយ! អ្នកដទៃធម្មតា ដែលយើងត្រូវទីពឹងអ្នកដទៃដូចពោលមកហើយ ឬទីពឹងខ្លួនឯងដូចពណ៌នាតទៅគឺយើងត្រូវធ្វើចិត្តឱ្យប្រាសចាកអគតិជាមុនសិន ហើយពិចារណាមើលក៏គង់ដឹងបានថា យើងពឹងអ្នកដទៃបាន ឬអ្នកដទៃដែលឱ្យយើងពឹងបាននោះ ត្រូវយើងមានសេចក្តីល្អណាមួយជាមូលហេតុដោយពិត បើមិនដូចនោះទេកុំសង្ឃឹមថានឹងទីពឹងបានឡើយ សូម្បីខ្លួនយើងវិញដូចនោះដែរគឺត្រូវពិចារណាមើលសេចក្តីល្អ ឬសេចក្តីល្អរបស់គេយ៉ាងណាមួយ បើគេប្រព្រឹត្តអាក្រក់ទុច្ចរិតមិនពោលពាក្យសត្យចំពោះយើងហើយក៏ឱ្យពឹងមិនបាន ។ ឯសេចក្តីបុគ្គលប្រព្រឹត្តអាក្រក់ហើយនឹងពឹងអ្នកដទៃ ឬរបស់ដទៃដើម្បីជៀសវាងផលអាក្រក់គឺសេចក្តីទុក្ខនោះពុំខានឡើយ សូម្បីអ្នកដទៃនោះព្យាយាមខ្លាំងក្លាជួយជីឆ្មាលឱ្យពឹងផ្អែកយ៉ាងណាក៏ដោយ សេចក្តីទុក្ខដែលជាផលនៃសេចក្តីអាក្រក់នោះ គង់កើតឡើងប្រាកដជាក់ស្តែង បើមិនឆាប់ក៏យូរពុំខានត្រូវគ្នានឹងពុទ្ធភាសិតថា "ធ្វើអាក្រក់បានអាក្រក់" ដូចស្រមោលអន្ទោលតាមប្រាណដូចនោះ នេះល្មមឃើញបានថា ដែលនឹងទីពឹងអ្នកដទៃនោះ យើងត្រូវពឹងខ្លួនយើង ពោលយើងត្រូវមានសេចក្តីល្អណាមួយជាមូលហេតុសិនហើយទើបពឹងគេបាន ការពឹងអ្នកដទៃតែម្យ៉ាងនោះរមែងប្រព្រឹត្តទៅ

មិនបានទេ ព្រោះជាការពឹងមិនឋិតថេរ តែបើទុកជាពឹងគ្នាបាន ក៏បានត្រឹមតែជាតិនេះប៉ុណ្ណោះ ។

ឯការពឹងគ្នាបានទាំងជាតិនេះនិងជាតិខាងមុខ ដល់ទីបំផុតនឹងរួចផុតចាកទុក្ខភ័យ គឺជាតិ ជរា ព្យាធិ មរណៈ បានយើងត្រូវពឹងព្រះធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្យាយាមប្រតិបត្តិតាមឱ្យបានល្អបរិសុទ្ធជាធម្មានុធម្មប្បដិបត្តិ ឯពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធនោះ មានច្រើនជាអនេកបរិយាយ តែក្នុងទីនេះនឹងពោលត្រឹមតែនាថករធម៌ ១០ប្រការគឺ : មានសីល១ ភាពពហុស្សូត្យ១ សេពគប់កល្យាណមិត្ត១ ជាបុគ្គលដែលគេប្រដៅងាយ១ ជាមនុស្សឧស្សាហ៍ព្យាយាម១ អ្នកត្រេកអរក្នុងធម៌១ ព្យាយាមដើម្បីលះបង់សេចក្តីអាក្រក់ប្រព្រឹត្តល្អ១ មានសេចក្តីសន្តោស១ មានស្មារតីភ្ញាក់រលឹក១ មានបញ្ញា១ ។ អ្នកដែលប្រព្រឹត្តធម៌១០ ប្រការនេះ នឹងពឹងអ្នកដទៃគេក៏មិនមានសេចក្តីរង្កៀស ព្រោះខ្លួនជាមនុស្សមានគុណគឺសេចក្តីល្អនៅក្នុងខ្លួនដែលជាផលនៃការព្រឹងព្រះធម៌ គឺប្រព្រឹត្តទៅតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានឈ្មោះថា ធ្វើរបស់ខ្លួនឱ្យជាទីពឹងដល់ខ្លួនឯង ។

**ខ្លួនទីពឹងខ្លួន បើពោលតាមក្បួន-ព្រះពិតៗ ថាខ្លួនធ្វើខ្លួន ឱ្យសុចរិត អ្នកផងអាណិតគេជួយថែម ។**

**សាធុរោ** ! អស់លោកសប្បុរសទាំងឡាយ ! បុគ្គលអ្នកទូន្មានខ្លួនដូចសម្តែងមកនេះ រមែងបានជាទីពឹងដ៏ល្អយ៉ាងឯក គឺព្រះនិព្វាន ដែលជាទីពឹងមិនជាជំពាក់ដោយទុក្ខទាំងពួង ជាទីពឹងដែលបុគ្គលដទៃក្រៅអំពីអ្នកដែលមានខ្លួនទូន្មានហើយនោះ បានដោយកម្រ ។

ទីពឹងដ៏ប្រសើរនេះ ឥតមានអ្នកណាមួយអាចជួយគ្នាឱ្យបានដល់ទេដែលនឹងជួយគ្នាបាន ត្រឹមតែប្រាប់ផ្លូវប៉ុណ្ណោះ ។ ឯការដើរផ្លូវតាមនោះស្រេចតែខ្លួនឯងដើរទើបបានដល់ ។

ការសម្តែងមកដល់ត្រឹមនេះ ក៏អស់លោកអាចចូលចិត្តបានថា *"ការពឹងពាក់អ្នកដទៃ សូម្បីឱ្យធ្វើតាមធម្មតាក៏មិនបាន តែជាទីពឹងមិនមាំទាំ ព្រោះធម្មតាមិនបានតាំងគោលច្បាប់ ឱ្យមនុស្សយើងពឹងពាក់គ្នាជានិច្ច ធម្មតាបាន កំណត់ផ្លូវឱ្យយើងព្រាត់ប្រាស់និរាសចាកគ្នា ហើយត្រូវស្លាប់អស់ជីវិតទៅជាទីបំផុត"* ។ ដូចនេះត្រូវខ្លួនឯង

ទូន្មានខ្លួនឱ្យតាំងនៅក្នុងគុណធម៌ គឺសេចក្ដីល្អជានិច្ច ទើបឈ្មោះថា ខ្លួនឯងជាទីពឹងខ្លួនឯងបានដោយពិត ព្រោះអាចបណ្ដុះសីល្ប៍វិទ្យា សេចក្ដីដឹងឱ្យកើតមានក្នុងខន្ធសន្ដានតាមសមគួរដល់ឋានៈ និងសេចក្ដីអង់អាច ដែលល្អមក្រសោបយកបាន ទាំងប្រព្រឹត្តខ្លួនឱ្យមាំក្នុងសេចក្ដីល្អជានិច្ចទៅ មិនព្រមឱ្យអត្តភាពរបស់ខ្លួនប្រព្រឹត្តទទេឥតប្រយោជន៍ដែលខ្លួនត្រូវបានត្រូវទៅដល់ មិនគិតតែពឹងពាក់អ្នកដទៃដែលលើសខ្លួន ឬមនុស្សដែលខ្លួនទាក់ទងដោយចំណែក១ ខំពិចារណាត្រួតត្រាភាពរបស់ខ្លួនរឿយៗថានៅខ្វះខាតដោយគុណធម៌ ចំណែកណាហើយខំបំពេញរបស់ដែលខ្វះខាតឱ្យចម្រើនល្អឡើងក្នុងខ្លួន ។ ចំណែកដែលអាក្រក់ក៏លះចេញ ចំណែកល្អក៏រក្សាទុកហើយខំព្យាយាមធ្វើឱ្យកើតមានជាលំដាប់ឡើង។ ចំណែកល្អនោះឯង នឹងបានទីពឹងពាក់របស់ខ្លួនយ៉ាងខ្ពង់ខ្ពស់ល្អលើសជាងពឹងអ្នកដទៃ ដែលមានសេចក្ដីសុខនោះទៅទៀត ។

តែមនុស្សយើងដែលគិតពឹងអ្នកដទៃ បានអាស្រ័យសេចក្ដីសុខចម្រើនដោយសារតែអ្នកដទៃ រស់រួចជីវិតរាងកាយហើយមិនគិតស្វែងរកសេចក្ដីល្អឱ្យកើតមានដល់ខ្លួន មិនគិតចិញ្ចឹមខ្លួនឯងឱ្យមានសេចក្ដីសុខ-ចម្រើនគិតតែស្រវឹងភ្លើតភ្លើនក្នុងទ្រព្យសម្បត្តិអ្នកដទៃ ។ មនុស្សខ្លះធ្វើអំពើអាក្រក់ដោយការ វាចា ចិត្ត ព្រោះហេតុតែអាស្រ័-យអ្នកដទៃជាទីតាំងដែលខ្លួនអាងថាលោកមានឫទ្ធិអំណាចតេជះ អាចជួយដោះមិនឱ្យបានទទួលផលរបស់កម្មដែលធ្វើនោះដូចនោះក៏មាន ។

មនុស្សខ្លះ ជាអ្នកទីទ័លទ្រព្យសម្បត្តិ ព្រោះសេចក្ដីប្រព្រឹត្តអាក្រក់របស់ខ្លួន ឬព្រោះកំណើតរបស់ខ្លួន ក៏ស្ទុះទៅសូមអង្វរករសូមពរដ៏ប្រសើរធ្វើផ្ដេសផ្ដាផ្សេងក៏មានធ្វើសក្ការៈបូជាក្រាបសំពះស្ថានទីផ្សេងៗក៏មាន បន់ស្រន់អង្វរករដើម្បីឱ្យព្រះជាម្ចាស់ប្រសិទ្ធិពរឱ្យបានសមតាមបំណង ឱ្យសំបូណ៌ដោយទ្រព្យ មាស ប្រាក់ កែវ កងក៏មានមនុស្សខ្លះមានសេចក្ដីប្រកាន់ខ្លួន មានទិដ្ឋិមានះរឹងត្អឹង បណ្ដោយឱ្យកិរិយាមារយាទចេញមកយ៉ាងថោកទាប រឃើករឃាកឥតសណ្ដាប់ធ្នាប់ បើកឱកាសឱ្យអ្នកដទៃដឹងបានយសរាសីសិរីរបស់គេដែលខ្លួនពឹងពាក់ពំនាក់អាស្រ័យមកគ្របដណ្ដប់ខ្លួន សម្ដែ-ងឱ្យប្រាកដត្រឹមតែហេតុដែលបានពឹងពាក់ក្នុងទីដ៏ល្អ ក្នុងសំណាក់អ្នកដ៏ខ្ពង់ខ្ពស់ក៏មាន ។

ហេតុនេះឯង បានជាព្រះដ៏មានព្រះភាគ ទ្រង់មានមហាករុណាប្រាថ្នាគុណប្រយោជន៍ឱ្យកើតមានដល់វេនេយ្យនិករ អ្នកទន់ខ្សោយដោយគំនិតប្រាជ្ញា ឱ្យដឹងច្បាស់ភ្នាក់ខ្លួន លះសេចក្ដីអាក្រក់ដែលមានក្នុងខ្លួនចេញទាំងអស់ ឱ្យអណ្ដើតខ្លួនដោយវិជ្ជការចេះដឹង និងគុណធម៌ដែលជាគ្រឿងដឹកនាំចិត្ត ទាំងឱ្យសំនួណ៌ដោយសម្បត្តិភស្តុភារ ទើបបានជាទ្រង់ត្រាស់ដាស់តឿនសតិទុកថា "**អត្តា ហិ អត្តនោ នាថោ**" ខ្លួនជាទីពឹងរបស់ខ្លួនឯង រួមសេចក្ដីឱ្យខ្លីមក ការរស់នៅក្នុងសង្គមមួយៗត្រូវធ្វើខ្លួនឱ្យរស់តាមបែបសុជីវធម៌ មានកាយវិការចរិយាសណ្ដាប់ធ្នាប់ មនោគតិ សុភាពរាបសាសុចរិត យុត្តិធម៌ ប្រាសចាកការទិទៀនជិះជាន់សង្កត់សង្កិនបៀតបៀនជនដទៃដែលទន់ខ្សោយដោយចំណេះវិជ្ជា ទ្រព្យសម្បត្តិ ជាតិត្រកូល យសស័ក្តិជាដើមនិងមិនជាអ្នកកំណាញ់ស្វិតស្វាញទ្រព្យសម្បត្តិហួសហេតុ ចំពោះជនដែលរស់នៅក្នុងសង្គមរបស់ខ្លួន ដែលគ្មានមានការខ្វះខាត ត្រូវមកពឹងពាក់លើខ្លួន ត្រូវលែលកចែកចាយតាមមានតាមបាន ព្រោះព្រឹត្តិការណ៍ជីវិតរស់នៅ តែងមានពឹងពាក់លើគ្នាទៅវិញទៅមកជៀសមិនផុត ថ្ងៃនេះគេខ្វះខាតគេពឹងយើង ថ្ងៃមុខយើងខ្វះខាតយើងពឹងគេ ។

ការរស់នៅក្នុងសង្គម មានការពឹងពាក់ក្នុងទៅវិញទៅមកដោយកម្លាំងយសស័ក្តិទ្រព្យសម្បត្តិក្ដី ឈ្មោះថាការរស់នៅប្រកបដោយសេចក្ដីសុខទូលាយទាំងសេចក្ដីសាមគ្គី ក៏មានឥទ្ធិពលខ្លាំងក្លា សត្រូវជិតឆ្ងាយខ្លបខ្លាច។ ផ្ទុយទៅវិញបើជនណាមួយរស់នៅក្នុងសង្គម ហើយមិនឱ្យជនក្នុងសង្គមខ្លួនទីពឹងផងបានទេ ជននោះដល់ខ្លួនមានអាសន្នខ្វះខាតដោយផ្លូវណាមួយ មិនអាចទៅទីពឹងជនដទៃវិញបានឡើយ នេះចំពោះបញ្ហាជីវិតរបស់នៅក្នុងលោកបច្ចុប្បន្នគឺខ្លួនធ្វើខ្លួនឱ្យល្អ ទើងខ្លួនទីពឹងអ្នកដទៃវិញបាន ។

ចំពោះបញ្ហាជីវិតទៅបរលោកវិញ ក៏ត្រូវតែទីពឹងខ្លួនឯងទើបបាន ។

មុននឹងបញ្ចប់ធម៌ទេសនា អាត្មាភាពសុំលើកយករឿងកាលដែលព្រះកើតជាមឃមាណពមានប្រពន្ធបួននាក់ គឺនាងសុធម្មា១ នាងសុនន្ទា១ នាងសុចិត្តា១ នាងសុជាតា១ ក្នុងព្រឹត្តិការណ៍ជីវិតរបស់ព្រះឥន្ទ កាលដែលកើតជាមឃមាណពនេះ ព្រះឥន្ទបានបំពេញវត្តបទ ៧ប្រការគឺ ការបម្រើមាតាបិតា១ សេចក្ដីប្រព្រឹត្តកោតក្រែងដល់បុគ្គលជាធំក្នុងត្រកូល១ វាចាទៀតទាត់១ វាចាទន់ភ្លន់១ វាចាមិនញុះញង់១ ការ

នាំបង់នូវសេចក្តីកំណាញ់១ សេចក្តីមិនក្រោធ១ បណ្តាវត្តបទទាំង ៧ប្រការនេះ ព្រះឥន្ទបានបំពេញយ៉ាងបរិបូណ៌គ្រប់ពេលវេលា មានការដឹកនាំជនដទៃឱ្យបំពេញសេចក្តីល្អ មានធ្វើផ្លូវថ្នល់ដាំដើមឈើ ធ្វើសាលាជាដើម ហើយប្រពន្ធទី១ ទី២ ទី៣ ប្រពន្ធទី១គឺនាង សុធម្មា ត្រូវគំនិតគ្នានឹងជាងឈើ បានធ្វើហោជាងមួយដាក់សាលា មានចារិកអក្សរថា "**នេះសាលាសុធម្មា**" ប្រពន្ធទី២ គឺនាងសុនន្ទា នាងបានជីកស្រះបោក្ខរណីមួយនៅប្របសាលានោះ មានឈ្មោះប្រាកដថា "**សុនន្ទាបោក្ខរណី**" ឯនាងសុចិន្តាប្រពន្ធទី៣ បានធ្វើសួនផ្កាមួយជារមណីស្ថានជាទីគួររីករាយបុប្ផាផលទាំងឡាយមានគ្រប់គ្រាន់ មានឈ្មោះប្រាកដថា "**សុចិត្តលតាវ័ន**" សម្រាប់មហាជនកំសាន្តចិត្ត ។

ប្រពន្ធទី១ ទី២ ទី៣នេះគេបានបំពេញសេចក្តីល្អទាមទារយកចំណែកបុណ្យគ្រប់ៗគ្នា ឯប្រពន្ធទី៤ គឺនាងសុជាតា ឥតបានធ្វើអ្វីនឹងគេឡើយ បែរជាគិតថា អញចាំបាច់ធ្វើអ្វីទៀត ព្រោះអញជាធីតារបស់ឪពុកធំមឃមាណពហើយ ហើយជាប្រពន្ធរបស់មឃមាណពនេះស្រាប់គាត់ធ្វើអ្វី ឈ្មោះថាអញបានធ្វើដែរហើយ ក៏គិតតែពីស្អិតស្អាងរាងកាយប៉ុននោះ ។

បណ្តាជនទាំងអស់នេះ លុះដល់ទំលុះកាយទំលាយខន្ធទៅកាន់លោកខាងមុខ មឃមាណព បានទៅកើតជាស្តេចទេវតា ព្រះនាម សក្កៈ នៅពិភពតាវតឹង្ស ។ ឯមាណពជាសម្លាញ់ទាំងនោះ ក៏បានទៅកើតក្នុងពិភពតាវតឹង្សនោះដែរ។ ជាឈើបានទៅកើតជាវិស្សកម្មទេវបុត្រ ។ ឯនាងសុធម្មាធ្វើមរណកាលទៅ បានទៅកើតក្នុងឋានតាវតឹង្សនោះដែរ នាងមានទេវសភាសាលាសម្រាប់ប្រជុំទេវតា១ ឈ្មោះសាលាសុធម្មា ទំហំ ៥០០យោជន៍ ឥតមានទីណាដទៃជាទីគួររីករាយជាងទេវសភានោះឡើយ ។

ឯនាងសុនន្ទា ធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងឋានតាវតឹង្ស នាងមានស្រះបោក្ខរណី១ ឈ្មោះសុនន្ទាបោក្ខរណី ទំហំ ៥០០យោជន៍។

ឯនាងសុចិត្តា ធ្វើមរណកាលទៅ ក៏បានទៅកើតក្នុងឋានតាវតឹង្សនោះដែរ នាងមានសួនច្បារមួយឈ្មោះ សុចិត្តលតាវ័ន ទំហំ ៥០០យោជន៍ ។

ចំណែកខាងនាងសុជាតា ដែលមិនបានធ្វើអ្វីនឹងគេសោះនោះ ដល់ធ្វើមរណកាលទៅ បានទៅកើតជាមេកុកមួយយ៉ាងសំគម នៅក្នុងច្រកភ្នំមួយ លុះព្រះឥន្ទ

ពិចារណាមើលទៅ ឃើញថានាងសុជាតាបានកើតជាកុកនៅក្នុងច្រកភ្នំដូចនេះ ក៏ព្រះអង្គចុះមកបង្គាប់ឱ្យរក្សាសីល៥ ហើយដល់ស្លាប់ទៅ បានទៅកើតជាកូនស្រីនាយស្មូនឆ្នាំង ព្រះឥន្ទទ្រង់ទៅណែនាំឱ្យរក្សាសីលទៀតស្លាប់ទៅ បានទៅកើតជាព្រះរាជធីតាព្រះបាទវេបចិត្រាសូរឈ្មោះនាងសុជាតានៅនាអសុពិភព ទើបទ្រង់ទៅនាំមកដំកល់ទុកជាអគ្គមហេសី ក្នុងដំណែងជាធំជាងពួងស្រីអប្សរចំនួនពីរកោដិកន្លះឯឋានតាវតឹង្សសួគ៌នាយ ។

**សាធុរោ** ! អស់លោកសប្បុរសទាំងឡាយ ! អាត្មាភាពលើកយករឿងនេះមកសម្ដែងមកសង្ខេបប៉ុននេះ ដើម្បីបញ្ជាក់ឱ្យឃើញថា កាលដែលព្រះឥន្ទកើតជាមាណព មានប្រពន្ធបួននាក់ បណ្ដាប្រពន្ធទាំងបី នាងខ្លះបានចូលកសាងសាលា នាងខ្លះបានដាំសួនច្បារ នាងមួយទៀតបានជីកស្រះ លុះដល់ស្លាប់ទៅបានទៅកើតនៅឋានតាវតឹង្ស សោយសុខក្នុងទេវសម្បត្តិអស់ទៅ ។ ចំណែកនាងសុជាតា ដែលមិនបានធ្វើកុសលអ្វីនឹងគេសោះ ដែលផ្អែកចិត្តគំនិតទៅពឹងលើប្ដី ដល់ស្លាប់ទៅៗកើតជាមេកុកនៅច្រកភ្នំ ហើយពេលក្រោយមកបើកុំតែនាងកាន់សីល រៀរតាមសិក្ខាបទនៃសីល ដែលព្រះឥន្ទបង្គាប់ឱ្យរក្សានោះទេ ម្ល៉េះក៏មិនមែនមកកើតជាកូននាយស្មូនឆ្នាំងរហូតដល់មកកើតជាព្រះរាជាធីតានៃព្រះបាទវេបចិត្រាសូរ ឈ្មោះនាងសុជាតាអសុរពិភពនោះដែរ ម្យ៉ាងទៀតបើទុកជាព្រះឥន្ទទ្រង់ទៅជួយដូចនោះ ហើយនាងមិនដុសខាត់ចិត្តធ្វើខ្លួនឱ្យជាប់សីលផងទេនេះ ព្រះឥន្ទក៏មិនអាចជួយបានដែរ ម្ល៉េះប្រហែលជានៅកើតតែមេកុកសំគមនៅសំកុកចាំអង្វះច្រកភ្នំដែលឥតត្រីនោះឯង។ ត្រង់នេះត្រូវនឹងពាក្យដែលបានពោលទុកខាងដើមហើយថា : "ខ្លួនត្រូវទីពឹងខ្លួន បើពោលតាមក្បួនព្រះពិតៗ ថាខ្លួនធ្វើខ្លួនសុចរិត អ្នកផងអាណិតគេជួយថែម" ។

អស់លោកទាំងឡាយ! កុំបាច់និយាយត្រឹមព្រះឥន្ទ សូម្បព្រះសម្ពុទ្ធបរមគ្រូ ក៏មិនអាចជួយយើងបានដែរ បើយើងមិនធ្វើខ្លួនយើងឱ្យល្អផង ។

ដូចព្រះអង្គទ្រង់ប្រទានឱ្យវាទថា :

**តុម្ហេហិ កិច្ចមាតប្បំ អក្ខាតារោ តថាគតា**

ប្រែថា ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ប៉ុននោះ ឯកិច្ចការព្យាយាមត្រូវអ្នករាល់គ្នាធ្វើខ្លួនឯង ។

អត្តា ហិ អត្តនោ នាថោ ប្រែថាខ្លួនជាទីពឹងរបស់ខ្លួនឯងមកប៉ុននេះនេះ ក៏ល្មមសមកាលវេលានឹងបញ្ចប់ធម៌ទេសនា។ តែមុននឹងបញ្ចប់ អាត្មាភាពសូមលើកយកកុសលដ៏ពិសេសនេះ ឧទ្ទិសថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូងព្រះមាតាជាតិ ជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក និងជាដង្ហើមរស់នៅប្រជាពលរដ្ឋខ្មែរទាំងព្រះរាជាណាចក្រកម្ពុជា និងថ្វាយចំពោះសម្តេចព្រះឧបយុវរាជ ជាអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមនៃប្រទេសកម្ពុជាសូមសម្តេចទាំងពីរព្រះអង្គ ព្រមទាំងព្រះរាជវង្សានុវង្ស ទ្រង់ប្រកបដោយសុភមង្គលវិបុលសុខគ្រប់ប្រការ ទ្រង់មានតែជានុភាពឈ្នះអស់មារសត្រូវគ្រប់ទិសទី និងមានមហិទ្ធិឫទ្ធិចេស្តាបារមីភ្លៀវក្លាវៀងវៃ ដោយព្រះប្រាជ្ញាញាណក៏មុះមុតដូចពេជ្រពណ្ណរាយ និងទ្រង់ប្រកបដោយជោគជ័យដ៏ឆ្នើមគ្រប់ព្រះរាជទស្សនៈកិច្ចជាផ្លូវការលើឆាកអន្តរជាតិ និងក្នុងពិភពលោកទាំងមូល ។

ម្យ៉ាងទៀត សូមឧទ្ទិសកុសលនេះមួយចំណែកជូនរដ្ឋសភា-រដ្ឋាភិបាលនិងនាហ្មឺនសព្វមុខមន្ត្រីគ្រប់ដំណែងឋានន្តរៈស័ក្តិ តាំងពីទាហានប៉ូលិស ប្លុងតុង យោក្ប័-ដ្ឋ បាល័ដ្ឋ ស្មៀនស្មេរ ឯកឧត្តមធំតូច ទោះបីនៅស្រុកស្រែ-ចំការផ្សារដីក្រុង ក្នុងក្រៅលំនៅជន រាជធានី ទីខេត្តខ័ណ្ឌ ព្រមទាំងប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ បានប្រកបជួបប្រទះតែសេចក្តីសុខ-ចម្រើនគ្រប់នាទី តាំងពីបច្ចុប្បន្នកាលរៀងទៅអានគត សូមឱ្យមានសុទិដ្ឋិនិយមយល់ស្របគ្នាជាឆ្លុងមួយ ស្ថិតនៅក្រោមព្រះរាជោវាទ ដង្ហែតាមក្រោយអង្គសម្តេចព្រះឧបយុវរាជ ជាអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមរបស់ខ្មែរ កាន់ដៃគ្នាយ៉ាងញញឹមក្លាហានបោះជំហានធ្វើដំណើរឆ្ពោះទៅកាន់វឌ្ឍនភាពអារ្យភាព ដូចខ្មែរក្នុងសម័យអង្គរវត្តកុំបីឃ្លាតក្លាយបែកបាក់គ្នាឡើយ ។

សូមឱ្យសព្វសត្វទាំងពួង កុំបីមានពៀរវេរានឹងគ្នា និរទុក្ខ-និរភ័យសូមប្រកបតែសុខក្សេមក្សាន្ត បានរលត់ទុក្ខគ្រប់កាលទាំងពួង ។

ការសម្តែងធម៌ទេសនាមកប៉ុណ្ណោះនេះ ក៏ល្មមសមកាលវេលា **ឯវំ** ។

★ ★ ★

# បុណ្យធម្មទាន

ខ្ញុំព្រះករុណា សូមនមស្សការចំពោះព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ព្រោះថា ចាប់ដើមតាំងពី ព្រះអង្គបានត្រាស់ដឹងបរិមាភិសេកសម្ពោធិញ្ញាណមកកាលណាហើយ ព្រះអង្គតែងមានព្រះទ័យពោរពេញទៅដោយមហាករុណាទិគុណអាណិតអាសូរដល់សព្វសត្តនិករទាំងអស់ ម៉្លោះហើយបានជាព្រះអង្គខំប្រឹងប្រែងយកព្រះទ័យទុកដាក់ក្នុងការសម្តែងធម៌ទេសនាទាំងយប់ទាំងថ្ងៃ ឥតមានសម្រាកព្រះអង្គមួយវេលារាត្រីណាសោះ ដរាបដល់ ៤៥ព្រះវស្សាគត់ សូម្បីតែព្រះអង្គរៀបយាងចូលទៅកាន់បរមនិព្វាន ក៏ខំប្រតិស្ថានសាសនារបស់ព្រះអង្គទុកឱ្យបាន ៥០០០ព្រះវស្សាទៀត ដើម្បីជាប្រយោជន៍ដល់សត្វសត្តនិករទាំងអស់ក្នុងត្រៃភព ។

ម្យ៉ាងទៀតខ្ញុំព្រះករុណា សូមមនស្សការចំពោះនិយ្យានិកធម៌ ដែលជាធម៌ស្រោចស្រង់សត្វ រឹសសោះអន្ទងដឹកនាំពាំយួរគៀរគរប្រមូលបញ្ចូលចិត្តរបស់សត្វឱ្យនាំបែរមុខឈមត្រង់ទៅរក មជ្ឈិមាបដិបទា គឺផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឆ្វេងមិនស្តាំ ឬ **ឧជុចមគ្គោ** និយ្យានិកធម៌ដែលជាធម៌ដឹកនាំសត្វឱ្យធ្លាក់ចុះទៅក្នុងផ្លូវត្រង់ ឆ្ពោះទៅរកសេចក្តីសុខចម្រើនក្នុងលោកបច្ចុប្បន្ននិងបរលោក ។

ម្យ៉ាងទៀតខ្ញុំព្រះករុណា សូមមនស្សការចំពោះព្រះសង្ឃទាំងពីរប្រការគឺសម្មតិសង្ឃ និងអរិយសង្ឃដែលលោកមានសីលដ៏បរិសុទ្ធ អាចរក្សានូវអានេសនៈ២១ និងបាប៥យ៉ាង សង្ឃទាំងពីរពួកនេះហើយដែលជាបុញ្ញខេត្តគឺជាស្រែបុណ្យ មានជីវជាតិដ៏ល្អស្អាត សត្តនិករទាំងអស់បាននាំគ្នាយកពូជធារពោលគឺបច្ច័យបួន មានចីវរប្បច្ច័យជាដើម យកទៅសាបព្រោះអាចដុះដាលលូតលាស់ផ្លែផ្កាសម្រេចតាមសេចក្តីប្រាថ្នារបស់ម្ចាស់ទានទៅបាន ។

ការរៀបរាប់នមស្សការមកប៉ុននេះសម្មតថាចប់ សព្វន្តរាយនិវារនត្ថំ ការធ្វើនមស្សការមកប៉ុននោះនេះដើម្បីការពាររារាំងនូវទុក្ខទោសគ្រោះថ្នាក់ ឬភយន្តរាយផ្សេងៗ ដែលធ្លាប់មានដល់អាត្មាភាពនិងពុទ្ធបរិសទ្យតាំងពីយូរណាស់ហើយក្តី ឬចង្រៃឧបទ្រពកាឡកណ្ណីអពមង្គលណាមួយ ដែលបម្រុងនឹងចូលមករុករានទន្ទ្រានបៀតបៀនយាយីក្នុងគ្រាឥឡូវនេះក្តី សូមឱ្យបាបគ្រោះទាំងអស់នោះ បររៀសជៀស

ចេញឆ្ងាយពិខន្ធសន្តាននៃយើងទាំងឡាយ **ឯតេន សច្ចវច្ចេន វុឌ្ឍិហោតុ សព្វទា** ដោយសច្ចវាចា គឺវាចាដ៏ពិតដែលបានរៀបរាប់មកនេះ សូមសិរីសួស្តីជ័យមង្គលសុខចម្រើនគ្រប់ប្រការកើតមានដល់ពុទ្ធបរិសទ្យទាំងឡាយឱ្យបានសព្វៗ កាលតរៀងទៅកុំបីមានឧបសគ្គណាមួយមកបៀតបៀនជិតដាមជាប់ដល់សិរីរាវយវៈ របស់អស់លោកឡើយ ។

"**តទនន្តរំ ធម្មំ ទេសេស្សាមិ** បន្ទាប់បន្សំអំពីបទនមស្សការនេះទៅអាត្មាភាពនឹងលើកយកធម៌មកសម្តែង ត្រដាងលាតចែកជូនដល់អស់លោកអ្នកដើម្បីតបស្នងឆ្លងសទ្ធា និងបានជាវត្តប្រតិបត្តិខាត់សន្តានចិត្តនៃអស់លោកឱ្យបង្វិលទ្រនិចនៃការយល់ធ្លាក់ចុះក្នុងនាទី គឺមគ្គផលតាមបែបពុទ្ធសាសនា ។ ឯធម៌ដែលបម្រុងសម្តែងក្នុងឱកាសនេះ គឺសម្តែងអំពីបុណ្យធម្មទា តែជាដំបូងនេះ អាត្មាភាពសុំញែកវែកពាក្យថា "បុណ្យ" ជូនអស់លោកជាខាងដើមសិន : ពាក្យថា បុណ្យៗនេះ ជាភសាសំស្រ្កឹត ភាសាបាលីថា **បុញ្ញ** បើភាសាខ្មែរថា "ពេញ" ឬថា ធម្មជាតិឯណាដែលស្អាតបរិសុទ្ធផូរផង់ប្រាសចាកមន្ទិល គឺសេចក្តីសៅហ្មង សមដូចបទពិគ្រោះដែលលោកចងទុកក្នុងគម្ពីរ **អភិធានប្បទីបិកាសូចិ** ថា : **សន្តានំ បុនាតិ សោធេតីតិ** > បុញ្ញំ ប្រែថា កុសលធម៌ឯណាដែលជម្រះសន្តានចិត្តឱ្យស្អាតបរិសុទ្ធបាន កុសលធម៌នោះឈ្មោះថា "បុណ្យ" ដូចនេះ ។

ន័យមួយទៀត បុណ្យនេះ លោកសម្តែងយកសេចក្តីសុខ ចម្រើនរីករាយ ដែលត្រូវបានដល់អ្នកធ្វើ ដូចមានពុទ្ធភាសិតសម្តែងទុកក្នុងគម្ពីរអង្គុត្តរនិកាយសត្តនិបាតថា "**មា ភិក្ខវេ បុញ្ញានំ ភយិត្ថ សុខស្សេតំ ភិក្ខវេ អធិវចនំ យទិទំ បុញ្ញានំ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យដែលហៅថា បុណ្យនេះ មិនគឺជាឈ្មោះនៃសេចក្តីសុខ សេចក្តីសុខនោះសោតក៏ជាឈ្មោះរបស់បុណ្យ" ដូចនេះ ។

ពុទ្ធភាសិតនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ទេសនាថា បើបុរសស្ត្រីណាមួយបានធ្វើបុណ្យ ត្រូវខំធ្វើបុណ្យនោះឱ្យរឿយៗ គឺទ្រង់ដាស់តឿនពុទ្ធបរិសទ្យឱ្យប្រឹងធ្វើបុណ្យដែលជាហេតុ គឺធម្មជាតិជម្រះសន្តានចិត្តឱ្យប្រាសចាកសេចក្តីលោភ សេចក្តីខឹង-វង្វេង ឱ្យញឹកញយដើម្បីយកបុណ្យដែលជាផល គឺសេចក្តីសុខចម្រើនន៑ុះឯង ព្រោះអ្នកដែលបានធ្វើចិត្តឱ្យប្រាសចាកអកុសលធម៌បីយ៉ាងខាងដើមនោះ ទើបបាន

ឈ្មោះថា "អ្នកមានចិត្តជាបុណ្យ" ។ ក៏ធម្មតាអ្នកមានចិត្តជាបុណ្យនុ៎ះឯង តែធ្វើបុញ្ញកិរិយាវត្ថុទាំងឡាយ មានទានសីលភាវនា ជាដើមបានដោយងាយ អំពើដែលធ្វើទានសីលភាវនាហ្នឹងហើយលោកហៅថា "ធ្វើបុណ្យ" បុណ្យនេះហើយដែលជាហេតុផ្តួចផ្តើមឱ្យកើតទៅរកកម្រៃផង គឺសេចក្តីសុខសប្បាយដោយយសស័ក្តិសម្បត្តិបរិវារអាយុយឺនយូរ និងសតិបញ្ញាវៀងវៃ ឱ្យបានជាផលក្នុងជាតិនេះ និងជាតិខាងមុខ ។

សាធុរ៉ា ! អស់លោកសប្បុរសទាំងឡាយ! ហើយហេតុដែលកើតជាបុណ្យនោះមាន ៣យ៉ាងគឺ :

**១. បសាទោ** មានចិត្តជ្រះថ្លា

**២. សង្វេគោ** មានចិត្តតក់ស្លុត

**៣. តេសុចរិតា** មានសេចក្តីស្អាតដោយកាយវាចាចិត្ត ។

ជាពិសេស! អ្នកធ្វើបុណ្យតែងបានអានិសង្ស ៥យ៉ាងគឺ :

**១. តិក្ខបញ្ញាវិសារទា** មានប្រាជ្ញាភ្លៀវក្លាមុះមុត

**២. សុវណ្ណត្តា** មានរូបល្អ

**៣. សុរូបតា** មានរូបល្អ

**៤. សុសណ្ឋានា** មានទ្រង់ទ្រាយល្អ

**៥. ចក្កវត្តិរាជាហោតិ** នឹងបានទៅជាស្តេចចក្រពត្តិក្នុងជាតិណាមួយពុំខានឡើយ ។

ការញែកវែកពាក្យថា "បុណ្យ" មកដោយសង្ខេបប៉ុណ្ណេះ ក៏ល្មមអស់លោកស្តាប់បាន។ លំដាប់តទៅនេះ សូមលើកយកពាក្យថា **ធម្មទាន**សម្តែង ចែកជូនសណ្តាប់តទៅទៀត :

ពាក្យថា **ធម្មទាន** ប្រែថា: "ការឱ្យទានធម៌ដល់អ្នកដទៃ" ការបង្ហាត់បង្រៀនពន្យល់ធម៌ក្តី ស្តាប់ធម៌ក្តី ឱ្យសៀវភៅតម្រាក្បួនច្បាប់សម្រាប់អានសិក្សាក្តី ការព្យាយ-មសរសេរតែជាក្បួនច្បាប់សម្រាប់សិក្សាក្តីឈ្មោះថា : "ធម្មទាន" ដូចសម្តែងថា ធម៌នេះជាកុសល ធម៌នេះប្រកបដោយក្តីទុក្ខ-វិនាស ធម៌នេះប្រកបដោយសេចក្តីសុខ-ចម្រើនជាដើម ឬសម្តែងប្រាប់អំពីកម្ម និងផលរបស់កម្ម ពន្យល់ចង្អុលបង្ហាញឱ្យបានឃើញច្បាស់ដើម្បីដឹកនាំទស្សនិកជនទាំងនោះឱ្យងាករេបែរចេញពីអកុសលធម៌

ហើយឱ្យតាំងចិត្តស៊ុបនៅក្នុងកុសលវិញ ដូចនេះហៅថា **លោកិយធម្មទាន** ។

ការសម្តែងប្រាប់នូវសច្ចៈធម៌បួនប្រការ ដល់អ្នកដទៃថាធម៌នេះ បុគ្គលគួរកំណត់ដឹងគឺ (**ទុក្ខសច្ចៈ**) ធម៌នេះបុគ្គលគួរលះបង់គឺ (**សមុទយសច្ចៈ**) ធម៌នេះបុគ្គលគួរធ្វើឱ្យជាក់ច្បាស់គឺ (**និរោសច្ចៈ**) ធម៌នេះបុគ្គលគួរចម្រើនគឺ (**មគ្គសច្ចៈ**) ប៉ុណ្ណេះជាដើម ហៅថាធម្មទាន ជាកំពូលនៃទានទាំងពួង ហៅថាសិប្បត្តធម្មទាន ឬលោកុត្តរធម្មទាន ក៏បាន ។

ធម្មទាន បើប្រៀបនឹងអាមិសទាន ធម្មទានមានផលប្រសើរខ្ពង់ខ្ពស់ជាង ព្រោះការសម្តែងទូទៅដល់បុគ្គលដទៃក្តី ការពន្យល់អំពីគុណទោសខុសត្រូវ ក្នុងផ្លូវលោកផ្លូវធម៌ចំពោះបុគ្គលម្នាក់ៗក្តីចំពោះពួកគណៈមួយក្តីឈ្មោះថាបានប្រគល់នូវ ចំណេះវិជ្ជាស្មារតីដ៏ធំទូលំទូលាយដល់បុគ្គលដទៃ តួយ៉ាងដូចបុគ្គលដែលបានទទួលភោគសម្បត្តិ ដំណែងឋានន្តរស័ក្តិណាមួយក្តី សុទ្ធតែបានមកអំពីការរៀនសូត្រស្តាប់ទាំងអស់ ឬថាមានការស្តាប់នេះឯងជាមូលហេតុ ។ ការសិក្សាត្រងត្រាប់ស្តាប់យកនូវឧបាយនេះរាប់ថាជាមេគំនិតមួយឬជាដើមពូជនៃប្រយោជន៍ ព្រោះថាបុគ្គលដែលបានសម្រេចមគ្គផលនិព្វានជាគុណវិសេសដ៏ខ្ពស់បំផុតនោះ ព្រោះអាស្រ័យការស្តាប់នេះជាបច្ច័យ ធម្មទានជាលោកិយ ជាឫសគល់នៃទានទាំងពួង ទាននេះឈ្នះអស់ទានទាំងពួងសមនឹងពុទ្ធភាសិតដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំពោះសក្កៈទេវរាជថា :

**សព្វទានំ ធម្មទានំ ជិនាតិ**
**សព្វរសំ ធម្មរសោ ជិនាតិ**
**សព្វរតឹ ធម្មរតិ ជិនាតិ**
**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ។

ប្រែថា ធម្មទានឈ្នះអស់ទានទាំងពួង ធម្មរសឈ្នះអស់រសទាំងពួងសេចក្តីត្រេកអរក្នុងធម៌ឈ្នះអស់សេចក្តីត្រេកអរទាំងពួង ការអស់ទៅនៃតណ្ហាឈ្នះអស់ទុក្ខទាំងពួង ។

## <u>អធិប្បាយថា</u>

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានរមែងឈ្នះអស់ទានទាំងពួង បណ្តាទានទាំង

ឡាយក្នុងពុទ្ធសាសនា មានតែធម្មទានមួយទេ ដែលជាទានផលានិសង្សខ្ពង់ខ្ពស់បំផុតជាងទានទាំងអស់ ដោយហេតុថា ជាប្រធានឬថាជាជីវិតនៃអាមិសទាន ។ ធម្មទានជាអាយុនៃពុទ្ធសាសនា អាចលើកស្ទួយពុទ្ធសាសនាឱ្យមានពន្លឺរស្មីរុងរឿងឋិតថេរដរាបទៅ ឧបមាដូចជាបុគ្គលឱ្យទានចីវរដែលមានសាច់ម៉ដ្ឋល្អដ៏ពិសេសដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពសូម្បីគង់នៅត្រៀបត្រាតតចន្លោះក្នុងផ្ទៃនៃចក្រវាឡដរាបដល់ព្រហ្មលោក តែនៅក្នុងទីប្រជុំនោះ មានធម្មថិកអង្គណាមួយធ្វើអនុមោទនាដោយគាថា៤បាទ គង់ប្រសើរជាងចីវរទាននោះទៅទៀត ឯចីវរទានមិនបានមួយចំណិតនៃគាថានោះ ដែលគេបែងឱ្យជា ១៦ចំណិតអស់វារៈ ១៦ដងទៀត ដោយចំណិតចុងបំផុត ចំណែកបិណ្ឌបាត្រទានក្តី សេនាសនទានក្តី គិលានភេសជ្ជៈទានក៏មានន័យដូចនេះដែរ ។

ព្រោះហេតុនោះ ការសម្តែងធម៌ក្តី ការបង្រៀនធម៌ក្តី ការស្តាប់ធម៌ក្តីជាគុណជាតិប្រសើរយ៉ាងនេះឯង ។

ដោយហោចទៅគ្រាន់តែបុគ្គលធ្វើមនុមោទនាដោយគាថា ៤បាទប៉ុននោះ ឃើញថាប្រសើរជាងឱ្យចង្ហាន់បិណ្ឌបាត្រ ដ៏ឧត្តមដាក់ពេញក្នុងបាត្រហើយប្រគេនដល់អរិយបុគ្គល មានព្រះពុទ្ធជាដើមផង ជាងគិលានភេសជ្ជៈមានសប្បិជាដើម ដែលបុគ្គលដាក់ពេញក្នុងបាត្រ ហើយប្រគេនដល់អរិយបុគ្គល មានព្រះពុទ្ធជាដើមផង ជាងសេនាសនៈទានដែលបុគ្គលសាងវិហារឬលោហប្រាសាទរាប់សែន មិនតែមួយឱ្យដល់អរិយបុគ្គល មានព្រះពុទ្ធជាដើមផង ព្រោះហេតុអ្វី? ព្រោះថាបុគ្គលនេះលៃលកធ្វើបុណ្យទាន មានសភាពដូចនោះកើត លុះតែបានស្តាប់ពាក្យប្រៀនប្រដៅជាមុនហើយទើបធ្វើ បើមិនបានស្តាប់ធម៌សោះទេ ក៏មិនអាចធ្វើអ្វីបានឡើយ ។

សត្វទាំងឡាយបើមិនបានស្តាប់ធម៌ហើយ សូម្បីតែវត្ថុអ្វីបន្តិចបន្តួចក៏មិនអាចធ្វើទៅជាទានបានឡើយ ។

ព្រោះហេតុនោះធម្មទានទើបបានឈ្មោះថា មានផលប្រសើរខ្ពង់ខ្ពស់ជាងអាមិសទានដូចនេះឯង ។

**សព្វរសំ ធម្មរសោ ជិនាតិ** ធម្មរសរមែងឈ្នះនូវរសទាំងពួង រសទាំងអស់ក្នុងលោក មានរសភោជនាហារម្ហូបចំណី បង្អែម ទឹកឃ្មុំ ឬរសសុធាភោជននៃទេតាទាំង

ឡាយ រសទាំងអស់នោះគ្រាន់តែជាបច្ច័យសម្រាប់សោយនូវទុក្ខក្នុងវដ្តសង្សារប៉ុននោះ ចំណែកខាងរសគឺពោធិបក្ខិយធម៌ ៣៧ប្រការនិងលោកុត្តធម៌ ៩ជារសប្រសើរក្រៃលែងជាងរសទាំងពួង ហេតុដូចនេះទើបព្រះមានព្រះភាគទ្រង់សម្តែងថា: **សព្វរសំ ធម្មរសោ ជិនាតិ** ដូចនេះឯង ។

**សព្វរតឹ ធម្មរតិ ជិនាតិ** សេចក្តីត្រេកអរក្នុងធម៌ ឈ្នះអស់សេចក្តីត្រេកអរទាំងពួង ការត្រេកអរក្នុងទ្រព្យសម្បត្តិផ្ទះសំបែងនិងបុត្រធីតា ភរិយា ស្វាមី ស្រ្តី-ល្បែង-របាំរាំច្រៀងជាដើមនេះ គ្រាន់តែជាបច្ច័យសម្រាប់សោយនូវទុកក្នុងវដ្តសង្សារ។ ចំណែកត្រេកអរក្នុងធម៌ញុំាងចិត្តឱ្យរីករាយ ធ្វើនៅទីបំផុតនៃសង្សារវដ្ត មានអរហត្តផលជាទីបំផុត ។ ត្រេកអរក្នុងធម៌នេះប្រសើរក្រៃលែងជាងត្រេកអរលើកវត្ថុអ្វីៗទាំងពួង ព្រោះហេតុដូចនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា : **សព្វរតឹ ធម្មរតិ ជិនាតិ** ដូចនេះឯង ។

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ការអស់ទៅនៃតណ្ហាឈ្នះអស់ទុក្ខទាំងពួង ចំណែ-កអស់ទៅនៃវត្ថុទាំងពួងក្នុងលោក សត្វរមែងសោកទុក្ខ។ ការអស់ទៅនៃតណ្ហានេះគឺអស់សមុទយសច្ចៈដែលជាទីប្រជុំឱ្យកើតកងទុក្ខទាំង ១២រមែងបាននូវសេចក្តីសុខដ៏លើសលប់ក្រៃលែងទៅទៀត បានជាព្រះមានព្រះភាគទ្រង់សម្តែងថា **តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ដូចនេះ ។ អ្នកឱ្យធម្មទានឈ្មោះថា ឱ្យព្រះនិព្វាន សមនឹងពុទ្ធភាសិតថា : **អមតន្ទោ ច សោ ហោតិ យោ ធម្មនុសាសតិ** បុគ្គលណាប្រៀនប្រដៅធម៌ឬសម្តែងធម៌ បុគ្គលនោះឈ្មោះថា ជាអ្នកឱ្យនូវអមតមហានិព្វាន សត្វដែលបានសម្រេចតាំងពីសោតាបត្តិមគ្គ ដរាបដល់អរហត្តផល ជាទីបំផុតបានដោយសារការស្តាប់ធម៌ទាំងអស់ មិនមែនសត្វណាកំពុងធ្វើអាមិសទាន កំពុងរក្សាសីល បានសម្រេចមគ្គផលនោះទេ លុះតែបានស្តាប់នូវធម៌ក្តី ភាវនានូវធម៌ក្តី ទើបសម្រេចមគ្គផលបាន ។

ចំណែកអាមិសទាន បានអានិស្សតែចំណែកខាងអ្នកឱ្យ ឯធម្មទានបានអានិស-ស្សទាំងពីរចំណែក អ្នកសម្តែងក៏បានអានិសង្ស ៥យ៉ាង អ្នកស្តាប់ក៏បានអានិសង្ស ៥យ៉ាង ។

<u>អានិសង្សអ្នកសម្តែង ៥យ៉ាងនោះគឺ:</u>

**១. អត្ថប្បដិសំវេទី ធម្មប្បដិសំវេទី** លោកអ្នកសម្តែងដោយផ្ចិតផ្ចង់ តាមអង្គនៃ

ធម្មកថិកចំពោះព្រះសទ្ធម្ម នឹងរីងរិតតែជាអ្នកយល់ធ្លុះធ្លាយក្នុងអត្ថ និងធម៌យ៉ាងក្រៃលែងទៅទៀត ។

**២. បាមោជ្ជំ** សេចក្តីរីករាយក្នុងអត្ថ និងធម៌ រមែងកើតឡើងគឺធម៌ទេសនានោះក៏ពីរោះចាប់ចិត្តខ្លួនឯង និងបុគ្គលអ្នកស្តាប់តាមលំដាប់នៃធម៌ដែលកើតឡើង ។

**៣. បីតិ** សេចក្តីត្រេកអរមានកម្លាំងឆ្អែតចិត្តក្នុងធម៌នោះៗក៏កើតឡើង

**៤. បស្សទ្ធិ** រូបកាយនិងនាមកាយរបស់លោកអ្នកសម្តែង និងអ្នកស្តាប់ក៏ស្ងប់រំងាប់ចាកអកុសលផ្សេង ដរាបដល់ចិត្តសង្វេគតក់ស្លុតក្នុងសង្ខារទាំងឡាយ ។

**៥. សមាធិ** ចិត្តរបស់លោកដែលកំពុងសម្តែងធម៌ ក៏តាំងមាំក្នុងការស្ងាត់ចាកនីវរណៈ ។

អានិសង្សទាំង ៥យ៉ាងនេះ ជាសន្ទិដ្ឋិកផល គឺផលគប្បីឃើញច្បាស់ក្នុងបច្ចុប្ប-ន្នក៏មាន ជាសម្បរាយិកផល គឺផលត្រូវបានទៅបរលោកក៏មាន។

ចំណែកអ្នកស្តាប់ក៏ត្រូវបានអានិសង្ស ៥យ៉ាងគឺៈ

**១. អស្សុតំ សុណាតិ** អ្នកស្តាប់រមែងបាននូវធម៌ដែលមិនធ្លាប់បានស្តាប់

**២. សុតំ សុណាតិ** អ្នកស្តាប់ធម៌ រមែងបានស្តាប់នូវធម៌ដែលធ្លាប់បានស្តាប់រឿយៗ ។

**៣. កង្ខំ វិមាសតិ** នឹងបានកំចាត់ចង់នូវសេចក្តីសង្ស័យ។

**៤. ទិដ្ឋឹ ឧជុំ ករោតិ** អ្នកស្តាប់ធម៌នឹងធ្វើនូវទិដ្ឋិឱ្យត្រង់ឡើង។

**៥. ចិត្តមស្ស បសីទតិ** អ្នកស្តាប់ធម៌នឹងញុំាងចិត្តឱ្យរីងរិតតែជ្រះថ្លាឡើង អានិ-សង្ស ៥យ៉ាងនេះ ជាផលគួរបានក្នុងបច្ចុប្បន្នក៏មាន ជាសម្បរាយិកផល គឺផលគួរបានក្នុងបរលោកក៏មាន ។

សាធុរោ! អស់លោកសប្បុរសទាំងឡាយ! អាត្មាភាពសម្តែងមកអំពីធម្មទាប៉ុណ្ណោះ ក៏ល្មមសមកាលវេលានឹងបញ្ចប់ធម៌ទេសនា តែមុននឹងបញ្ចប់សូមលើកយកនូវបុញ្ញរាសី គឺគំនរនៃបុណ្យក្នុងឱកាសនេះ ឧទ្ទិសជូនចំពោះបុព្វការីជនរបស់អស់លោកទាំងឡាយ ដែលធ្វើមរណកាលទៅកាន់បរលោកខាងមុខហើយ ក្រែងលោកទាំងនោះ ភ្លាំងភ្លាត់សតិអារម្មណ៍បានទៅចាប់កំណើតកើតក្នុងទីថោកទាបពុំសមតាមបំណង **ឥមិនា បុញ្ញតេជេន** ដោយតេជៈនៃបុណ្យកុសលក្នុងពេលនេះ សូមអណ្តែត

ត្រសែតទៅជួយសួយទ្រសណ្តោងយិតយោងនូវ ដួងវិញ្ញាណក្ខន្ធនៃលោកទាំងនោះ ដាក់នៅក្នុងទីដ៏ខ្ពង់ខ្ពស់ជាភេយ្យោភាព ហើយសូមឱ្យបានប្រកបតែសេចក្តីសុខចម្រើនរៀងទៅ ។

ម្យ៉ាងទៀតសូមជូនកុសលមួយផ្នែក ចំពោះលោកជាសាមីម្ចាស់បុណ្យព្រមទាំងអស់លោកដែលបានអញ្ជើញមកពីទីជិតទីឆ្ងាយ ចូលស្តាប់មគ្គផលយកកុសលក្នុងឱកាសនេះ សូមឱ្យបានចំណែកបុណ្យស្មើៗភាគគ្នា ហើយសូមឱ្យបានប្រកបជួបប្រទះតែនឹងសេចក្តីចម្រើនគ្រប់ប្រការ កុំបីមានឧបសគ្គណាមួយមកបៀតបៀនឆាឆៅដល់សិរីរាវយវៈនៃក្រុមគ្រួសាររបស់អស់លោកឡើយហើយសូមឱ្យ បានសម្រេចនូវសម្បត្តិទាំងបីប្រការគឺ សម្បត្តិមនុស្ស១ សម្បត្តិទេព្តា១ សម្បត្តិព្រះនិព្វាន១ តាមសមគួរដល់សេចក្តីប្រាថ្នានៃអស់លោកទាំងនោះៗចុះ។ ការសម្តែងមកអំពីធម្មទាន ក៏ល្មមសមកាលវេលា **ឯវំ** ។

(ក្នុងប្រជុំបុញ្ញប្រវត្តិ)

★ ★ ★

# ជីវិតរបស់មនុស្សមានប្រយោជន៍ឬទេ?

ក្នុងវត្តិសម័យនេះ អាត្មាភាពត្រូវនាទីជាធម្មកថិកាចារ្យមួយរូបដែលត្រូវលើកយកធម៌ណាមួយតាមសមគួរ ដល់សតិបញ្ញា និងពេលវេលាមកសម្តែងបញ្ជាក់ចែកជូនអស់លោកអ្នកជាពុទ្ធបរិសទ្យទាំងឡាយ ។

មុននេះសូមជូនពរទាំងឡាយ ៤ប្រការគឺ :

**១. អាយុ** សូមឱ្យមានជន្មាយុយឺនយូរ

**២. វណ្ណៈ** សូមឱ្យមានពណ៌សម្បុរកាយរូបឆោមល្អ

**៣. សុខៈ** សូមឱ្យបានសុខកាយសប្បាយចិត្ត

**៤. ពលៈ** សូមឱ្យមានកម្លាំងកាយកម្លាំងសទ្ធា ។

ពរទាំង ៤ប្រការនេះ វឌ្ឍន្តុ ចូរចម្រើនកើតមានដល់បណ្តាអស់លោកជាពុទ្ធបរិសទ្យទាំងឡាយ ដែលបានអញ្ជើញមកជួបជុំសន្និបាតក្នុងឱកាសនេះសុទ្ធតែអារាធនានិមន្តអាត្មាភាពឱ្យជាអ្នកសម្តែងធម៌ទេសនា។

អាត្មាភាពក៏ទទួលភារៈភ្នាក់ងារជាអ្នកសម្តែងធម៌ទេសនា ដើម្បីជាបដិការៈ តបស្នងឆ្លងសទ្ធារបស់អស់លោកក្នុងឱកាសនេះដែរ ក៏ប៉ុន្តែបើប្រសិនជាអាត្មាភាពសម្តែងទៅហើយ ជួនជាមានបើលើសលោះខ្វះខាត ដោយបទបាថព្រះបាលី សេចក្តីអធិប្បាយ ស្រាយត្រង់កន្លែងណាមួយពុំសមរម្យតាមអធ្យាស្រ័យនិស្ស័យចិត្តថ្លើមអស់លោកឬភ្លាំងភ្លាត់ខុសចាកពីពុទ្ធឱវាទ ដែលមិនមានចេតនារម្មណ៍ និងពោលភ្លែងនោះ ក៏សូមអស់លោកជាពុទ្ធបរិសទ្យទាំងឡាយខន្តីអភ័យទោសានុទោសនោះដល់ អាត្មាភាព នឹងបានសម្តែងទៅតាមសតិបញ្ញាស្មារតី សូមចម្រើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

ខ្ញុំព្រះករុណាសូមនមស្សការចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយគោរព ។

**សារេន សារទំ ហន្ទ ទិហិតា ទិហិតា មយា**

**វន្ទនា វន្ទនា មាន តាជនេ រតនត្តយេ ។**

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណាបានធ្វើឱ្យប្រកបដោយសេចក្តីគោរព

ក្នុងប្រជុំបីនៃរតនៈ មានព្រះពុទ្ធជាដើម ដែលជាភាជន៍គួរតែបុគ្គលថ្វាយបង្គំបូជាដោយទ្វារទាំងបី មានកាយទ្វាជាដើម កិរិយាថ្វាយបង្គំនុ៎ះឯង ជាអំពើដ៏វិសេស ព្រោះញុំាងសម្បត្តិជាលោកិយ លោកុត្តរៈ ឱ្យសម្រេចបាន សូមញុំាងសេចក្តីក្រវល់ក្រវាយ ដែលប្រព្រឹត្តទៅក្នុងកាយនិងចិត្តនៃខ្ញុំព្រះករុណាឱ្យវិនាសបាត់បង់ទៅ ។

**តទនន្តរំ ធម្មទេសស្សាមី** លំដាប់តពីបទនមស្សការនេះទៅអាត្មាភាពសុំលើកយកពាក្យថា "ជីវិតរបស់មនុស្ស តើមានប្រយោជន៍ឬទេ?" មកសម្តែងបញ្ជាក់ជូនអស់លោកដូចតទៅនេះ :

បញ្ហានេះអាត្មាភាព សូមអធិប្បាយទំលាយសេចក្តីអោយងាយស្តាប់ថា ជីវិតគឺការរស់នៅរបស់មនុស្សនោះ មានប្រយោជន៍ក៏មាន ឥតប្រយោជន៍សោះក៏មាន។ ជីវិតរបស់មនុស្សដែលមានប្រយោជន៍នោះ គឺមនុស្សណាមួយដែលកំពុងរស់នៅក្នុងលោកបច្ចុប្បន្ន បើផ្នែកខាងបព្វជិត (អ្នកបួសក្នុងព្រះពុទ្ធសាសនា) អ្នកបួសនោះ បានបំពេញការសិក្សាក្បួនច្បាប់ខាងព្រះពុទ្ធសាសនាចេះដឹងហើយ បានប្រតិបត្តិតាមការចេះដឹង ព្រមទាំងបាមបំពេញមុខការតាមឋានៈរបស់បុព្វជិក ទាំងកិច្ចការណាដែលទាក់ទងដល់ផ្លូវលោក កុំឱ្យតែផ្ទុយនឹងច្បាប់ព្រះពុទ្ធសាសនា ហើយបានបំពេញកិច្ចការនោះឱ្យសមតាមវិជ្ជាចេះដឹង និងសមត្ថភាពរបស់ខ្លួន ដើម្បីឱ្យមានប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង ដល់ប្រទេសជាតិផង ដល់ខ្លួន និងសាធារណៈជនផងមិនប្រព្រឹត្តខ្ជិលច្រអូស ធ្វើខ្លួនឱ្យសមជាបព្វជិតល្មមទីពឹងខ្លួនឯងបាន ទាំងជនដទៃក៏អាចចូលមកទីពឹងពុំនាក់បានផង ។

បើជាគ្រហស្ថវិញ គ្រហស្ថនោះមានចិត្តប្រកបដោយសប្បុរសធម៌មានប្រាជ្ញាស្គាល់ការខុសត្រូវ ហើយប្រព្រឹត្តមិនឱ្យឆ្គាំឆ្គងនឹងច្បាប់ផ្លូវលោក ផ្លូវធម៌ ព្រមបានបំពេញប្រយោជន៍ដល់ប្រទេសជាត ដល់សាសនា ដល់ខ្លួនគ្រួសារនិងដល់សាធារៈណៈជនដោយកម្លាំងកាយ វាចា ចិត្ត និងកម្លាំងទ្រព្យ។ ជីវិតរបស់មនុស្សទាំងនោះទោះជាបព្វជិតក្តី គ្រហស្ថក្តី ឈ្មោះថាជីវិតរស់នៅមានប្រយោជន៍ក្នុងពេលដែលខ្លួនរស់នៅ ជននោះលុះដល់បញ្ជូនវិញ្ញាណក្ខន្ធទៅកាន់បរលោកនាយ កិច្ចការដែលខ្លួនធ្វើជាប្រយោជន៍ទាំងប៉ុន្មាន អាចជូនផលដល់ខ្លួនឯងឱ្យបានសុខទៅលោកខាងមុខផង កិច្ចការដែលសល់នៅសម្រាប់ធ្វើឱ្យកើតប្រយោជន៍ដល់ជនឯក្រោយទៀតផង

ជនដែលធ្វើអំពើល្អក្នុងពេលដែលខ្លួនមានជីវិតរស់នៅទាំងនោះ ឈ្មោះថា ជាជីវិតរស់នៅប្រកបដោយប្រយោជន៍ ។

ជីវិតរបស់មនុស្សដែលរស់នៅឥតប្រយោជន៍សោះនោះ គឺមនុស្សណាមួយដែលកំពុងរសនៅក្នុងលោកបច្ចុប្បន្ន បើជាបព្វជិតក្នុងសាសនា បព្វជិតនោះមិនយកចិត្តទុកដាក់ក្នុងការសិក្សា ឱ្យបានចេះដឹងនូវច្បាប់ព្រះពុទ្ធសាសនា មិនយកចិត្តទុកដាក់ក្នុងការប្រតិបត្តិ តាមច្បាប់ដែលបព្វជិតត្រូវកាន់បែរជាយកចិត្តទុកដាក់ ចំពោះការដែលទាស់ខុសនឹងច្បាប់ព្រះពុទ្ធសាសនាទៅវិញ ឥតបានបំពេញមុខការណាមួយដែលមានប្រយោជន៍ដល់ព្រះពុទ្ធសាសនាដល់ខ្លួន ដល់ជនឯទៀត ឬដល់ប្រទេសជាតិរបស់ខ្លួន តាមទំនងដែលបព្វជិតត្រូវធ្វើបាននោះសោះឡើយ ផ្ទុយទៅវិញត្រលប់ជាធ្វើបាបខ្លួនឱ្យជាបុគ្គលម្នាក់ សម្រាប់ជំទាស់ ឬស្ទាក់ដំណើរការដែលនាំឱ្យចម្រើនដល់ព្រះពុទ្ធសាសនានិងប្រទេសជាតិ មិនតែប៉ុណ្ណោះឡើយ ថែមទាំងធ្វើខ្លួនឱ្យឃ្លាតចាកផលប្រយោជន៍ក្នុងលោកបច្ចុប្បន្ន និងបរលោកទៀត ការប្រព្រឹត្តបែបនេះ បើជាគ្រហស្ថវិញ គ្រហស្ថនោះជាមនុស្សប្រាសចាកសតិបញ្ញាមានការប្រហែសភ្លេចខ្លួនជានិច្ច ពេញចិត្តធ្វើតែអំពើលាមកអាក្រក់មានអបាយមុខ និងបញ្ចវេរាជាដើម ជាអំពើនាំឱ្យខ្លួនវិនាសក្នុងលោកទាំងពីរឥតបានបំពេញផលប្រយោជន៍អ្វីមួយដល់ប្រទេសជាតិដល់សាសនា ដល់ខ្លួនដល់ជនទូទៅ ។

ជីវិតរបស់ជនទាំងនោះ បើទុកជាកម្លាំងមាន ទ្រព្យមាន ក៏មិនយកកម្លាំង និងទ្រព្យនោះទៅធ្វើឱ្យកើតជាប្រយោជន៍សម្រាប់ខ្លួន សម្រាប់ស្រុកឬសម្រាប់សាធារណៈជណសោះឡើយ លុះដល់ជីវិតបាត់បង់ទៅ អ្វីដែលខ្លួនមានក្នុងការរស់នៅ ក៏ទៅជាមួយខ្លួនទាំងអស់ គ្មានបានបញ្ចេញផលល្អទុកឱ្យសល់នៅជាប្រយោជន៍វែងឆ្ងាយសោះឡើយ ជីវិតរបស់ជនទាំងនោះ ទោះជាបព្វជិតក្តី គ្រហស្ថក្តី ជាជីវិតរស់នៅឥតប្រយោជន៍ទេ ព្រោះថាកាលខ្លួនមានជីវិតរស់នៅនោះ មិនបានធ្វើអ្វីដែលមានប្រយោជន៍ដល់ជាតិដល់សាសនាដល់ខ្លួន និងជណទូទៅបន្តិចសោះ យ៉ាងនេះហៅថា ជីវិតនៃជនរស់នៅឥតប្រយោជន៍ ។

**សាធុរោ** ! អស់លោសប្បុរសទាំងឡាយ ! យើងដែលបានកើតមកជាមនុស្សហើយ បានឋិតនៅក្នុងទីឋានដែលមានច្បាប់ព្រះពុទ្ធសាសនា ព្រមទាំងមានច្បាប់

សម្រាប់ប្រទេសបរិបូណ៌ទៀត គួរតែកុំបណ្តែតបណ្តោយប្រហែលសធ្វេសភ្លេចខ្លួនឱ្យសោះ គប្បីតាំងសតិសម្បជញ្ញៈឱ្យខ្ជាប់ខ្ជួនក្នុងខ្លួនជានិច្ចហើយប្រើមធ្យោបាយពិចារណារកហេតុផលឱ្យឃើញសព្វទាន់ខ្លួនមានជីវិតរស់នៅ ខំប្រឹងលះបង់ការខុសប្រកាន់យកត្រូវ លះអំពើអយុត្តិធម៌ ធ្វើអំពើយុត្តិធម៌ លះបង់ទោសយកគុណហើយត្រូវមានវិរយភាពប្រកបកាតព្វកិច្ចទាំងឡាយ ដែលនាំឱ្យមានប្រយោជន៍ក្នុងលោកបច្ចុប្បន្ននិងបរលោកកុំសំចៃកម្លាំងឡើយ។

ដូចនេះ ជនម្នាក់ៗដែលមានខ្លួនជាទីស្រឡាញ់ គួរកុំបណ្តោយខ្លួនឱ្យជាមនុស្សខ្ជិលច្រអូសឥតការងារអ្វី ជាហេតុនាំនូវសេចក្តីថោកទាបដល់ខ្លួនសមដូចពាក្យថា : រដ្ឋគ្មានអាករ មនុស្សគ្មានរបរ មិនរុងរឿងឡើយ ។ កន្លែងដទៃទៀតមានសំនួររបស់អ្នកប្រាជ្ញបរទេសខ្លះថា : អ្នកស្រឡាញ់ជីវិតអ្នកឬ? គេអាចឆ្លើយថា : បើដូច្នោះ អ្នកបណ្តោយឱ្យវេលាកន្លងទៅទទេៗ ព្រោះវេលាជារបស់សន្សំធ្វើឱ្យមានជីវិត ធ្វើជីវិតឱ្យថ្លៃថ្នូរ ។

ពាក្យថា កុំបណ្តោយឱ្យវេលាកន្លងទៅទទេៗ នោះ ខាងផ្លូវពុទ្ធសាសនាយើងក៏មាននិយាយមកហើយថា : "**អតិបត្តិ វយោ ខណោ តថេវ**" វ័យរមែងកន្លងផុតទៅ ដូចយ៉ាងខណៈ "សេចក្តីថា : កាលណាវ័យកន្លងទៅវ័យរបស់យើងក៏កន្លងទៅជាមួយរាល់ៗថ្ងៃ រាល់ៗនាទីគ្មានសម្រាក យើងក៏កាន់ឈានចូលទៅជិតសេចក្តីស្លាប់។ ខណៈ ឬវេលាដែលកន្លងហួសពីព្រំដែនទៅហើយ យើងមិនអាចហៅឱ្យត្រឡប់មកវិញបាន វ័យរបស់យើងដែលឆ្លងផុតទៅហើយ ក៏មិនអាចនឹងហៅឱ្យត្រឡប់មកទៀតបានដូចគ្នា" ។

**កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា** កាលវេលារមែងទំពាស៊ីនូវសព្វសត្វព្រមជាមួយនឹងខ្លួនរបស់វា យើងត្រូវសាងផលប្រយោជន៍ល្អទុកសម្រាប់ខ្លួន កុំឱ្យវេលាស៊ីប្រយោជន៍របស់យើងទៅទទេៗ ។

**ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា អច្ចេន្តិ** ប្រយោជន៍រមែងហួសយុវជនអ្នកបោះបង់ការងារ សេចក្តីថាជនដែលចូលចិត្តថាខ្លួនមានវ័យនៅក្មេង ចូលចិត្តថាមានវេលានៅច្រើនទៀត បណ្តោយឱ្យវេលាកន្លងទៅ គុណប្រយោជន៍រមែងកន្លងទៅជាមួយផង ព្រោះវេលានោះឯងជាតួគុណប្រយោជន៍។

អស់លោកជាពុទ្ធសាសន៍ទាំងឡាយ! ជីវិតដែលមិនមានប្រយោជន៍នោះគឺស្លាប់មុនដល់វេលាស្លាប់ ដូចនេះគ្រប់វេលាដែលយើងមានជីវិតរស់នៅនោះសូមឱ្យយើងរស់នៅយ៉ាងមនុស្ស ដែលចេះប្រើវេលាឱ្យជាប្រយោជន៍មិនមែនរស់នៅយ៉ាងមនុស្សស្លាប់ គឺមានជីវិតរស់នៅដោយមានប្រយោជន៍អ្វី ។

ពិតណាស់អស់លោក! នៅក្នុងលោកយើងនេះ ! គេអាចពិសោធន៍ឃើញជាក់ច្បាស់ថា : មានតែមនុស្សស្មុះស្មារប្រឹងប្រែង ពេញចិត្តធ្វើការប្រើវេលាឱ្យជាប្រយោ-ជន៍ប៉ុននោះទេ ដែលអាចនឹងទ្រាំទ្រជាមួយជីវិតបាន។ ចំណែកជនដែលមិនធ្វើការអ្វីរង់ចាំតែលាភបានមកស្រាប់ៗនោះ និងមានផ្លូវបានលាភខ្លះៗតែក្នុងរឿងព្រេងប៉ុននោះឯង ចំពោះបញ្ហាជីវិតពិតប្រាកដនោះមិនអាចនឹងសង្ឃឹមថា ជួបលាភជោគបានឡើយ ។

សមនឹងភាសិតថា *"កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប គួរប្រឹងគប់សេពសិល្ប៍វិជ្ជា កុំបណ្តោយតាមយថាកម្មា កុំចាំព្រេងវាសនា លើកបាយបញ្ចុក"*។

សាធុរោ ! អស់លោកសប្បុរសទាំងឡាយ ! អាត្មាសុំបំបែរសតិអារម្មណ៍អស់លោកងាកមកជួយពិចារណានូវទ្រឹស្តីនៃពុទ្ធភាសិតម្តង ព្រះសក្យមុនីគោត្តមបរមគ្រូនៃយើង ព្រះអង្គទ្រង់ត្រាស់ដឹងនូវបញ្ហាជីវិតយ៉ាងទូលំទូលាយសុះសព្វគ្មានចន្លោះ ហើ-យព្រះអង្គទ្រង់ត្រាស់សម្តែងពន្យល់ដល់សត្វលោក ឱ្យបានយល់ច្បាស់នូវបញ្ហាជីវិតដូចមានជាអាទិថា :

**អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ អប្បមត្តា ន មិយ្យន្តិ យេ បមត្តា យថា មតា** ប្រែថា "សេចក្តីមិនធ្វេសប្រហែសជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីធ្វេសប្រហែស ជាផ្លូវនៃសេចក្តីស្លាប់ ជនដែលមិនធ្វេសប្រហែស ជាជនមិនស្លាប់ ជនដែលមានសេចក្តីធ្វេសប្រហែស ទុកណាជាមានជីវិតនៅ ក៏ដូចជាស្លាប់ទៅហើយដែរ" ។

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ ឯកាហំ ជីវិតំ សេយ្យោ វិរិយំ អារព្ភ-តោ ទឡ្ហំ** ប្រែថា "ជនណាខ្ជិលច្រអូសមិនមានសេចក្តីព្យាយាមរស់នៅអស់មួយរយឆ្នាំការរស់នៅជននោះពុំប្រសើរស្មើនឹងការរស់នៅ ត្រឹមតែមួយថ្ងៃនៃជនដែលមានសេចក្តីព្យាយាមមាំមួន" ពុទ្ធភាសិតនេះ សសេចក្តីឱ្យឃើញថា ជនដែលរស់នៅអស់មួយរយឆ្នាំតែពុំបានធ្វើអ្វីឱ្យជាប្រយោជន៍ដល់ខ្លួន ដល់គ្រួសារ ដល់ប្រទេសជាតិរបស់ខ្លួនជា

មនុស្សបណ្តោយខ្លួនឱ្យសេចក្តីខ្ជិលច្រអូសសង្កត់ ជាជនមានជីវភាពទន់ខ្សោយ ការរស់នៅដូចនេះពុំប្រសើរសោះឡើយ ។

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ** ប្រែថា "ជនណាទ្រុស្តសីល មានខ្លួនមិនដំកល់នៅក្នុងសីលធម៌រស់នៅអស់មួយរយឆ្នាំ ការរស់នៅជននោះ ពុំប្រសើរស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃនៃជនដែលមានសីល មានខ្លួនតាំងនៅក្នុងសីលធម៌" ពុទ្ធភាសិតនេះមានន័យថាអ្នកមានជីវិតរស់នៅមួយរយឆ្នាំដោយមិនមានសីល មិនមានចរិយាមារយាទថ្លៃថ្នូរមានធម៌រឹបជាន់បៀតបៀនមនុស្សជាតិដូចគ្នា ដោយប្រើកម្លាំងណាមួយមានកម្លាំងយសស័ក្តិ និងកម្លាំងទ្រព្យជាដើម ការរស់នៅដូចនេះពុំប្រសើរសោះឡើយ ។

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ** ប្រែថា "ជនណាមិនមានបញ្ញា មានខ្លួនប្រាណចាកសេចក្តីចេះដឹងរស់នៅអស់មួយរយឆ្នាំការរស់នៅនៃជននោះ ពុំប្រសើរស្មើនឹងការរស់នៅត្រឹមតែមួយថ្ងៃនៃជនដែលមានបញ្ញា មានខ្លួនដំកល់នៅក្នុងសេចក្តីចេះដឹង" ។

ពុទ្ធភាសិតនេះដៅឱ្យឃើញថា : អ្នកមានជីវិតរស់នៅអស់កាលយូរតែពុំបានសិក្សាចំណេះវិជ្ជានានា ពុំបានដឹកនាំខ្លួនទៅរកសេចក្តីចេះដឹងគ្រប់កម្មវិធីទាំងអស់ មានការចូលកាន់សមាគមបណ្ឌិតអ្នកប្រាជ្ញជាដើម ជីវិតរស់នៅប្រាសចាកបញ្ញាដូចនេះ ជាជីវិតខ្សោយបំផុត បើរស់នៅយូរទៅ កាន់តែចោកទាបណាស់ កាន់តែជំទាស់ដល់សង្គមមនុស្សដែលគេត្រូវរៀបចំ និងនាំឱ្យទទឹងទាស់សេចក្តីចម្រើនដែលសាសនានិងជាតត្រូវការ ។

ដូចនេះជនម្នាក់ៗ គប្បីខំប្រឹងបំពេញកិច្ចការទាំងឡាយដែលមានផលប្រយោជន៍ បូជាដល់ជាតិ-សាសនាដល់ខ្លួន គ្រួសាររបស់ខ្លួន និងជនទូទៅគ្រប់ពេលវេលា កុំបើកឱ្យវេលាកន្លងទៅទទេៗ ព្រោះពេលវេលាអាចទុកគុណប្រយោជន៍ គុណសម្បត្តិក្នុងលោកនេះ និងលោកខាងមុខ ឯពេលវេលានោះគឺក្នុងវេលាដែលយើងកំពុងរស់នៅនេះឯង ដែលហៅថា ជីវិតៗបើជីវិតអស់វេលាណា វេលានោះឈ្មោះថាស្លាប់ បើសេចក្តីស្លាប់មកដល់ខណៈណាខណៈនោះក៏ឈ្មោះថាពេលវេលាអស់ហើយ។

**សាធុរោ!** អស់លោកសប្បុរសទាំងឡាយ! បើយើងស្រឡាញ់ជីវិតចង់រស់នៅឱ្យបានសុខស្រួលប្រកបដោយសេចក្ដីថ្លៃថ្នូរគ្រប់គ្នានោះ គួរធ្វើជីវិតដែលជាទីស្រឡាញ់ពេញចិត្តកុំឱ្យជីវិតរស់នៅធ្ងន់ដីឥតប្រយោជន៍ គួរធ្វើជីវិតរបស់ខ្លួនឱ្យមានប្រយោជន៍ពិតៗ ។

ឱ្យសមនឹងពាក្យថា :

ការមានប្រយោជន៍គួរខំធ្វើ វិជ្ជាចេះស្ទើរគួរបំពេញ អកុសលមានៅគួរលះចេញ ជួញមានចំនេញគួរខំជួញ។

យ៉ាងនេះ ទើបសេចក្ដីសុខ-ចម្រើននឹងសុភមង្គលចូលមកប្រតិស្ថានលើខ្លួន និងគ្រួសាររបស់ខ្លួនសមតាមបំណងពុំខានឡើយ ។

ការសម្ដែងមកអំពី "ជីវិតរបស់មនុស្ស មានប្រយោជន៍ឬទេ?" ក៏ល្មមសមតាមកាលវេលានឹងបញ្ចប់ធម៌ទេសនា ! តែមុននឹងបញ្ចប់អាត្មាភាពសូមលើកយកកុសលដែលកើតអំពីធម្មទានដ៏ពិសេសនេះ ថ្វាយចំពោះសម្ដេច**ព្រះមហាក្សត្រិយានីកុសុមៈនារីរត្នន៍ សិរីវឌ្ឍនា** ជាម្ចាស់ជីវិត សូមទ្រង់ប្រកបដោយព្រះបរមសុខក្នុងសិរីរាជសម្បត្តិ មានព្រះជន្មវស្សាទីឃាយុយឺនយូរជាងរយព្រះវស្សា និងថ្វាយពំពោះសម្ដេចព្រះប្រមុខរដ្ឋជាអគ្គមគ្គុទ្ទេសន៍ដ៏ឆ្នើមរបស់ខ្មែរ ព្រមទាំងព្រះរាជវង្សានុវង្ស សូមព្រះអង្គទ្រង់ប្រកបដោយព្រះជោគជ័យគ្រប់វិស័យក្នុងការកសាងជាតិ ព្រះកិត្តិសព្ទលេចឮរន្ទឺខ្ទរខ្ទារពេញផ្ទៃពិភពលោក សត្រូវគ្រប់ទិសទីខ្លបខ្លាចចេស្ដាបារមី ។ មន្ត្រីអ្នករាជការគ្រប់ដំណែងឋានន្តរស័ក្ដិ សូមបានសមប្រកបជួបប្រទះតែនឹងសេចក្ដីសុខ-ចម្រើនគ្រប់ប្រការម្យ៉ាងទៀតសូមជូននូវចំណែកភាគផលក្នុងឱកាសនេះ ដល់លោកជាសាមីដើមបុណ្យ និងអស់លោកជាបរិវារបុណ្យ ដែលបានអញ្ជើញមកចូលចាប់កុសលតាមកម្លាំងសទ្ធា ទោះតិចក្ដី ច្រើនក្ដីក្នុងឱកាសនេះ សូមលោកទាំងនុ៎ះបានកុសលផលបុណ្យស្មើៗភាគគ្នា ហើយសូមឱ្យបានប្រកបបានសេចក្ដីសុខក្សេមក្សាន្តរកទទួលទានមានបានលូតលាស់ដុះដាលកើតកាលវាលគុម្ពត្រជាក់ត្រជុំសំបូណ៌ ដោយមាសប្រាក់កែវ កង ចិញ្ចៀនត្បូងពិទូរ សូរ្យកាន្ត ចារកន្ទ្រំ ពេជ្រ និល រទេះស្រឡីក្របីគោ មាន់ទាស្រែចំការច្បារដំណាំ នៅទឹកមានទូកនៅគោកមានឡាន ទាំងកុមារាកុមារីស្រីប្រុសក៏សូមឱ្យសំបូណ៌ដោយចំណេះវិជ្ជា ផ្លូវលោកផ្លូវធម៌ គឺរៀនអក្សរឆាប់ចាំ រៀនលេខឆាប់

ចេះ ប្រលងឆាប់ជាប់ចាក់ម្ជុលឆាប់ចូល។ ហើយបើអស់លោកទៅរកទទួលទានក្រៅផ្ទះ សូមបានប្រកបតាមសេចក្តីប្រាថ្នា បើចុះទឹកកុំឱ្យជួបក្រពើ ឡើងលើកុំឱ្យជួបខ្លាំ ទៅព្រៃកុំឱ្យមុតបន្លា ទៅផ្សារកុំឱ្យជួបប៉ូលិស ។

យំ យំ ឥច្ឆិតំ តំ តំ សមិច្ឆតុ សេចក្តីប្រាថ្នាដែលអស់លោកតាំងចិត្តប្រាថ្នាយ៉ាងណាៗ ក៏សូមឱ្យបានសម្រេចយ៉ាងនោះៗចុះ ធម៌ទេសនាក៏សន្មតថាចប់ដោយសង្ខេប **ឯវំ** ។

(ក្នុងប្រជុំធម្មទេសនា ដែលបានិពន្ធពីឆ្នាំ ១៩៦០)

★ ★ ★

# កម្មឱ្យផលតាមពូជដើម

ពរទាំងឡាយ ៥ប្រការគឺ :

**អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ បដិភាណៈ១** ។

ពរទាំង ៥ប្រការនេះ **ខឡ្សន្ត** ចូរចម្រើនកើតមានដល់បណ្តាអស់លោកជាពុទ្ធសាសនូបត្ថម្ភទាំងឡាយ ដែលបានអញ្ជើញអំពីទីជិតក្តី ឆ្ងាយក្តីមកប្រជុំសន្និបាតក្នុងឱកាសនេះ សុទ្ធតែជាអ្នកមានសទ្ធាជ្រះថ្លាត្រងត្រាប់ស្តាប់យកនូវឱជារសនៃព្រះធម៌ទេសនា ហើយក៏បានអារាធនានិមន្តអាត្មាភាពឱ្យជាអ្នកសម្តែង អាត្មាភាពក៏ទទួលភារៈងារជាអ្នកសម្តែងធម៌ក្នុងឱកាសនេះដែរ ប៉ុន្តែបើអាត្មាសម្តែងទៅហើយ ក្រែងជួនជាមានលើសលោះខ្វះខាតបទបាទព្យញ្ជនៈ អក្ខរៈ បាលី សេចក្តីអធិប្បាយត្រង់កន្លែងណាមួយពុំសមរម្យតាមអធ្យាស្រ័យ អស់លោកក៏សូមអភ័យទោសដល់អាត្មាជាអ្នកសម្តែងព្រោះអស់លោកដែលបានអញ្ជើញមកស្តាប់ក្នុងឱកាសនេះ សុទ្ធតែមាននិស្ស័-យចិត្តថ្លើមផ្សេងៗគ្នា មិនមែនត្រូវគ្នាទាំងអស់ទេ ដូចលោកយាយ-តា ចូលចិត្តស្តាប់សាច់ធម៌សុទ្ធៗ ឯចំណែកអស់លោកដែលមានវ័យនៅក្មេងវិញ ចូលចិត្តស្តាប់ខាងរឿងរ៉ាវផ្សេងៗ នឹងព្រឹត្តិការណ៍ជីវិតដែលមានការទាក់ទងគ្នាជុំវិញខ្លួនក្នុងលោកបច្ចុប្បន ដូចនេះការសម្តែងនេះ បើតម្រូវអធ្យាស្រ័យខាងណាម្ខាងគង់ខុសខាងម្ខាងពុំខាន ។

ណ្ហើយចុះ! រឿងនេះស្រេចលើអាត្មាភាពជ្រើសរើសរកធម៌ត្រង់ណាមួយមកសម្តែងតម្រូវតាមកុសល ដែលអស់លោកធ្វើក្នុងឱកាសនេះផង តាមសតិបញ្ញាដែលអាត្មាភាពអាចសម្តែងទៅបានផង សូមចម្រើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)

ខ្ញុំព្រះករុណា សូមធ្វើអភិវន្ទនកិច្ចគោរពចំពោះព្រះត្រ័យសរណវត្ថុទាំង៣គឺ ព្រះពុទ្ធ និងព្រះធម៌ ព្រមទាំងព្រះអរិយសង្ឃ ដោយសេចក្តីគោរពយ៉ាងសង្ខេបខ្លីតែប៉ុននេះ ។

**តទនន្តរំ ធម្មំ ទេសេស្សាមិ** បន្ទាប់បន្សំអំពីបទនមស្សការនេះទៅអាត្មាភាពសូម

លើកយកនូវធម៌មកសម្តែងបញ្ជាំងបំភ្លឺដល់អស់លោកជាពុទ្ធបរិសទ្យទាំងឡាយ អំពីពាក្យថា "**កម្មឱ្យផលតាមពូជដើម**" ព្រះសក្យមុនីគោត្តមជារបមគ្រូនៃពុទ្ធសាសនិកជន ទ្រង់ប្រកាសសាសនាដល់បរិសទ្យរបស់ព្រះអង្គឱ្យជឿ "**កម្មនិងផលនៃកម្ម**" គឺឱ្យជឿថា កម្ម "**អំពើដែលសត្វលោកធ្វើដោយកាយ វាចា ចិត្ត**" មានល្អ មានអាក្រក់ អំពើល្អ ហៅថា កល្យាណកម្ម ឬកុសលកម្ម អំពើអាក្រក់ ហៅថា បាបកម្ម ឬអកុសល ដ្បិតកម្ម គឺអំពើដែលខ្លួនធ្វើនេះតែកើតមក ក៏សឹងតែមានផលកម្ម ជាប់មកផងពុំមានឃ្លាត ជាពូជពង្សវស្សាគណាញាតិមិត្តសម្លាញ់ថា បើអំពើអតីតៈខ្លួនប្រាណប្រព្រឹត្តល្អ ឬអាក្រក់ ដល់ខ្លួនកើតមាននេះ ក៏ត្រូវតែទទួលនូវមរតកនោះៗពុំខាន ថាបើក្នុងបច្ចុប្បន្នជាតិនេះ ខ្លួនយើងបានធ្វើនូវអំពើអ្វីមួយ ជាបុណ្យ ឬបាបទាំងប៉ុន្មានលុះដល់ខ្លួនទំលុះកាយ ទំលាយខន្ធអំពីជាតិនេះ ទៅកាន់លោកខាងមុខទៀតក៏មិនអាចនឹងឃ្លាតអំពីផលកម្ម ដែលខ្លួនបានធ្វើនោះឡើយ ។ មានជនពួកខ្លះក្នុងលោកនេះ ច្រើនយល់ជ្រុល បើខ្លួន មិនបានប្រព្រឹត្តអំពើអ្វីមួយមិនគប្បី ហើយមានគេស្តីបន្ទោស ខ្លួនក៏ឆ្លើយឡើងថាៈ ខ្ញុំមិនចង់ធ្វើប៉ុន្មានដែរ តែនេះវាបណ្តាលមកពីកម្មរបស់ខ្ញុំទេ អើសម្តីនេះបើស្តាប់ទៅ ឃើញថា នេះគេមានអត្តភាពមួយពូកែដែរ សូម្បីតែចិត្តគេមិនចង់ធ្វើផង តែកម្មនោះ បង្វែរទៅផ្លូវណា ចិត្តរបស់គេក៏សឹងមានប្រទិចបែរទៅផ្លូវនោះ បើប្រសិនជាកម្មនោះ ដូចនោះមែន ព្រះសម្ពុទ្ធជាម្ចាស់នៃយើង មិនមែនទ្រង់ប្រដៅឱ្យពួកបរិសទ្យហាត់ធ្វើ សីល សមាធិ បញ្ញាអ្វីដែរ បើទុកជាធ្វើទៅហើយក៏គ្មានប្រយោជន៍អ្វីព្រោះវាស្រេចតែ លើកម្មដឹកនាំទៅផ្លូវណាក៏បាន ។

ម្យ៉ាងទៀត បើថាកម្មនោះក្រៅចិត្តរបស់ខ្លួនមែន បុរសដែលចង់បានស្ត្រីជាភរិយា មិនចាំបាច់ទៅរកអ្នកផ្លូវថៅមហាទៅដណ្តឹងរៀបអាពាហ៍ពិពាហ៍នាំឱ្យខាតទុន សូន្យទ្រព្យនោះឡើយ ត្រូវតាំងចិត្តនៅឱ្យស្ងៀមតែម្យ៉ាងទុកឱ្យកម្មគេចាត់វិធានការណ៍ ក៏គង់តែកម្មនោះចាប់ផ្សំផ្គុំគ្នាស្រេចមិនបានខ្វល់។

តាមពិតកម្មនេះ មិនមែនមានកន្លែងណាមួយនៅឯណានោះឡើយ គឺជាចិត្តនេះ ឯងហើយនាំឱ្យធ្វើកម្ម ដូចឧត្តគតិបុរាណចារ្យតែងពោលថាសក់ល្អព្រោះប្រេង ទឹករឹង ព្រោះខ្យល់ កម្មអកុសលព្រោះចិត្ត ។

ដូចនេះ ត្រង់ឧត្តគតិនេះហើយ ដែលបុរាណចារ្យបានលាតសន្ធឹងឱ្យឃើញ

ច្បាស់ថា គឺជាតួចិត្តនេះឯងហើយ ដែលជារោងចក្រសម្រាប់ធ្វើផលិតកម្ម។

កម្មជាកុសល ឬអកុសល តែងឱ្យអំណោយផលច្រើនប្រការ តែក្នុងឱកាសនេះ អាត្មាភាពសូមសម្ដែងតែផលក្នុងសង្ខិតកថា ដូចតទៅនេះ :

សេចក្ដីថា បុគ្គលឯណាមានកម្ម គឺអំពើដែលខ្លួនធ្វើ ទោះបីធ្វើកម្មជាកុសលក្ដី អកុសលក្ដីក្នុងបច្ចុប្បន្ន ហើយឱ្យអំណោយផលក្នុងបច្ចុប្បន្ន ផលនេះជាផល **ទិដ្ឋវេទ-នីយកម្ម** បើឱ្យអំណោយផលបន្ទាប់អំពីជាតិនេះហៅថា **ឧបបជ្ជវេទនីយកម្ម** បើថាធ្វើក្នុងបច្ចុប្បន្នជាតិនេះ តែដល់ទៅជាតិទី៣ រឺច្រើនជាតិទៅទៀត ទើបឱ្យអំណោយផលហៅថា **អបរាបរវេទនីយកម្ម** កម្មដែលផ្ដល់អំណោយផលកម្មផ្សេងពីគ្នាយ៉ាងនេះ មានកន្លែងខ្លះសម្ដែងថា : ព្រោះជនដែលប្រព្រឹត្តធ្វើនូវកម្មនោះ មានចេតនាមិនដូចគ្នា មានអន់ មានក្លាហាន ។

ន័យមួយទៀត ផលកុសលកម្ម និងអកុសលកម្ម មានឱ្យផលកាត់មុខគ្នាក្នុងបច្ចុប្បន្នក៏មាន ដូចអង្គុលីមាលដែលធ្វើឃាតកម្មមនុស្សអំណោយផលត្រូវព្រះមហាក្សត្រចាប់ពិឃាដប្រហារជីវិត តែដោយអំណោយកម្មដែឡបានព្វជ្ជាជាបព្វជិតហើយបានទាំងសម្រេចជាព្រះអរិយផលកម្មល្អ អាចទៅកាត់ផលអាក្រក់បានរួចខ្លួនទទេយ៉ាងនេះក៏មាន ឯផលកម្មអាក្រក់ទៅកាត់ផលល្អនោះ ដូចមានរឿងនិទានអំពីព្រះបាទអជាតសត្តុរាជព្រះមហាក្សត្រក្រុងមគធៈ បើតាមផលល្អអំពីអតីតៈមក ត្រូវបានសម្រេចអរិយបុគ្គលក្នុងបច្ចុប្បន្នដែលព្រះអង្គនៅក្នុងព្រះរាជសម្បត្តិ តែផលអ្នកអាក្រ-ក់ទៅកាត់ឧបនិស្ស័យព្រោះទ្រង់ធ្វើបិតុឃាដឱ្យព្រះបិតាក្ស័យព្រះជន្ម បានជាលោកឱ្យពិចារណាថា យើងជាអ្នកទទួលនូវផលខាងអាក្រក់ ឱ្យប្រែខានទទេសោះនោះពុំមានឡើយ ។ ដូចមាននិទានអំពីរឿង ឧត្តរៈសាមណេរមួយទៀត ដែលមាននៅក្នុងគម្ពីរធម្មបទដ្ឋកថាថា :

កាលសាសនាព្រះសម្ពុទ្ធព្រះនាមសុមេធៈ មានវិជ្ជាធរ១រូបនៅក្នុងព្រៃហេម-ពាន្ត ជាអ្នកមានសេចក្ដីជ្រះថ្លាមុតមាំក្នុងព្រះពុទ្ធសាសនា ។ ថ្ងៃមួយព្រះអរហន្តសម្ពុទ្ធព្រះនាមសុមេធៈ ទ្រង់យាងទៅកាន់ព្រៃហេមពាន្តវិជ្ជាធរបានចូលទៅនមស្សការថ្វាយបង្គំបូជាផ្កាកណ្ណិកា ៣ទង ដោយអំណាចជ្រះថ្លានឹងពុទ្ធតេជៈផ្កា ៣ទងនោះក៏ប្រតិស្ឋានលើអាកាសបាំងព្រះសម្ពុទ្ធហាក់ដូចជាបាំងទិព្វ។ វិជ្ជាធរនោះក៏មានបីតិ

សោមនស្សក្រៃលែងចំពោះពុទ្ធបូជារបស់ខ្លួន លុះអស់អាយុបានទៅកើតក្នុងទេវលោក សោយសុខអស់កាលជាយូរអង្វែង មិនដែលធ្លាប់ទៅអបាយភូមិម្តងឡើយ ។

លុះដល់មកព្រះសាសនាព្រះសម្ពុទ្ធរបមគ្រូយើងនេះ បានមកកើតក្នុងត្រកូលព្រាហ្មណ៍មហាសាសនាក្រុងរាជគ្រឹះ មានឈ្មោះថា ឧត្តរកុមារជាអ្នកមានបញ្ញាឈ្លាសវៃនិងបរិបូណ៌ដោយរូបសម្បត្តិល្អឆើតជាអ្នកនគរទាំងអស់។

ឧត្តរកុមារនេះមានអាយុ ១៦ឆ្នាំមានព្រាហ្មណ៍ម្នាក់ឈ្មោះវស្សការជាមហាមាត្យ បានឃើញឧត្តរកុមារមារូបល្អ ចង់បានធ្វើជាកូនប្រសារ បានប្រើអ្នកបម្រើឱ្យទៅប្រាប់ដល់មាតាបិតារបស់ឧត្តរកុមារ ឱ្យចូលមកដណ្តឹងកូនក្របុំរបស់ខ្លួន ។ ចំណែកឧត្តរកុមារវិញឮដំណឹងនោះហើយ ក៏ហាមឃាត់មាតាបិតាមិនឱ្យចូលទៅដណ្តឹង ព្រោះចង់ចេញទៅបួស មាតាបិតាព្រមតាម។ មិនយូរប៉ុន្មានឧត្តរកុមារក៏លាមាតាបិតាចូលបួសក្នុងសម្នាក់ព្រះសារីបុត្តខំប្រតិបត្តិធម៌វិន័យដោយផ្ចិតផ្ចង់ ។

ថ្ងៃមួយព្រះសារីបុត្រ ជាឧបជ្ឈាយ៍មានអាពាធ ឧត្តរសាមណេរក៏លាឧបជ្ឈាយ៍ទៅរកថ្នាំ ទៅដល់ស្រះមួយដាកបាត្រក្រោដើមឈើ ចុះទៅស្រង់ទឹកក្នុងវេលាព្រឹកព្រហាម ពេលនោះជួនជាមានចោរលួចបង្វិចទ្រព្យអ្នកនគរពួករាជអាមាត្យដេកតាមចោរបានយកបង្វិចទ្រព្យទៅដាក់ក្នុងបាត្ររបស់សាមណេរហើយរត់ហួសទៅ។ ពួករាជអាមាត្យទៅឃើញបង្វិចទ្រព្យនៅក្នុងបាត្រក៏ចាប់សាមណេរនោះ យកមកឱ្យវស្សការព្រាហ្មណ៍ជាមហាមាត្យដោយសំគាល់ថា : សាមណេរនេះជាចោរពិត។ វស្សការមហាមាត្យស្គាល់ជាក់ថាឧត្តរសាមណេរហើយ ក៏កោធសេចក្តីក្រោធឡើង ព្រោះចងគំនុំនឹងឧត្តរសាមណេរដែលមិនព្រមទទួលយកកូនក្រមុំរបស់ខ្លួន បានប្រើពេជ្ឈឃាដចាប់សាមណេរចង់ស្លាបសេកយកទៅដោតលើចុងឈើ ចាប់ទំលុះទំលាយមានឈាមហូរពាសពេញខ្លួន ។ សាមណេរខំអត់អន់មិនអើពើនឹងការចាក់ដោតនោះឡើយខំបញ្ជូនចិត្តទៅរកឧបជ្ឈាយ៍ នឹងថាបាននរណាយកថ្នាំទៅប្រគេនឧបជ្ឈាយ៍របស់អញ! ម្ល៉េះលោកចាំមើលផ្លូវអញយ៉ាងណាទៅហ្ន៎! កំពុងតែគិតដូចនោះព្រះសារីបុត្រជាឧបជ្ឈាយ៍លោកជ្រាបថា :

ឧត្តរសាមណេរកំពុងត្រូវទោសជាទំងន់ ក៏ទៅក្រាបទូលដល់ព្រះសម្ពុទ្ធព្រះសម្ពុទ្ធទ្រង់ជ្រាបថា សាមណេរនេះមានឧបនិស្ស័យខ្ពស់ល្មមព្រះអង្គទៅជួយសង្គ្រោះ

បាន ក៏ស្ដេចយាងទៅដល់នោះមួយរំពេច ជាមួយនឹងភិក្ខុសង្ឃជាច្រើនពាន់អង្គ។

ឯឧត្តរសាមណេរ កាលបើឃើញព្រះសម្ពុទ្ធស្ដេចយាងទៅដល់ហើយ ក៏ថ្លែងសេចក្ដីទុក្ខរបស់ខ្លួនថ្វាយព្រះសម្ពុទ្ធៗ ទ្រង់យកព្រះហស្ដស្ទាបព្រះសិរសាឧត្តរសាមណេរយ៉ាងថ្នាក់ថ្នម មានពន្លឺរស្មីផ្សាយចេញពីព្រះហស្ដភ្លឺរន្ទាលទើបមានព្រះពុទ្ធដីកាថា : "ម្នាលសាមណេរអ្នកកុំតូចចិត្ត អំពើនេះជាអំពើរបស់អ្នកបានសន្សំទុកមកយូរហើយ អ្នកទទួលទុក្ខលំបាកម្ដងនេះជាទីបំផុតហើយលែងមានតទៅទៀត ទ្រង់រំលឹកយ៉ាងនេះហើយ ទ្រង់នាំអតីតៈនិទានមកសម្ដែងប្រាប់ថា: កាលកន្លងយូរយារណាស់ហើយ នេនឯងកើតជាកូនអ្នកស្រែបានចាប់រុយយកបន្លាដោតគូថ ហើយយកទៅដោយភ្ជាប់នឹងសំបកស្ដៅសើចលេងសប្បាយ មាតាបិតាស្ដីបន្ទោស បានចំអកឱ្យវិញថា បើមិនឱ្យដោតរុយលេង មានតែដោតម៉ែឯងលេង។ ដោយអំពើអាក្រក់នេះឯងបានជានេនឯងទទួលនូវសេចក្ដីលំបាក ដោយគេដោតឱ្យដេកលើឈើអណ្ដោតរាប់រយពាន់ជាតិមកហើយ។ ម្យ៉ាងទៀតដែលតថាគតមកជួយសង្គ្រោះនេះ ដោយផលដែលនេនឯងកើតជាវិជ្ជាធរ បានបូជាកណ្ណិកាបីទងដល់ព្រះសម្ពុទ្ធព្រះនាមសុមេធៈ។

កាលបើព្រះសម្ពុទ្ធមានព្រះពុទ្ធដីកាចប់ហើយ ឧត្តរសាមណេរក៏សម្រេចព្រះអរហន្តផលព្រមទាំងបដិសម្ភិទា ហើយទៅឰដ៏អាកាសធ្វើបដិហារ្យថ្វាយព្រះសាស្ដាយ៉ាងអស្ចារ្យ ដល់ទីបំផុតព្រះជន្មក៏បរិព្វានទៅ។

**សាធុរោ**! អស់លោកសប្បុរសទាំងឡាយ! អាត្មាទាញរឿងមកប៉ុននេះនេះ ដើម្បីបញ្ជាក់ឱ្យឃើញថា : កម្មជាកុសលក្ដី អកុសលក្ដី ដែលខ្លួនបានធ្វើទុកមកហើយ តែដល់ពេលហុចឱ្យ ត្រូវតែទទួលចៀសពុំរួចឡើយដូចជាឧត្តរសាមណេរដែលបានទទួលទុក្ខលំបាកដូចនោះ ក៏ព្រោះតែផលអកុសលកម្មហុចឱ្យ ដែលបានសម្រេចព្រះអរហន្តផលនោះ ក៏ព្រោះតែផលជាកុសលដែលលោកបានថ្វាយផ្កាកណ្ណិកា៣ទងដល់ព្រះសម្ពុទ្ធហុចឱ្យ ។

ត្រង់នវហើយ ដែលឈ្មោះថា "កម្មឱ្យផលតាមពូជដើម ព្រះសក្យមុនីសព្វញ្ញុពុទ្ធជាសាស្ដាចារ្យឯករបស់យើង ទ្រង់ពុំដែលប្រៀនប្រដៅថាឱ្យពុទ្ធសាសនិកជនផ្អែកវេរគំនិតអាងដល់ព្រះអង្គ សូមឱ្យព្រះអង្គជួយទទួលបាបជំនួសខ្លួននោះសោះឡើយ ព្រោះទ្រង់ជ្រាបតាមការពិតថា: សត្វលោកសុទ្ធតែមានកម្មជារបស់ខ្លួនរាល់រូប ទាំង

ព្រះអង្គដែរ ។

ទ្រង់មានព្រះពុទ្ធតម្រាស់បញ្ជាក់ថា ព្រះតថាគតជាព្រះពុទ្ធគ្រាន់តែជាអ្នកដឹង ហើយប្រកាសប្រាប់អ្នករាល់គ្នាឱ្យដឹងផងប៉ុននោះ ពុំមែនទទួលរ៉ាប់រងអំពើរបស់អ្នកទេ ការធ្វើ ការប្រតិបត្តិប្រព្រឹត្តកាន់ ជាការផ្ទាល់ខ្លួនរាល់រូបឥតមានអ្នកណាជំនួសអ្នកណា កើតទេ ទាំងសេចក្ដីបរិសុទ្ធ និងសេចក្ដីសៅហ្មង ក៏ជំនួសគ្នាពុំកើតដូច្នោះដែរ ។

នេះជាការពិតឥតមានល្អៀង សូម្បីមាតាបិតាបង្កើត ដែលប្រព្រឹត្តគន្លងច្បាប់ មានទោសកំហុសត្រូវជាប់មន្ទីរឃុំឃាំង ឬត្រូវប្រហារជីវិត បុត្រធីតាអ្នកមានកតញ្ញូ កតវេទិតាធម៌ ក៏ពុំអាចសុំធានអះអាងទទួលទុក្ខទោសនោះជួសអ្នកមានគុណបាន ឡើយ កម្មរបស់បុគ្គលណា បុគ្គលនោះត្រូវទទួលរ៉ាប់រងដោយខ្លួនឯង ។ ហេតុនេះ ហើយបានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា : សត្វទាំងឡាយសុទ្ធតែមានកម្មជារបស់ខ្លួន ឥតមានបុគ្គលណាទទួលទោស ទទួលបាបជួសបុគ្គលណាកើតទេ។ សមដូចសុភា-សិតលោកថា : សុចរិត ទុច្ចរិតដែលខ្លួនប្រព្រឹត្តក្នុងជាតិនវណា ជាប់ជានិស្ស័យ បច្ច័យ វាសនា ជិតជាប់អាត្មាទៅបរលោកនាយ ។

សាធុរ៉ា! អស់លោកសប្បុរសទាំងឡាយ! វៀរលែងតែព្រះអរហន្តដែលលោក ចូលកាន់អនុបាទិសេសនិព្វានទៅហើយ ទើបពុំមានផលកម្មប្រចាំនៅ ហៅថា **អហោ-សិកម្ម** ។ ហេតុនេះ អស់លោកទាំងឡាយ! គួរប្រតិបត្តិឱ្យចាំព្រះបណ្ដាំនេះ គប្បីរៀន ហាត់ចិត្តឱ្យផុតចាកកិលេសគឺ: **រាគៈ ទោសៈ មោហៈ** ឧស្សាហ៍លះអកុសលឱ្យដល់ ព្រះនិព្វាន ឱ្យជាអហោសិកម្ម ដែលគ្មានផលកម្មអ្វីមកកាត់មុខ ។

ព្រះបរមពុទ្ធាធិប្បាយដែលទ្រង់សម្ដែងទុក គួរឱ្យចេះពិចារណាមិនគួរមាន ឧបាទានឱ្យជាប់ភព តែជាប់ភពហើយ គង់តែមានជាតិ ព្យាធិមរណៈសេចក្ដីព្រាត់ ប្រាស ពីព្រោះហេតុគឺខ្លួនធ្វើ។ ដ្បិតបុថុជ្ជនចិត្តមិនទៀងរមែងធ្វើល្អខ្លះ អាក្រក់ខ្លះ ជួន កាលផ្លាស់ពីមនុស្សទៅទេវលោក ជួនពីសុគិតទៅអបាយ ដោយផលនៃកម្ម ដ្បិតចិត្ត ត្រាំនៅក្នុងអាសវៈ ម៉្លោះហើយចិត្តនេះឯងវាតែងតែដឹកនាំ ម្ដងទៅខាងនេះ ម្ដងទៅ ខាងនោះ បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ប្រាប់ពុទ្ធបរិសទ្យរបស់ព្រះអង្គឱ្យរៀនពត់ចិត្ត ឱ្យបានល្អ ដូចមានបាលីសម្ដែងថា : **សចិត្តបរិយោទបនំ** ប្រែថា : "ចិត្តឱ្យបរិសុទ្ធ" បានសេចក្ដីថាបើនរជនជាតិគ្រហស្ថបុរសស្ត្រី ដែលបានជំរះចិត្តខ្លួនឱ្យបរិសុទ្ធផុងល្វង់

គឺមិនលោភ មិនខឹង មិនវង្វេង មានចិត្តស្អាតបរិសុទ្ធឥតមានអ្វីមកដឹកនាំបានឡើយ។ ព្រោះយើងដែលបានកើតមកជាមនុស្សហើយ លុះតែមកដឹកនាំបានឡើយ។ ព្រោះយើងដែលបានកើតមកជាមនុស្សហើយ លុះតែរៀនហាត់ចិត្តកំចាត់នូវសេចក្តីល្ងង់ទើបមានបញ្ញា មិនមែនដូចរុក្ខជាតិនោះឡើយ តាមពិតរុក្ខជាតិទាំងឡាយ ដែលដល់រដូវដល់ ក៏សឹងតែផ្កាឯងផ្លែឯងរុក្ខជាតិណាមានរស់ផ្អែម ក៏ផ្អែមឯង ជូរក៏ជូរឯងតាមធម្មជាតិរបស់ឈើ មិនចាំបាច់យកថ្នាំទៅចាក់ ឬដាក់ស្ករអ្វីឡើយ ។

បើជាមនុស្សជាតិយើងវិញ បើនឹងមានក្លិនក្រអូបល្អក៏ព្រោះតែលាបទឹកអប់ និងមានចំណេះវិជ្ជាសព្វគ្រប់ ក៏ព្រោះតែបានហាត់រៀនចិត្តចំណេះវិជ្ជាណាមកប្រតិស្ថាននៅលើកខ្លួនយើងទេ លុះណាតែស្វះស្វែងរកទើបបានសម្រេច។

សាធុសប្បុរសទាំងឡាយ! ដែលអាចនឹងឱ្យរួចចាកទុក្ខអំពីប្រាណបានលុះត្រាតែសម្រេចអរិយមគ្គ មានសោតាបត្តិមគ្គជាដើម ដរាបដល់អរហត្តផល ទើបបានដល់ព្រះនិព្វានផុតចាកទុក្ខ។

ហេតុនេះគួរពុទ្ធបរិសទ្យទាំងឡាយ ហាត់ធ្វើចិត្តឱ្យស្អាតប្រកបដោយលោកចេតនា ទោះបីធ្វើការ កុសលណានីមួយក៏ដោយ នៃតណ្ហា ប្រាថ្នាឥស្សរិយយស និងភោគសម្បត្តិក្នុងលោកនេះ ជាឧបសគ្គមួយសម្រាប់ស្ទាក់ដំណើរសត្វមិនឱ្យដល់ទីវិមុត្តិរួចផុតកាយ លុះតែលះតណ្ហា ទើបឈ្នះគ្រប់ប្រការដូចមានបាលីសម្តែងថា : **តណ្ហក្ខ-យោ សព្វទុក្ខំ ជិនាតិ** ប្រែតែធ្វើឱ្យអស់តណ្ហា ទើបឈ្នះទុក្ខទាំងពួង ។

សេចក្តីពិតថា : ទុក្ខទាំងពួងដែលគ្មាន ក៏មកអំពីអស់តណ្ហា ឯតណ្ហាដែលអស់ក៏មកអំពីបញ្ញាប្រហារ ដែលកើតបញ្ញា ក៏មកអំពីរៀនហាត់ សមាធិដែលនឹងកើតជាសមាធិ មកអំពីជាប់សីល ព្រោះសីលនេះជាមេផ្តើមឬដើមផ្លូវជាក្បាលស្ពាន មានបាលី **សីលំ សេតុ មហេសក្ខោ** ប្រែថាសីលជាស្ពានមានស័ក្តិដ៏ធំ គឺថាសីលនេះជាស្ពានដែលបុគ្គលមានបំណងនឹងធ្វើដំណើរទៅកាន់ព្រះនិព្វាន ដែលជាទីក្រុងដ៏ធំ ព្រោះសីលនេះជាមេដើមហេតុឱ្យកើតសមាធិបញ្ញា លះតណ្ហាបានសម្រេចមគ្គផលដល់ព្រះនិព្វាន។

ឯសីលឧបោសថនោះ បើរក្សាឱ្យសម្រេចផលប្រយោជន៍ ឃើញមានបទសម្តែ-ងថា : លុះតែប្រកបដោយវិរិយៈ ៤ប្រការគឺ :

ប្រការទី១ មានព្រះបាលីថា : **កាលេន ធម្មស្សវនំ** បានសេចក្តីថាក្នុងរវាងកាល

ដែលបានរក្សានូវឧបោសថនោះ ត្រូវសវនាការព្រះសទ្ធម្មទេសនាដើម្បីឱ្យមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាស្គាល់ផ្លូវសម្មាបដិបត្តិពេញទី។

ប្រការទី២ **កាលេន ធម្មសាកច្ឆា** ក្នុងរវាងកាលនោះ ត្រូវធម្មសាកច្ឆាដើម្បីកម្ចាត់បង់នូវវិចិកិច្ឆា យល់ផ្លូវបញ្ញាសព្វសេចក្តី ។

ប្រការទី៣ **កាលេន សមថោ** ក្នុងរវាងកាលនោះ ត្រូវធ្វើសមថភាវនាដើម្បីកម្ចាត់បង់នូវនីវរណៈឱ្យដល់ថ្នាក់សមាធិយ៉ាងមាំមួន។

ប្រការទី៤ កាលេន វិបស្សនា ក្នុងរវាងកាលនោះ ត្រូវចម្រើនវិបស្សនាភាវនាដើម្បី ឱ្យកើតបញ្ញាប្រហារនូវកិលេសតណ្ហាឱ្យដាច់និងសម្រេចមគ្គផលដល់ព្រះនិព្វាន។

ហេតុនេះបានជាថា បើបានរក្សាឧបោសថសីល ហើយថែមទាំងមានវិរិយៈទាំង៤ប្រការ ទើបចាត់ថាសិលនេះពេញពិតជាស្ពានបាន បើប្រសិនជាបុគ្គលគ្រាន់តែតែងខ្លួនហ៊ឹហា ហើយដើរទៅឈរយកខ្យល់អាកាស តែត្រឹមក្បាលស្ពាន ហើយមិនធ្វើដំណើរឆ្លងទៅទៀត មុខជាមិនឃ្លាតដល់ភូមិលោកុត្តរៈឡើយ ។ ឯយើងជាបុថុជ្ជនធ្ងន់ដោយកិលេស គួរតែមានវិរិយៈតាមបទដែលលោកប្រដៅ កុំគប្បីអាងលើឧបនិស្ស័យនោះឡើយ សូម្បីព្រះសម្ពុទ្ធជាម្ចាស់ដែលព្រះអង្គមានឧបនិស្ស័យយ៉ាងក្រាស់ បានសាងព្រះបារមីយ៉ាងពេញបន្ទុកជាច្រើនកប្បមកហើយ ដល់មកជាតិដែលព្រះអង្គបានត្រាស់ដឹង ព្រះអង្គតែងមានវិរិយៈព្យាយាមយ៉ាងក្រៃពេកណាស់ ។

អស់លោកទាំងឡាយ គង់បានជ្រាបស្រាប់ហើយ ក្នុងទុក្ករៈកិរិយានោះមិនមែនឧបនិស្ស័យមកប្រតិស្ថានថ្វាយឱ្យព្រះអង្គត្រាស់ដឹងស្រួលៗនោះទេ ឧបនិស្ស័យនេះអស់លោកប្រៀបដូចយើងដែលបរិបូណ៌ដោយពូជស្រូវពេញជង្រុកមិនខ្វះខាត លទ្ធផលដែលយើងបានទទួលពូជស្រូវគ្រប់គ្រាន់ដូចនវ ក៏ព្រោះតែយើងខំកាប់គាស់រាស់ភ្ជួរ ហើយយកពូជស្រូវនោះទៅសាបព្រួសទើបបានផល ដ្បិតពូជស្រូវឥតជើងមិនអាចនឹងទៅដល់ក្នុងស្រែនោះឡើយ ។ ហេតុនេះអស់លោកទាំងឡាយ! គប្បីមានវិចារណញ្ញាណមានគំនិតប្រកបដោយសម្មាទិដ្ឋិ គួរប្រព្រឹត្ត ដោយចរិយាវត្តឱ្យស្ទាត់ជំនាញ កុំគប្បីទម្រន់សម្អាងទៅលើអ្វីៗ នោះឡើយ ដែលធ្វើឱ្យផុតអំពីព្រំដែននៃសេចក្តីទុក្ខទៅបានក៏ព្រោះតែចេះកម្ចាត់សេចក្តីល្ងង់ឱ្យផុត ហើយមានសេចក្តីព្យាយាមបំពេញ

ចំណេះវិជ្ជា ពាក្យថា ចំណេះជាភាសាខ្មែរ បើហៅជាភាសាបាលីថា "វិជ្ជា" បើឥត ចំណេះហៅថា "អវិជ្ជា" ចំណែកយើងរាល់គ្នាដែលកើតមកនេះ សុទ្ធតែឥតចំណេះគឺ វិជ្ជា លុះតែបានសិក្សា ទើបមានចំណេះ គឺវិជ្ជាវិជ្ជានេះបើមានប្រាកដហើយអាចកម្ចាត់ អវិជ្ជាបាន ឯវិជ្ជាមានច្រើនយ៉ាងដែលធ្វើឱ្យចម្រើនក៏មានធ្វើឱ្យវិនាសក៏មាន ដូចបាលី សម្តែងថា :

**សុវិជ្ជានោ ភវំ ហោតិ ទុវិជ្ជានោ បរាភវោ** សេចក្តីថា : អ្នកមានវិជ្ជាល្អ រមែង ចម្រើន អ្នកមានវិជ្ជាអាក្រក់រមែងវិនាសទៅខាងមុខ។ ម្យ៉ាងទៀត លោកសម្តែងថា យោគាវចរកុលបុត្រឯណា បានបង្ហាត់ចិត្តរៀនវិជ្ជាផ្សេងៗ ញ៉ាំងកាលសុចរិត វចីសុច-រិត មនោសុចរិត អប់រំឱ្យឋិតនៅក្នុងកុសលកម្មបថ ១០ប្រការ ចេះធ្វើទាន សីល ភាវនា ប្រព្រឹត្តត្រឹមត្រង់តាមផ្លូវអដ្ឋង្គិកមគ្គទាំង ៨មានសតិសម្បជញ្ញៈប្រកបដោយ **វិរិយ** ក្នុងព្រំដែន**វិបស្សនា** មានបញ្ញានេះប្រហារនូវអវិជ្ជា និងតណ្ហា វិជ្ជាដូចនវ ព្រះ បរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា វិជ្ជាល្អ រមែងចម្រើន ឯវិជ្ជាអាក្រក់ក៏មានច្រើន តែបើ ពោលឱ្យខ្លីមក គឺវិជ្ជាណាមួយក្តី ដែលប្រលាក់ដោយកិលេសតណ្ហា ឬគ្រឿងពិឃាដ ឱ្យសត្វលោកបាត់បង់ជីវិត វិជ្ជាដូចនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា វិជ្ជាអាក្រក់ រមែងវិនាសទៅខាងមុខ ។

**ចប់**

★ ★ ★